The table below presents the undiscounted cash flows arising from financial assets and liabilities and commitments of the Bank based on the remaining contractual maturities as at the balance sheet date.

## 25. FINANCIAL RISK MANAGEMENT (CONTINUED)

### 25.3 Liquidity risk (continued)

#### (c) Non-derivative cash flows (continued)

| | Up to 1 month | 1 to 3 months | 3 to 12 months | 1 to 5 years | Over 5 years | Total |
|---|---|---|---|---|---|---|
| | US$ | US$ | US$ | US$ | US$ | US$ |
| **2016** | | | | | | |
| **Financial liabilities** | | | | | | |
| Deposits from banks and other financial institutions | (117,360,538) | (53,165,617) | (61,742,647) | - | - | (232,268,802) |
| Deposits from customers | (117,280,607) | (41,915,534) | (118,502,094) | (24,727,675) | - | (302,425,910) |
| Other liabilities | (5,572,949) | - | - | - | - | (5,572,949) |
| | (240,214,094) | (95,081,151) | (180,244,741) | (24,727,675) | - | (540,267,661) |
| **Total financial assets** | 150,976,415 | 53,595,665 | 110,924,596 | 170,457,040 | 281,166,234 | 767,119,950 |
| **Net liquidity gap** | (89,237,679) | (41,485,486) | (69,320,145) | 145,729,365 | 281,166,234 | 226,852,289 |
| In KHR'000 equivalent | (360,252,510) | (167,476,907) | (279,845,425) | 588,309,446 | 1,135,068,087 | 915,802,691 |
| **2015** | | | | | | |
| **Financial liabilities** | | | | | | |
| Deposits from banks and other financial institutions | (167,726,534) | (44,142,147) | (51,409,308) | - | - | (263,277,989) |
| Deposits from customers | (71,804,833) | (50,483,333) | (95,992,979) | (786,063) | - | (219,067,208) |
| Other liabilities | (5,617,693) | - | - | - | - | (5,617,693) |
| | (245,149,060) | (94,625,480) | (147,402,287) | (786,063) | - | (487,962,890) |
| **Total financial assets** | 101,449,404 | 60,044,844 | 83,937,240 | 92,007,126 | 272,084,379 | 609,522,993 |
| **Net liquidity gap** | (143,699,656) | (34,580,636) | (63,465,047) | 91,221,063 | 272,084,379 | 121,560,103 |
| In KHR'000 equivalent | (581,983,608) | (140,051,576) | (257,033,442) | 369,445,304 | 1,101,941,735 | 492,318,413 |

## 25. FINANCIAL RISK MANAGEMENT (CONTINUED)

### 25.4 Operational risk

Operational risk is the risk of loss resulting from inadequate or failed internal processes, people or systems, or from external events. This includes legal, compliance, accounting and fraud risk.

The Bank has established policies and procedures to provide guidance to the key operating units on the risk governance structure and baseline internal controls necessary to identify, assess, monitor and control their operational risks. Internal control policies and measures that have been implemented including the establishment of signing authorities, defining system parameter controls, streamlining procedures and documentation ensuring compliance with regulatory and legal requirements. The policies and procedures are reviewed periodically, taking into account the business objectives and strategies of the Bank as well as regulatory requirements.

The internal audit function provides independent assessment of the adequacy of the internal control policies and procedures of the Bank to mitigate risk associated with operational activities. Any findings arising from the audit and review will be escalated to the senior management of the Bank and the Audit Committees of the Bank and of the parent company.

### 25.5 Fair value of financial assets and liabilities

As at the interim balance sheet date, the fair values of financial instruments of the Bank approximate their carrying amounts.

The estimated fair values are based on the following methodologies and assumptions:

**(i) Balances and placements with banks and other financial institutions**

The fair values of balances and placements with banks and other financial institutions with maturity of less than one year approximate their carrying amounts.

**(ii) Loans and advances to customers**

For fixed rate loans with remaining period to maturity of less than one year, the carrying amounts are generally reasonable estimates of their fair values.

For fixed rate loans with remaining period to maturity of one year and above, fair values are estimated by discounting the estimated future cash flows using the prevailing market rates of loans with similar credit risks and maturities.

**(iii) Deposits from banks, other financial institutions and customers**

The fair values of deposits payable on demand (current and savings accounts), or deposits with remaining maturity of less than one year are estimated to approximate their carrying amounts. The fair values of deposits with remaining maturity of more than one year are estimated based on discounted cash flows using prevailing market rates for similar deposits from banks, other financial institutions and customers.

**(iv) Other financial assets and liabilities**

The carrying amounts of other financial assets and liabilities are assumed to approximate their fair values as these items are not materially sensitive to the shift in market interest rates.

## 25. FINANCIAL RISK MANAGEMENT (CONTINUED)

### 25.6 Capital management

The Bank's objectives when managing capital, which is a broader concept than the 'equity' on the face of the balance sheet, are:

To comply with the capital requirement set by the Central Bank;

- To safeguard the ability of the Bank to continue as a going concern so that it can provide returns to its shareholder and benefits for other stakeholders; and
- To maintain a strong capital base to support the development of business.

The Central Bank requires all commercial banks to i) hold a minimum capital requirement, ii) maintain the Bank's net worth equal at least to the minimum capital and iii) comply with solvency and liquidity ratios.

The table below summarises the composition of the Bank's regulatory capital:

| | 2016 | | 2015 | |
|---|---|---|---|---|
| | US$ | KHR'000 | US$ | KHR'000 |
| **Tier 1 capital** | | | | |
| Share capital | **67,000,000** | 270,479,000 | **67,000,000** | 271,350,000 |
| Retained earnings | **17,446,669** | 70,432,203 | **10,749,262** | 43,534,511 |
| Less: Intangible assets | **(295,308)** | (1,192,158) | **(353,150)** | (1,430,258) |
| Less: Loans to management | **-** | - | **(143,938)** | (582,949) |
| | **84,151,361** | 339,719,045 | **77,252,174** | 312,871,304 |
| **Tier 2 complementary capital** | | | | |
| General provision (1%) | **3,447,304** | 13,916,766 | **3,359,494** | 13,605,951 |
| Less: Equity participations in banking and financial institutions | **(25,000)** | (100,925) | **(25,000)** | (101,250) |
| | **87,573,665** | 353,534,886 | **80,586,668** | 326,376,005 |

The National Bank of Cambodia issued a Prakas No. B7-016-117, dated 22 March 2016, on "new minimum registered capital requirement for banks and financial institutions". It requires that commercial banks being a local entity or a subsidiary of foreign bank must have a minimum registered capital of at least KHR 300 billion (equivalent to US$75 million). The Prakas allows commercial banks to increase its capital to meet the new minimum registered capital requirement within 2 years from the date this Prakas.

On 16 June 2016, the Central Bank issued an instruction on the implementation of its Prakas No. B7-016-117, dated 22 March 2016, on "new minimum registered capital requirement for banks and financial institutions". The Instruction requires the banks to increase the additional capital at least 50% of the amount to fulfil the minimum registered capital by end of March 2017 and the remaining amount by 22 March 2018.

The Bank got approvals from the Board of Directors on 30 November 2016 and the Central Bank approved the capital injection plan of US$4 million in January 2017 for meeting the additional capital requirement by 31 March 2017.

របាយការណ៍ហិរញ្ញវត្ថុ 2016

ធនាគារ អ អេច ប៊ី ឥណ្ឌូចៃណា
RHB Indochina Bank



# ការអនុវត្តន៍ប្រកបដោយនិរន្តរភាព

យើងរួមគ្នាដើម្បីភាពរីកចំរើន

# មាតិកា

## ពត៌មានទូទៅអំពីធនាគារ




144 ពត៌មានទូទៅអំពីធនាគារ 148 ផ្នែកសំខាន់ហិរញ្ញវត្ថុឆ្នាំ 2016 150 សង្ខេបហិរញ្ញវត្ថុរយៈពេល 5ឆ្នាំ ផ្នែកសំខាន់ហិរញ្ញវត្ថុ 151 សង្ខេបហិរញ្ញវត្ថុរយៈពេល 5ឆ្នាំ 152 ផ្តល់ជូននូវដំណោះស្រាយសេវាធនាគារ 158 រចនាសម្ព័ន្ធគ្រប់គ្រង

## ភាពជាអ្នកដឹកនាំ



160 របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល 166 សមាសភាពក្រុមប្រឹក្សាភិបាល 169 ប្រធានក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល 170 របាយការណ៍អគ្គនាយកប្រចាំប្រទេសកម្ពុជា 176 សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ 181 គណៈកម្មាធិការគ្រប់គ្រង

## អភិបាល

182 របាយការណ៍ក្រុមប្រឹក្សាភិបាល 184 របាយការណ៍សវនករឯករាជ្យ 186 របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ 192 សកម្មភាពរបស់គណៈកម្មការសវនកម្ម និងមុខងារសវនកម្មផ្ទៃក្នុង



## របាយការណ៍ហិរញ្ញវត្ថុ

197 របាយការណ៍ហិរញ្ញវត្ថុ 2016



## ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា





# ពត៌មានទូទៅអំពីធនាគារ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃ




## វត្តមាន ប្រតិបត្តិការ និងការអនុវត្តន៍របស់យើង

### ការិយាល័យកណ្តាល

263 វិថីព្រះអង្គឌួង (វិថី110) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។
ទូរស័ព្ទលេខ : (855) 23 992 833 ទូរសារលេខ : (855) 23 991 822
អ៊ីម៉ែល: kh.customerservice@rhbgroup.com

### ទីស្នាក់ការកណ្តាល

ទីស្នាក់ការកណ្តាល ត្រូវបានដឹកនាំដោយ លោក ហួត អាង រួមជាមួយបុគ្គល 26នាក់។

263 វិថីព្រះអង្គឌួង (វិថី110) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 992 833
ទូរសារលេខ : (855) 23 991 822

អ៊ីម៉ែល: kh.phnompenhmain@rhbgroup.com

### សាខា ស៊ីធីម៉លអូឡាំពិក

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ស៊ីធីម៉ល អូឡាំពិក ត្រូវបានដឹកនាំដោយ លោក គៀង ច័ន្ទវាសនា រួមជាមួយបុគ្គល 17នាក់។

ទីតាំងឡូត៍លេខ អាបីអឹស៊ីវ៉ូ ជាន់ផ្ទាល់ដីផ្សារស៊ីធីម៉ល វិថីមុន្នីវ៉េត រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 993 568

ទូរសារលេខ : (855) 23 993 565

អ៊ីម៉ែល: kh.citymall@rhbgroup.com

### សាខា ស្ទឹងមានជ័យ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ស្ទឹងមានជ័យ ត្រូវបានដឹកនាំដោយ កញ្ញា ជឹម ស្រីណុន រួមជាមួយបុគ្គល 12នាក់។

ទីតាំងវិថីមុន្នីវ៉េត (ផ្លូវ 217) កែងផ្លូវចាក់សំរាម រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 969 228

ទូរសារលេខ : (855) 23 969 231

អ៊ីម៉ែល: kh.stoeungmeanchey@rhbgroup.com

## សាខា ក្បាលថ្នល់

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ក្បាលថ្នល់ ត្រូវបានដឹកនាំដោយ លោក ញឹម បូរី រួមជាមួយ បុគ្គល 12នាក់។

ទីតាំងអគារលេខ 530អា - 530ប៊ី មហាវិថីមុនីវង្ស (កែងវិថី 271) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 993 598
ទូរសារលេខ : (855) 23 993 593

អ៊ីម៉ែល: kh.stoeungmeanchey@rhbgroup.com

## សាខា ពេទ្យលោកសង្ឃ

ធនាគារអ អេចប៊ី ឥណ្ឌូឆៃណា សាខា ពេទ្យលោកសង្ឃ ត្រូវបានដឹកនាំដោយ លោក ទៀង សុធារ៉ូ រួមជាមួយ បុគ្គល 11នាក់។

ទីតាំងអគារលេខ 1 - 3 វិថី 271 រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 969 368
ទូរសារលេខ : (855) 23 969 370

អ៊ីម៉ែល: kh.petloksong@rhbgroup.com

## សាខា ទួលគោក

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ក្បាលថ្នល់ ត្រូវបានដឹកនាំដោយ លោក ហួត សុវវឌ្ឍនៈ រួមជាមួយបុគ្គល 12នាក់។

ទីតាំងអគារលេខ 18ស៊ី គីមអ៊ីលស៊ុង (វិថី 289) រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 989 600
ទូរសារលេខ : (855) 23 989 606

អ៊ីម៉ែល: kh.toulkork@rhbgroup.com

## សាខា ម៉ៅសេទុង

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ម៉ៅសេទុង ត្រូវបានដឹកនាំដោយ លោក សុក សុផេង រួមជាមួយ បុគ្គល 11នាក់។

ទីតាំងអគារលេខ 281អា វិថី ម៉ៅសេទុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 989 881
ទូរសារលេខ : (855) 23 989 885

អ៊ីម៉ែល: kh.maotsetung@rhbgroup.com

## សាខា បឹងកេងកង

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា បឹងកេងកង ត្រូវបានដឹកនាំដោយ លោក ផេង ចន្ទូ រួមជាមួយ បុគ្គល 12នាក់។

ទីតាំងអគារលេខ 167 មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 23 989 188
ទូរសារលេខ : (855) 23 989 788

អ៊ីម៉ែល: kh.boeungkengkang@rhbgroup.com

## សាខា សៀមរាប

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា សៀមរាប ត្រូវបានដឹកនាំដោយ លអ្នកនាង ឃឹម សុធារីរួមជាមួយ បុគ្គល 11នាក់។

ទីតាំងអគារលេខ 12-14-16 ផ្លូវជាតិលេខ 6 ខេត្តសៀមរាប ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 63 969 811
ទូរសារលេខ : (855) 63 969 816

អ៊ីម៉ែល: kh.siemreap@rhbgroup.com

## សាខា ព្រះសីហនុ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា ព្រះសីហនុ ត្រូវបានដឹកនាំដោយ លោក ឈឹម ចាន់ភិរម្យ រួមជាមួយបុគ្គល 10នាក់។

ទីតាំងអគារលេខ 129 ផ្លូវ 7 មករា ខេត្តព្រះសីហនុ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 34 934 811
ទូរសារលេខ : (855) 34 934 816

អ៊ីម៉ែល: kh.sihanoukville@rhbgroup.com

## សាខា បាត់ដំបង

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា បាត់ដំបង ត្រូវបានដឹកនាំដោយ លោក អ៊ាន ច័ន្ទណា រួមជាមួយ បុគ្គល 10នាក់។

ទីតាំងអគារលេខ 1-3-5-7 វិថីលេខ 3 ខេត្តបាត់ដំបង ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 34 934 811
ទូរសារលេខ : (855) 34 934 816

អ៊ីម៉ែល: kh.sihanoukville@rhbgroup.com

## សាខា កំពង់ចាម

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា សាខា កំពង់ចាម ត្រូវបានដឹកនាំដោយ លោក យ៉េន ផៃវ៉ាត រួមជាមួយបុគ្គល 9នាក់។

ទីតាំងអគារលេខ 41 ផ្លូវជាតិលេខ 7 ខេត្តកំពង់ចាម ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ : (855) 42 942 811
ទូរសារលេខ : (855) 42 942 899

អ៊ីម៉ែល: kh.kampongcham@rhbgroup.com

# ផ្នែកសំខាន់ហិរញ្ញវត្ថុ ឆ្នាំ 2016

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

### ចំណូលសរុប

**USD20.9 million**




### ប្រាក់ចំណេញមុនបង់ពន្ធ

**USD8.4 million**



### ទ្រព្យសកម្មសរុប

**USD622.9 million**



### ប្រាក់កម្ចីសរុប

**USD358.1 million**



### ប្រាក់បញ្ញើអតិថិជន

**USD297.3 million**



### ប្រាក់បញ្ញើសរុប

**USD528.6 million**



មូលនិធិម្ចាស់ក្រុមហ៊ុន



**USD84.4 million**

**12 សាខា**



**238 បុគ្គលិក**



**33 ម៉ាស៊ីន អេ ធី អឹម ក្នុងប្រទេសកម្ពុជា**

មានវត្តមាននៅ

**ភ្នំពេញ**
**កំពុងចាម**
**បាត់ដំបង**
**សៀមរាប**
**ព្រះសីហនុ**



ម៉ាស៊ីនដាក់ប្រាក់ និងមូលប្បទានបត្រ
**ដំបូងបង្អស់**
ក្នុងប្រទេសកម្ពុជា

# សង្ខេបហិរញ្ញវត្ថុរយៈពេល 5ឆ្នាំ ផ្នែកសំខាន់ហិរញ្ញវត្ថុ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា


















# សង្ខេបហិរញ្ញវត្ថុរយៈពេល 5ឆ្នាំ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

សាច់ប្រាក់បានពីប្រតិបត្តិការ

| | 2016 | 2015 | 2014 | 2013 | 2012 |
|---|---|---|---|---|---|
| **លទ្ធផលប្រតិបត្តការ (ប្រាក់ដុល្លារ)** | | | | | |
| ប្រាក់ចំណេញមុនបង់ពន្ធ | **8,425,018** | 8,008,106 | 7,018,575 | 8,425,018 | 8,425,018 |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | **6,697,407** | 5,870,823 | 5,454,706 | 861,477 | 1,092,237 |
| **ទិន្នន័យតារាងតុល្យការ (ប្រាក់ដុល្លារ)** | | | | | |
| ទ្រព្យសកម្មសរុប | **622,894,516** | 563,943,753 | 349,086,028 | 242,126,972 | 159,340,990 |
| ឥណទាន និងបុរេប្រទាន | **347,575,673** | 338,622,585 | 213,613,796 | 139,716,334 | 88,953,800 |
| ទ្រព្យអកម្មសរុប | **538,447,847** | 486,194,491 | 292,207,589 | 190,703,239 | 108,778,735 |
| ប្រាក់បញ្ញើអតិថិជន | **297,271,520** | 216,199,505 | 138,791,735 | 84,550,674 | 83,509,351 |
| ប្រាក់បញ្ញើសរុប | **528,639,004** | 478,738,832 | 286,201,796 | 188,319,121 | 106,293,935 |
| ដើមទុន | **67,000,000** | 67,000,000 | 52,000,000 | 52,000,000 | 52,000,000 |
| មូលនិធិម្ចាស់ក្រុមហ៊ុន | **84,446,669** | 77,749,262 | 56,878,439 | 51,423,733 | 50,562,255 |
| **លទ្ធផលប្រតិបត្តិការ (ភាគរយ)** | | | | | |
| ឥណទានមិនដំណើរការធៀបនឹង ឥណទាន និងបុរេប្រទាន | **2.47** | 0.87 | 0.49 | 3.01 | - |
| ការបង្វិលចំណូលលើទ្រព្យសកម្មសុទ្ធ | **1.08** | 1.04 | 1.56 | 0.36 | 0.69 |
| ការបង្វិលចំណូលលើមូលនិធិម្ចាស់ហ៊ុន | **7.93** | 7.55 | 9.59 | 1.68 | 2.16 |
| អនុបាតឥណទានធៀប នឹងប្រាក់អតិថិជន | **116.92** | 156.88 | 155.79 | 169.29 | 107.60 |
| អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើ | **65.75** | 70.85 | 75.55 | 76.01 | 84.53 |

## ផ្តល់ជូននូវដំណោះស្រាយសេវាធនាគារ











យើងប្តេជ្ញាបង្កើតនិងរក្សាទំនាក់ទំនងយូរអង្វែងជាមួយអតិថិជននិងសហគមន៍របស់យើង តាមរយៈការប្រតិបត្តិសេវាធនាគារ ផលិតផលនិងសេវាកម្មប្រកបដោយភាពច្នៃប្រឌិត និងការផ្តល់សេវាកម្មដ៏ល្អឥតខ្ចោះ។

# ផ្តល់ជូននូវដំណោះស្រាយសេវាធនាគារ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

## ប្រាក់បញ្ញើ









### ប្រាក់បញ្ញើសន្សំ

យើងខ្ញុំចាំជួយបង្កើនហិរញ្ញវត្ថុគ្រួសាររបស់លោកអ្នក ជាមួយនិងភាពងាយស្រួលនៃសេវាកម្មធនាគារ 24ម៉ោង។

ប្រាក់បញ្ញើសន្សំអាចជួយលោកអ្នកសំរាប់ទិញផ្ទះ ក្នុងសុបិន្ត ឡាន ការសិក្សាបុត្រធីតារបស់លោកអ្នក ឬសូម្បីតែម៉ាស៊ីនកំព្យូទ័រមួយគ្រឿង។

### គណនីមានកាលកំណត់

មានលក្ខណៈសាមាញ្ញដើម្បីបង្កើនការសន្សំរបស់លោកអ្នក

ប្រាក់បញ្ញើមានលក្ខណៈពិសេសជាច្រើនដើម្បីការវិនិយោគមានប្រសិទ្ធភាព។

### គណនីចរន្ត

ផលិតផលធនាគារនៅចង្អុលដៃរបស់លោកអ្នក

គណនីចរន្តគឺជាមធ្យោបាយគ្រប់គ្រងសាច់ប្រាក់ដ៏មានប្រសិទ្ធភាពដោយជួយសន្សំពេលវេលារបស់លោកអ្នកទៅធនាគារដើម្បីដកប្រាក់សំរាប់បង់វិក័យប័ត្រ និងការចំណាយផ្សេងៗ។

### គណនី ESCROW

ជាដៃគូទុកចិត្តដើម្បីភាពជោគជ័យរបស់លោកអ្នក។

គណនីនេះនឹងជួយការពារផលប្រយោជន៍លោកអ្នកក្នុងប្រតិបត្តិការរបស់លោកអ្នក។

## សេវាផ្ទេរប្រាក់







### សេវាផ្ញើរប្រាក់ TELEGRAPHIC

ភាពងាយស្រួលក្នុងការផ្ញើរ និងទទួលប្រាក់របស់លោកអ្នក

សេវាផ្ញើរប្រាក់ធនាគារយើងខ្ញុំអាចជួយលោកអ្នកសំរាប់ការបន្លាស់ទីនូវប្រាក់របស់លោកអ្នកគ្រប់ទីកន្លែងលើពិភពលោកជាមួយល្បឿនលឿន និងមានប្រសិទ្ធភាព។ រួមជានឹងសេវាផ្ញើរប្រាក់តាមសេវា Western Union។

### មូលប្បទានបត្រធនាគារិក

ជាមធ្យោបាយទូទាត់ដែលអាចជឿទុកចិត្ត

មូលប្បទានប័ត្រធនាគារិកគឺជាមធ្យោបាយនៃការទូទាត់ជំនួយជាសាច់ប្រាក់សំរាប់ការទូទាត់ទំនិញ។

### សេវាប្តូរប្រាក់

យើងនឹងផ្តល់ជូននូវកម្រៃជើងសារដ៏ល្អ ដែលបានផ្តល់ជូនដោយសេវា Froex

សេវាប្តូរប្រាក់ធនាគារយើងខ្ញុំ ផ្តល់ជូននូវកម្រៃជើងសារដ៏ល្អមួយក្នុងទីក្រុងជាមួយការទិញ ឬ លក់រូបិយប័ណ្ណបរទេស។

## កម្ចីផ្ទាល់ខ្លួន







### ប្រាក់កម្ចីទិញគេហដ្ឋាន

<u>យើងខ្ញុំជួយលោកអ្នកធ្វើជា ម្ចាស់កម្មសិទ្ធលើគេហដ្ឋាន ដែលលោកអ្នកសុបិន្តចង់បាន</u>

ជាមួយអត្ថប្រយោជន៍ និងជម្រើសជាច្រើនសំរាប់ឥណទានគេហដ្ឋានក្នុងសុបិន្តរបស់លោកអ្នក។

### ប្រាក់កម្ចីផ្ទាល់ខ្លួន

<u>ទទួលយកនូវអ្វីដែលលោកអ្នកប្រាថ្នាឥលូវនេះ</u>

ប្រាក់កម្ចីផ្ទាល់ខ្លួននិងផ្តល់ប្រាក់សំរាប់លោកអ្នកប្រើប្រាស់នូវអ្វីដែលលោកអ្នកប្រាថ្នាក្នុងជីវិត។ នឹងទទួលបាននូវជម្រើសជាច្រើនពីប្រាក់កម្ចីនេះ ដូចជាដើម្បីទិញកុំព្យូទ័រ ជួសជុលផ្ទះ និងការបង្កើនមុខរបរ។

### ប្រាក់កម្ចីទិញរថយន្ត

<u>បើករថយន្តក្នុងសុបិន្តរបស់លោកអ្នកថ្ងៃនេះ</u>

ជាមួយនឹងជម្រើសជាច្រើនពីប្រាក់កម្ចីនេះ លោកអ្នកអាចបើករថយន្តដែលលោកអ្នកប្រាថ្នាចង់បាន។

## កម្ចីអាជីវកម្ម និងក្រុមហ៊ុន









### កម្ចីអចលនទ្រព្យ

<u>យើងខ្ញុំចាំជួយលោកអ្នកសម្រាប់ការវិនិយោគលើអចនទ្រព្យ។</u>

ប្រាក់កម្ចីយើងខ្ញុំនឹងជួយលោកអ្នកសម្រាប់ការវិនិយោគលើអចនទ្រព្យ ឬគោលបំណងវិនិយោគផ្សេងៗ។

### សេវាហិរញ្ញប្បទានពាណិជ្ជកម្ម

<u>យើងខ្ញុំផ្តល់ជូនលោកអ្នកនូវសេវាហិរញ្ញប្បទានលើផ្នែកនាំចេញ និងនាំចូល</u>

ហិរញ្ញប្បទានពាណិជ្ជកម្មរបស់យើងខ្ញុំ នឹងជួយលោកអ្នក អស់ក្តីបារម្ភអំពីការខកខានបញ្ជូនទំនិញក្នុងអាជីវកម្មនៃការនាំចេញនាំចូលរបស់លោកអ្នក។

### ក្រុមហ៊ុន និងភាគហ៊ុន

<u>តម្រូវការអាជីវកម្មរបស់អ្នកគឺជាអាទិភាពរបស់យើង</u>

ពីការចុះបញ្ជីក្រុមហ៊ុនរបស់អ្នកទៅជាការរួមបញ្ចូលគ្នាអាជីវកម្មនិងការទិញយកអ្នកអាចទុកចិត្តបានថាអ្នកអាចពឹងពាក់លើយើង។

### ប្រាក់កម្ចីដើមទុន

<u>សូមអនុញ្ញាតពួកយើងជួយលើលំហូរសាច់ប្រាក់កាន់តែល្អរបស់លោកអ្នក</u>

ជាមួយប្រាក់កម្ចីទុនបង្វិលយើងខ្ញុំ នឹងជួយក្នុងការប្រកបមុខរបរលោកអ្នកអោយកាន់តែល្អជាមុន។

# ផ្តល់ជូននូវដំណោះស្រាយសេវាធនាគារ (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា




## ម៉ាស៊ីន អេ ធី អឹម តាមបណ្តាសាខាធនាគារ

### ទីក្រុងភ្នំពេញ

1. ទីស្នាក់ការកណ្តាល (ម៉ាស៊ីនចំនួន 3គ្រឿង)
2. សាខា ស៊ីធីម៉លអូឡាំពិក (ម៉ាស៊ីនចំនួន 2គ្រឿង)
3. សាខា ស្ទឹងមានជ័យ
4. សាខា ក្បាលថ្នល់
5. សាខា ពេទ្យលោកសង្ឃ
6. សាខា ទួលគោក
7. សាខា មៅសេទុង (ម៉ាស៊ីនចំនួន 3គ្រឿង)
8. សាខា បឹងកេងកង (ម៉ាស៊ីនចំនួន 2គ្រឿង)

### តាមបណ្តាខេត្ត

9. សាខា កំពង់ចាម
10. សាខា បាត់ដំបង
11. សាខា សៀមរាប
12. សាខា ព្រះសីហនុ




## ម៉ាស៊ីន អេ ធី អឹម តាមបណ្តារទីសាធារណៈ

### ទីក្រុងភ្នំពេញ

1. ផ្សារទំនើបអ៊ីអន
2. ធីខេ អាវេនញ៉ូ (ទួលគោក)
3. ដេលី កាហ្វេ (មហាវិថី ព្រះសីហនុ)
4. ហ្វៃ ម៉ាឃីត (ផ្លូវលេខ 63 កែងនឹងមហាវិថីម៉ោសេទុង)
5. អេច ម៉ាឃីត (ស្ទឹងមានជ័យ)
6. ភោជនីយដ្ឋាន ពោចិនតុង (មហាវិថី សហព័ន្ធរុស្សី)
7. ក្រុមហ៊ុនសូឡា ឡុង ថាន (ផ្លូវ 271)
8. តេលា ម៉ាត (ស្ពានច្រូយចង្វារ)
9. តេលា ម៉ាត (ផ្លូវ 1986)
10. ហាងលក់នំ អេប៊ីស៊ី (មហាវិថី កម្ពុជាក្រោម)
11. សណ្ឋាគារ ហ៊ីម៉ាវ៉ារី (ផ្លូវ )
12. ឱសថស្ថាន ហេ៊ាប ផ្លើស (មហាវិថី កម្ពុជាក្រោម)
13. សកលវិទ្យាល័យ IIC (ផ្លូវជាតិលេខ2)

### តាមបណ្តារខេត្ត

14. ហ៊ុយ ម៉េង មីនីម៉ាត (មហាវិថី ស៊ីវុត្ថា)
15. ឡាក់គីម៉ល (មហាវិថី ស៊ីវុត្ថា)

# រចនាសម្ព័ន្ធគ្រប់គ្រង

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា




ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការ លាភការ និង ការតែងតាំង
គណៈកម្មាធិការ គ្រប់គ្រង
ប្រធានក្រុមមន្ត្រី យុទ្ធសាស្ត្រ
អគ្គនាយក
អគ្គនាយករង
នាយកផ្នែកគ្រប់គ្រង ឥណទាន
នាយកផ្នែកអភិវឌ្ឍផលិតផល និង ទំនាក់ទំនងទីផ្សារ
នាយកផ្នែកសារអាជីវកម្ម
សាខា
វាយតម្លៃឥណទាន
រដ្ឋបាលឥណទាន
គ្រប់គ្រង និង ត្រួតពិនិត្យឥណទាន
អភិវឌ្ឍផលិតផល
ទំនាក់ទំនងទីផ្សារ
ប្រព័ន្ធធនាគារអេឡិចត្រូនិច
ឥណទានទូរស័ព្ទចល័ត
ក្រុមហ៊ុន និង អាជីវកម្ម
លក់រាយ និងបញ្ញើ
ជំនួយការផ្នែកលក់
ទីស្នាក់ការកណ្តាល
ស៊ីធីម៉លអូឡាំពិក
ស្ទឹងមានជ័យ
ក្បាលថ្នល់
ពេទ្យលោកសង្ឃ
ទួលគោក
កំពង់ចាម
បាត់ដំបង
សៀមរាប
ព្រះសីហនុ
ម៉ៅសេទុង
បឹងកេងកង

# របាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាល

**ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា បានសេចក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុលើកទី9 របស់ធនាគារ។**

ក្នុងឆ្នាំ 2016 នេះ ធនាគារបានបន្តរីកចម្រើនប្រកបដោយចិរភាព និង ទទួលបានប្រាក់ចំណេញខ្ពស់ ទោះបីជាមានការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក ដែលបានបណ្តាលឲ្យប៉ះពាល់ ដល់តម្លៃទំនិញភាពមិនប្រាកដប្រជាជុំវិញការបោះឆ្នោតជ្រើសរើសប្រធានាធិបតីរបស់សហរដ្ឋអាមេរិក ការបោះឆ្នោតចាកចេញពីសហភាពអឺរ៉ុបរបស់ចក្រភពអង់គ្លេស (BREXIT) និង ការធ្លាក់ចុះនៃការធ្វើពាណិជ្ជកម្មក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ និង ប្រទេសចិន។ ក្នុងឆ្នាំ 2016 ធនាគារជាតិនៃកម្ពុជា បានផ្តួចផ្តើមបង្កើតបទប្បញ្ញត្តិថ្មីៗ រួមមានបទប្បញ្ញត្តិស្តីពីអនុបាតក្របខណ្ឌសន្ទនីយភាព និងបទប្បញ្ញត្តិស្តីពីការបង្កើនដើមទុនអប្បបរមាខ្ពស់ជាងមុន ដើម្បីធានាថាវិស័យធនាគាររបស់កម្ពុជា អាចទប់ទល់នឹងភាពរាំងស្ទះសេដ្ឋកិច្ច ពិភពលោក និងស្របទៅតាមលក្ខខណ្ឌបទដ្ឋានអន្តរជាតិ។



**លោក Ong Seng Pheow**
ប្រធានក្រុមប្រឹក្សាភិបាល

## របាយការណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មរបស់ធនាគារ មានការកើនឡើងចំនួន 10% ឬ 59 លានដុល្លារអាមេរិក ពី 564 លានដុល្លារអាមេរិកក្នុងឆ្នាំ 2015ទៅ 623 លានដុល្លារអាមេរិកក្នុងឆ្នាំ2016ដែលបានធ្វើឲ្យចំណាត់ថ្នាក់ផ្នែកទ្រព្យសកម្មរបស់ធនាគារមានភាពប្រសើរឡើង ពីចំណាត់ថ្នាក់ទី12 ក្នុងឆ្នាំ 2015 មកចំណាត់ថ្នាក់ទី11 ក្នុងឆ្នាំ 2016 ក្នុងចំណោមធនាគារនានានៅកម្ពុជា។ ទោះបីជាស្ថិតក្នុងបរិយាកាសប្រកួតប្រជែងខ្លាំងក៏ដោយ ធនាគារកំពុងតែធ្វើដំណើរទៅមុខយ៉ាងល្អក្នុងការឈានទៅសម្រេចសេចក្តីប៉ងប្រាថ្នាដើម្បីក្លាយជាធនាគារនាំមុខមួយលើទ្រព្យសកម្ម ក្នុងចំណោមធនាគារនាំមុខទាំង10។

ប្រាក់បញ្ញើរបស់អតិថិជនរបស់ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា មានការកើនឡើងយ៉ាងខ្លាំងចំនួន 37% ដែលស្មើនឹង 1.8 ដងនៃការកើនឡើងប្រាក់បញ្ញើរបស់ឧស្សាហកម្មក្នុងអត្រា 21%។ កត្តានេះបានរួមចំណែក ធ្វើឲ្យកើនឡើងចំណែកទីផ្សារប្រាក់បញ្ញើរបស់អតិថិជនរបស់ធនាគារ និងបង្ហាញពីទំនុកចិត្តរបស់ អតិថិជនចំពោះធនាគារ ហើយក៏ជាការទទួលស្គាល់ពីលទ្ធភាពរបស់ធនាគារក្នុងការឆ្លើយតបនឹងតម្រូវការរបស់អតិថិជនផងដែរ។

ប្រាក់ចំណេញមុនដកពន្ធរបស់ធនាគារ បានកើនឡើងដល់ 8.4 លានដុល្លារអាមេរិកក្នុងឆ្នាំ 2016 ដែលកើនឡើងចំនួន 0.8 លានដុល្លាអាមេរិកបើធៀបនឹងឆ្នាំមុន។ ប្រាក់ចំណេញមុនដកពន្ធ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ មានអត្រាកំណើនប្រចាំឆ្នាំសរុបចំនួន 115% ខណៈដែលប្រាក់បញ្ញើរបស់អតិថិជនមានអត្រាកំណើនប្រចាំឆ្នាំសរុបចំនួន 51% ឥណទានមានអត្រាកំណើនប្រចាំឆ្នាំសរុបចំនួន 46% និងទ្រព្យសកម្មមានអត្រាកំណើនប្រចាំឆ្នាំសរុបចំនួន 43%។

**ប្រាក់ចំណេញក្រោយបង់ពន្ធ**

**6.7**

**លានដុល្លារអាមេរិក**

**មូលនិធិម្ចាស់ក្រុមហ៊ុន**

**84.4**

**លានដុល្លារអាមេរិក**

**ទ្រព្យសកម្មសរុប**

**622.9**

**លានដុល្លារអាមេរិក**

## អភិបាលកិច្ចសាជីវកម្ម

ទាក់ទងនឹងអភិបាលកិច្ច អនុលោមភាព និង ការគ្រប់គ្រងហានិភ័យដោយយកចិត្តទុកដាក់ ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា ប្តេជ្ញាប្រកាន់ខ្ជាប់នូវបទដ្ឋានខ្ពស់បំផុត។ សម្ព័ន្ធធនាគារ អ អេច ប៊ី បន្តរក្សា និង លើកកម្ពស់ការអនុវត្តអភិបាលកិច្ចដែលល្អប្រសើរនៅក្នុងសម្ព័ន្ធ ដែលបានបង្កើតឡើង និងពង្រីកនៅក្នុងប្រវត្តិសាស្ត្ររបស់ សម្ព័ន្ធជាង 100ឆ្នាំ មកហើយ។

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា មានអនុបាតក្របខណ្ឌសន្ទនីយភាពចំនួន 90.1% គិតត្រឹមបំណាច់ឆ្នាំ 2016 ដែលខ្ពស់ជាង 1.5 ដង នៃលក្ខខណ្ឌតម្រូវ 60% ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌមួយទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា គឺការបង្កើនដើមទុនអប្បបរមាថ្មីចំនួន 75 លានដុល្លារអាមេរិកឲ្យបានមុនខែមីនា ឆ្នាំ2018។ ធនាគារបានអនុលោមតាមលក្ខខណ្ឌតម្រូវនេះ បន្ទាប់ពីបង្កើនដើមទុនចុះបញ្ជីដល់ 71 លានដុល្លារអាមេរិក នៅខែមីនា ឆ្នាំ2017 ហើយធនាគារមានទំនុកចិត្តថា នឹងបំពេញលក្ខខណ្ឌបង្កើនដើមទុនអប្បរមាទាំងស្រុងកំណត់ដោយ ធនាគារជាតិនៃកម្ពុជានៅក្នុងខែមីនា ឆ្នាំ2018 ខាងមុខនេះ។ ធនាគារបានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងអស់របស់កម្ពុជា ដែលរួមទាំងបទប្បញ្ញត្តិថ្មី និងដែលបានធ្វើវិសោធនកម្មមួយចំនួនក្នុងឆ្នាំ2016 នេះ ដោយធនាគារជាតិនៃកម្ពុជា និងបន្តអនុលោមតាមយ៉ាងយកចិត្តទុកដាក់តទៅទៀត។

ទាក់ទិននឹងអនុលោមភាពនេះ គណៈកម្មការគ្រប់គ្រងហានិភ័យ និងគណៈកម្មការសវនកម្មរបស់ធនាគារបានជួបប្រជុំបួនដងក្នុងមួយឆ្នាំ ដើម្បីពិនិត្យ និងមើលការខុសត្រូវលើបញ្ហាទាក់ទងនឹងហានិភ័យ និងអនុលោមភាព ក៏ដូចជាការត្រួតពិនិត្យផ្ទៃក្នុងផងដែរ។ សេចក្តីលម្អិតបន្ថែមទៀតត្រូវបានផ្តល់នៅក្នុងរបាយការណ៍ ត្រួតពិនិត្យផ្ទៃក្នុង ដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំ2016។

## ការជួយដល់សង្គម

ក្នុងរយៈពេលបីឆ្នាំបន្តបន្ទាប់គ្នានេះ ធនាគារបានរៀបចំកម្មវិធីប្រកួតបាល់ទាត់កុមារ អ អេច ប៊ី ដែលអនុញ្ញាតឲ្យកុមារក្រីក្រ និងទន់ខ្សោយនៅក្នុងរាជធានីភ្នំពេញអាចបណ្តុះចំណង់ចំណូលចិត្តក្នុងវិស័យកីឡា និងដុសខាត់ទេពកោសល្យផ្នែកបាល់ទាត់របស់ពួកគេ។ធនាគារមានមោទនភាពណាស់ដែលទទួលបានការគាំទ្រ និងចូលរួមកាន់តែច្រើនឡើងៗ ជារៀងរាល់ឆ្នាំ និង មានគម្រោងពង្រីកកម្មវិធីនេះទៅថ្នាក់ជាតិក្នុងឆ្នាំ2017។ ក្រៅពីកីឡាបាល់ទាត់ ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា ក៏បានឧបត្ថម្ភដល់ក្រុមជិះកង់ជម្រើសជាតិកម្ពុជាដើម្បីចូលរួមព្រឹត្តិការណ៍ជិះកង់ថ្នាក់ជាតិ និងអន្តរជាតិនានា និងបានឧបត្ថម្ភព្រឹត្តិការណ៍ជិះកង់ឡើងភ្នំកម្ពុជាជាច្រើនក្នុងឆ្នាំ 2016 ដែលជាសកម្មភាពដើម្បីសុខភាពមួយទៀតដែលធនាគារកំពុងចូលរួមលើកកម្ពស់យ៉ាងសកម្មនៅកម្ពុជា។

តាមរយៈ Aide-et-Action ដែលជាអង្គការដែលលើកកម្ពស់ការទទួលបានការអប់រំប្រកបដោយគុណភាព ធនាគារបានកសាងសាលាបឋមសិក្សាមួយនៅឃុំស្អាងភ្នំ ខេត្តកណ្តាល ក្រោមកម្មវិធី "The Early Childhood Development School Program" ដែលអាចផ្ទុកសិស្សបាន 30នាក់ និង បានផ្គត់ផ្គង់សម្ភារសម្រាប់លើកកម្ពស់ការទទួលបានការអប់រំសម្រាប់សិស្ស។ បន្ថែមពីលើនេះទៀត ធនាគារក៏បានធ្វើការបរិច្ចាគជាសាច់ប្រាក់ទៅកាន់អង្គការមនុស្សធម៌ដែលធំជាងគេនៅកម្ពុជាផងដែរ គឺកាកបាទក្រហមកម្ពុជា។

ខណៈ ដែលអាជីវកម្មរបស់ធនាគារ បន្តរីកចម្រើន ធនាគារនៅតែបន្តយកចិត្តទុកដាក់លើសកម្មភាពជួយដល់សង្គម និង បន្តបង្កើត និងគាំទ្រ សកម្មភាពដែលនាំមកនូវប្រយោជន៍ជូនសង្គមកម្ពុជា។

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូចៃណា

## ការលើកកម្ពស់គុណតម្លៃម្ចាស់ភាគហ៊ុន

ក្រុមប្រឹក្សាភិបាលថ្មីរបស់ធនាគារ អ អេច ប៊ី ឥណ្ឌូចៃណា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក Tuan Haji Khairuddin លោក Foo San Kan និងលោក Leong Yeng Kit ដែលបានចូលរួមចំណែកដោយមិនខ្លាចនឿយហត់ ក្នុងការអភិវឌ្ឍធនាគារក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ។ ខណៈដែលពួកគាត់បានចូលនិវត្តន៍ពីតួនាទីនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារក្នុង ឆ្នាំ2016 និង ចាប់ផ្តើមអាជីពថ្មី សមាជិកក្រុមប្រឹក្សាភិបាលថ្មី ប្តេជ្ញាកសាងលើកេរ្តិ៍តំណែលដែលបន្សល់ទុកដោយក្រុមប្រឹក្សាភិបាលចាស់ និង អភិវឌ្ឍធនាគារឲ្យទទួលបានជោគជ័យមួយកម្រិតទៀត។

តាមរយៈ RHB Bank Berhad ធនាគារ អ អេច ប៊ី ឥណ្ឌូចៃណា បានបំពេញលក្ខខណ្ឌបង្កើនដើមទុនអប្បបរមា ខែមីនា ឆ្នាំ2017 របស់ខ្លួន និង រំពឹងបំពេញលក្ខខណ្ឌបង្កើនដើមទុនអប្បបរមាទាំងស្រុង ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ក្នុងខែ មីនា ឆ្នាំ 2018 ខាងមុខនេះ។ ធនាគារបានរៀបចំផែនការរួចជាស្រេច សម្រាប់ប្រើប្រាស់ដើមទុនដែលមាន ដើម្បីបង្កើនប្រាក់ចំណេញបន្ថែមទៀត។

## ដំណើរឆ្ពោះទៅមុខ

ធនាគារ នឹងបន្តស្វែងរកឱកាសពង្រីកប្រតិបត្តិការ និង រីកចម្រើននៅក្នុងប្រទេសកម្ពុជា ទោះបីជាមានការកើនឡើង និងបរិយាកាសប្រកួតប្រជែងខ្លាំងក៏ដោយ។ ធនាគារយើងខ្ញុំសង្ឃឹមចង់ឃើញមានដៃគូប្រកួតប្រជែងថ្មីចូលរួមក្នុងវិស័យធនាគារកម្ពុជា ជាពិសេសធនាគារនាំមុខក្នុងតំបន់អាស៊ាន ដែលមានផែនការពង្រីកប្រតិបត្តិការក្នុងតំបន់។ធនាគារក៏បានរំពឹងទុកពីការកើនឡើងនៃការចំណាយ នានាទាក់ទងនឹងអនុលោមភាព ព្រោះថាច្បាប់ និងបទប្បញ្ញត្តិថ្មីគ្រប់គ្រងវិស័យធនាគារ ត្រូវបានរំពឹងថានឹងបង្កើតឡើង ក្នុងឆ្នាំ 2017 ហើយយើងខ្ញុំស្វាគមន៍រាល់កិច្ចខិតខំប្រឹងប្រែងរបស់និយ័តករដែលលើកកម្ពស់សុខភាពហិរញ្ញវត្ថុ និង ចិរភាពនៃវិស័យនេះ។ ធនាគារបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រឈមនឹងបញ្ហាថ្មីៗទាំងនេះ និង បំលែងទៅជាឱកាសសម្រាប់ការរីកចម្រើន។

## សេចក្តីថ្លែងអំណរគុណ

តាងនាមក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណ ជាពិសេសចំពោះធនាគារជាតិនៃកម្ពុជា អតិថិជនទាំងអស់ និង បុគ្គលិករបស់ធនាគារគ្រប់ជាន់ថ្នាក់ ដែលបានចូលរួមចំណែក ធ្វើឲ្យធនាគារសម្រេចសេចក្តីប៉ងប្រាថ្នារបស់ខ្លួន ក្នុង ឆ្នាំ2016។ យើងខ្ញុំ នឹងបន្តឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នក ដូចដែលចែងនៅក្នុងពាក្យស្លោករបស់ធនាគារគឺ "Together We Progress"។




**Ong Seng Pheow**

ប្រធានក្រុមប្រឹក្សាភិបាល





# ក្រុមប្រឹក្សាភិបាល




ពីខាងឆ្វេងដៃ:

1) Chulapong Yukate 2) Encik Abdul Aziz Peru Mohamed 3) YBhg. Dato' Khairussaleh Ramli 4) Ong Seng Pheow 5) Christopher Loh Meng Heng 6) Lim Loong Seng

# សមាសភាពក្រុមប្រឹក្សាភិបាល

ធនាគារ អ អេច ប៊ី ឥណ្ឌូចិណា



## លោក Ong Seng Pheow

ប្រធានក្រុមប្រឹក្សាភិបាលឯករាជ្យ និងមិនប្រតិបត្តិ
អាយុ 68ឆ្នាំ ជនជាតិម៉ាឡេស៊ី

**សមាជិកភាព គណៈកម្មការក្រុមប្រឹក្សាភិបាល**
- គណៈកម្មការសវនកម្ម (សមាជិក)
- គណៈកម្មការគ្រប់គ្រងហានិភ័យ (សមាជិក)
- គណៈកម្មការផ្តល់តម្លៃការ និងជ្រើសតាំង (សមាជិក)

**ធនាគារ** RHB Banking Group
**សមាជិកភាព គណៈកម្មការក្រុមប្រឹក្សាភិបាល**
- ប្រធានក្រុមប្រឹក្សាភិបាលនៃ RHB Insurance Berhad (ប្រធាន)
- គណៈកម្មការឥណទាន (សមាជិក)
- គណៈកម្មការផ្តល់តម្លៃការ និងជ្រើសតាំង (សមាជិក)
- គណៈកម្មការបច្ចេកវិជ្ជា (សមាជិក)
- សមាជិកវិនិយោគនៃក្រុមហ៊ុន RHB Insurance Berhad (សមាជិក)

**គុណវុឌ្ឍិ**
- សមាជិកវិទ្យាស្ថាន Malaysian Institute of Certified Public Accountants
- សមាជិកវិទ្យាស្ថាន Malaysian Institute of Accountants

**ជំនាញ និងបទពិសោធន៍**
លោក Ong Seng Pheow មានបទពិសោធន៍ច្រើនជាង 34ឆ្នាំ នៅក្នុងវិស័យគណនេយ្យ និង សវនកម្ម។ លោកធ្លាប់ជាដៃគូរបស់ក្រុមហ៊ុន Ernst & Young ចាប់ពីឆ្នាំ 1984 ដល់ឆ្នាំ 2003។ តួនាទីចុងក្រោយរបស់លោកនៅក្រុមហ៊ុន Ernst & Young គឺជានាយកប្រចាំប្រទេសផ្នែកសេវាធានាគុណភាព និងប្រឹក្សាយោបល់។ លោកក៏មានតួនាទីនៅក្នុងគណៈកម្មាធិការ និង ក្រុមការងាររបស់ MICPA ផងដែរ។



## លោក Abdul Aziz Peru Mohamed

អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
អាយុ 68ឆ្នាំ ជនជាតិម៉ាឡេស៊ី

**សមាជិកភាព គណៈកម្មការក្រុមប្រឹក្សាភិបាល**
- គណៈកម្មការគ្រប់គ្រងហានិភ័យ (ប្រធាន)
- គណៈកម្មការសវនកម្ម (សមាជិក)
- គណៈកម្មការផ្តល់តម្លៃការ និងជ្រើសតាំង (សមាជិក)

**ធនាគារ** RHB Banking Group
**សមាជិកភាព គណៈកម្មការក្រុមប្រឹក្សាភិបាល**
- គណៈកម្មការឥណទាន (សមាជិក)

**គុណវុឌ្ឍិ**
- សាកលវិទ្យាល័យ Harvard University, Harvard Business School
- កម្មវិធី Pacific Bankers Rim នៅសហរដ្ឋអាមេរិក

**ជំនាញ និងបទពិសោធន៍**
បច្ចុប្បន្ន លោក Encik Aziz Peru ជាប្រធាននាយកប្រតិបត្តិ/អភិបាល នៃ As-Salihin Trustee Berhad ជាក្រុមហ៊ុនបរធនបាលកិច្ច ដែលមានឯកទេសខាងរៀបចំចាត់ចែងមរតកសាសនិកអ៊ីស្លាម។ លោកធ្លាប់កាន់មុខតំណែង ជាច្រើននៅក្នុងគណៈគ្រប់គ្រងជាន់ខ្ពស់ក្នុងវិស័យធនាគារ ជាមួយនឹងជោគជ័យក្នុងអាជីពរយៈពេល 30ឆ្នាំប្រ់គ្រងបណ្តាញសាខា និង គ្រប់គ្រងសេវាធនាគារអតិថិជនជារូបវន្តបុគ្គល។ លោក បានចំណាយពេលជាច្រើនឆ្នាំ ធ្វើការឲ្យធនាគារ Malayan Banking Berhad ដែលតួនាទីចុងក្រោយរបស់លោកជាមួយធនាគារនេះគឺ នាយកគ្រប់គ្រងទូទៅសេវាធនាគារអតិថិជន។ លោកក៏ធ្លាប់បម្រើការងារជា នាយកគ្រប់គ្រងទូទៅជាន់ខ្ពស់ នៅធនាគារ AmBank Berhad ពីឆ្នាំ 2002 ដល់ ឆ្នាំ 2005។ ក្នុងអំឡុងពេលធ្វើការនៅក្នុង វិស័យធនាគារ លោក ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការច្បាប់នៃសមាគមធនាគារនៅម៉ាឡេស៊ី និង កាន់មុខតំណែងសំខាន់ៗមួយចំនួនទៀតរួមមាន សមាជិកក្រុមប្រឹក្សាភិបាល របស់ Mayban Property Trust និង Mayban Trustees Bhd។



## លោក Chulapong Yukate

អភិបាលឯករាជ្យ និងមិនប្រតិបត្តិ
អាយុ 60ឆ្នាំ ជនជាតិថៃ

**សមាជិកភាព គណៈកម្មការក្រុមប្រឹក្សាភិបាល**

- គណៈកម្មការសវនកម្ម (ប្រធាន)
- គណៈកម្មការផ្តល់តម្លៃការ និងជ្រើសតាំង (ប្រធាន)
- គណៈកម្មការគ្រប់គ្រងហានិភ័យ (សមាជិក)

**គុណវុឌ្ឍិ**

- អនុបណ្ឌិតនីតិសាស្ត្រពីសាកលវិទ្យាល័យ Washington University សហរដ្ឋអាមេរិក (ក្រោមអាហារូបករណ៍ Deacons)
- វិញ្ញាបនបត្របញ្ចប់ការសិក្សាផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិពីសាកលវិទ្យាល័យ Tokyo University ប្រទេសជប៉ុន (ក្រោមអាហារូបករណ៍របស់ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មអន្តរជាតិជប៉ុន)
- បរិញ្ញាបត្រនីតិសាស្ត្រពីសាកលវិទ្យាល័យ Chulalongkorn University ប្រទេសថៃ
- ក្រុមប្រឹក្សាមេធាវីរបស់ប្រទេសថៃ
- ក្រុមប្រឹក្សាច្បាប់របស់រដ្ឋ Victoria ប្រទេសអូស្ត្រាលី

**ជំនាញ និងបទពិសោធន៍**

លោក Chulapong Yukate បាននាំមកនូវចំណេះដឹងយ៉ាងទូលំទូលាយដល់ក្រុមហ៊ុន ZICO Law Limited ដោយលោកមានបទពិសោធន៍ប្រហែល 30ឆ្នាំ ក្នុងវិស័យសំខាន់ៗដូចជា ការទិញលក់ភាគហ៊ុន & ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា គម្រោងនានា សេវាធានារ៉ាប់រង និងមជ្ឈត្តការអន្តរជាតិ។ លោកគឺជាដៃគូ និងទីប្រឹក្សានៅក្នុងក្រុមហ៊ុនមេធាវីអន្តរជាតិនាំមុខ Deacons ក្នុងប្រទេសថៃ និង អូស្ត្រាលី Colin Ng & Partners ក្នុងប្រទេសសិង្ហបុរី និង Baker & McKenzie ក្នុងប្រទេសថៃ។ លោកបានចូលរួមជាមួយក្រុមហ៊ុន Dhipaya Insurance Public Company Limited ក្នុងទីក្រុងបាងកកជា Group General Counsel រហូតដល់ខែកក្កដា ឆ្នាំ 2013។

លោកក៏ជាស្ថាបនិក និងនាយកគ្រប់គ្រង របស់ក្រុមហ៊ុនមេធាវី DLA Piper មានការិយាល័យនៅទីក្រុងបាងកក ដែលចាប់ផ្តើមជាមួយមេធាវី 2រូប ក្នុងឆ្នាំ 2003 ហើយបីឆ្នាំក្រោយមក ក្រុមហ៊ុនមេធាវីនេះទទួលបានជោគជ័យដោយពង្រីកការិយាល័យ និងមានមេធាវីចំនួន 25 នាក់។



## លោក Dato’ Khairussaleh Ramli

អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
អាយុ 49ឆ្នាំ ជនជាតិម៉ាឡេស៊ី

**គុណវុឌ្ឍិ**

- បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Washington University, St. Louis
- កម្មវិធីគ្រប់គ្រងជាន់ខ្ពស់ពីសាកលវិទ្យាល័យ Harvard University, Harvard Business School
- Fellow Chartered Banker, Asian Institute of Chartered Bankers

**ជំនាញ និងបទពិសោធន៍**

លោក Dato′ Khairussaleh មានបទពិសោធន៍ច្រើនជាង 20ឆ្នាំ នៅក្នុងវិស័យទីផ្សារហិរញ្ញវត្ថុ និង សេវាហិរញ្ញវត្ថុ ដែលលោកបានកាន់តំណែងជាន់ខ្ពស់ជាច្រើន នៅក្នុងស្ថាប័នហិរញ្ញវត្ថុដែលល្បីឈ្មោះនៅក្នុងតំបន់ជាច្រើន។ លោក ក៏ជាសមាជិកក្រុមប្រឹក្សានៃសមាគមធនាគារនៅម៉ាឡេស៊ី និង Asian Institute of Chartered Bankers។

ចំណេះដឹងដ៏ជ្រៅជ្រះ និង បទពិសោធន៍យ៉ាងទូលំទូលាយ បានធ្វើឲ្យលោកទទួលបានពានរង្វាន់ Best CFO in Malaysia Award ក្នុងឆ្នាំ 2010 និង 2011 ពី Finance Asia និង Best CFO in Malaysia Award ក្នុងឆ្នាំ 2012 ពី Alpha Southeast Asia។

# សមាសភាពក្រុមប្រឹក្សាភិបាល (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា



## លោក Christopher Loh Meng Heng

អភិបាលមិនឯករាជ្យ និងមិនប្រតិបត្តិ
អាយុ 40 ឆ្នាំ ជនជាតិម៉ាឡេស៊ី

**គុណវុឌ្ឍិ**

- បរិញ្ញាបត្រ Engineering, Business Minor, Nanyang Technological Unviersity, Singapore
- RHB-INSEAD Senior Leadership Programme

**ជំនាញ និងបទពិសោធន៍**

លោក Christopher Loh មានបទពិសោធន៍ប្រឹក្សាយោបល់ច្រើនជាង 16ឆ្នាំ ទាក់ទងសេវាហិរញ្ញវត្ថុ និង ការគ្រប់គ្រងហានិភ័យ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច សហរដ្ឋអាមេរិក និង ប្រទេសអង់គ្លេស ដែលលោកបានបម្រើការងារនៅក្រុមហ៊ុនថ្នាក់សកល និងថ្នាក់តំបន់ ដើម្បីអភិវឌ្ឍអាជីវកម្មរបស់ក្រុមហ៊ុនទាំងនោះ និង រៀបចំយុទ្ធសាស្រ្តគ្រប់គ្រងហានិភ័យ។

បទពិសោធន៍របស់លោករួមមាន យុទ្ធសាស្រ្តអាជីវកម្ម និង ការផ្លាស់ប្តូរ ការគ្រប់គ្រងហានិភ័យ ការរៀបចំទម្រង់ប្រតិបត្តិការ ប្រសិទ្ធផលនៃប្រតិបត្តិការ ការអនុលោមតាមបទប្បញ្ញត្តិ និង ហានិភ័យ និង ការគ្រប់គ្រងដើមទុន។ លោកគឺជាដៃគូ និងអគ្គនាយកនៃក្រុមហ៊ុនពិគ្រោះយោបល់សកលមួយ ជាកន្លែងដែលលោកបានបង្កើត និងដឹកនាំអនុវត្តការគ្រប់គ្រងហានិភ័យដ៏ជោគជ័យ។



## លោក Lim Loong Seng

អគ្គនាយក
អាយុ 62ឆ្នាំ ជនជាតិម៉ាឡេស៊ី

**គុណវុឌ្ឍិ**

- អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពីសាកលវិទ្យាល័យ University of Sunderland (ចក្រភពអង់គ្លេស)
- បរិញ្ញាបត្រ Science in Agribusiness & Diploma in Agriculture ពីសាកលវិទ្យាល័យ Putra Malaysia University

**ជំនាញ និងបទពិសោធន៍**

លោក Lim Loong Seng មានបទពិសោធន៍ច្រើនជាង 38ឆ្នាំ ដែល 34ឆ្នាំ នៅក្នុងឧស្សាហកម្ម សេវាហិរញ្ញវត្ថុ និងប្រហែល 9ឆ្នាំ ក្នុងប្រទេសកម្ពុជា។ លោកបានចាប់ផ្តើមអាជីពក្នុងវិស័យធនាគារជាមួយ សម្ព័ន្ធសេវាហិរញ្ញវត្ថុនាំមុខមួយរបស់ម៉ាឡេស៊ី។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយទាក់ទងនឹង សេវាធនាគារសាជីវកម្ម សេវាធនាគាររូបវន្តបុគ្គល និងសេវាធនាគារក្រុមហ៊ុន ដោយកាន់តំណែងជាន់ខ្ពស់គ្រប់គ្រងផ្នែកប្រតិបត្តិការ ឥណទាន ហានិភ័យ និង ផ្នែកលក់ & ទីផ្សារ។

លោកទទួលបានមេដាយមាស SEARCA និង Harvard Business Alumni Club Malaysia Gold Medal នៅពេលដែលលោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក Agribusiness ក្នុងឆ្នាំ1986។

លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន RHB Indochina Securities Co., Ltd. និង ធនាគារ RHB Bank (Laos) Ltd.។ លោកក៏ទទួលមើលការខុសត្រូវលើ ការិយាល័យតំណាងរបស់ធនាគារ RHB នៅប្រទេសវៀតណាម និង ប្រទេសមីយ៉ាន់ម៉ាផងដែរ។

លោកទទួលបានអាជ្ញាប័ណ្ណជាពាណិជ្ជករមូលបត្រ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា។ លោកត្រូវបានជ្រើសតាំងជាអនុប្រធានសមាគមពាណិជ្ជកម្មម៉ាឡេស៊ី នៅកម្ពុជាចាប់តាំងពីឆ្នាំ 2010 មក។

# ប្រធានក្រុមប្រឹក្សាភិបាល និង
# គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

## គណៈកម្មាធិការគ្រប់គ្រង

| | | |
|---|---|---|
| 1. | Mr. Ong Seng Pheow | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Abdul Aziz Peru Mohamed | សមាជិកគណៈកម្មាធិការ |
| 3. | Dato' Khairussaleh Ramli | សមាជិកគណៈកម្មាធិការ |
| 4. | Mr. Christopher Loh Meng Heng | សមាជិកគណៈកម្មាធិការ |
| 5. | Mr. Chulapong Yukate | សមាជិកគណៈកម្មាធិការ |
| 6. | Mr. Lim Loong Seng | សមាជិកគណៈកម្មាធិការ |

## គណៈកម្មាធិការគ្រប់គ្រង

| | | |
|---|---|---|
| 1. | Mr. Chulapong Yukate | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Ong Seng Pheow | សមាជិកគណៈកម្មាធិការ |
| 3. | Mr. Abdul Aziz Peru Mohamed | សមាជិកគណៈកម្មាធិការ |

## គណៈកម្មាធិការគ្រប់គ្រង

| | | |
|---|---|---|
| 1. | Mr. Abdul Aziz Peru Mohamed | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Chulapong Yukate | សមាជិកគណៈកម្មាធិការ |
| 3. | Mr. Ong Seng Pheow | សមាជិកគណៈកម្មាធិការ |

## គណៈកម្មាធិការគ្រប់គ្រង

| | | |
|---|---|---|
| 1. | Mr. Chulapong Yukate | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Ong Seng Pheow | សមាជិកគណៈកម្មាធិការ |
| 3. | Mr. Abdul Aziz Peru Mohamed | សមាជិកគណៈកម្មាធិការ |

# របាយការណ៍លោកអគ្គនាយកប្រចាំប្រទេសកម្ពុជា

ឧស្សាហកម្មសេវាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំងក្នុងទសវត្សចុងក្រោយនេះ។ ជាមួយនឹងការបង្កើតធនាគារពាណិជ្ជថ្មីចំនួន1 ធនាគារឯកទេសថ្មីចំនួន៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានថ្មីយ៉ាងហោចណាស់ចំនួន15 ហើយ ធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុថ្មីមួយចំនួនទៀត ត្រូវបានរំពឹងថានឹងចូលក្នុងទីផ្សារកម្ពុជាក្នុង ឆ្នាំ2017 ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា ("ធនាគារ") រំពឹងថា ការប្រកួតប្រជែងដែលកំពុងជួបប្រទះក្នុងពេលបច្ចុប្បន្ន នឹងកាន់តែមានភាពតឹងតែងជាងមុន។ ធនាគារខ្លះក្នុងចំណោមធនាគារថ្មីទាំងនេះ បានចាប់ផ្តើមផ្តល់សេវាទទួលប្រាក់បញ្ញើក្នុងអត្រាល្អជាងដៃគូប្រកួតប្រជែង ដែលបានបង្រួមគម្លាតប្រាក់ចំណេញយ៉ាងធ្ងន់ធ្ងរ។ ដៃគូប្រកួតប្រជែងខាងលើដែលចូលក្នុងទីផ្សារធនាគារកម្ពុជា ភាគច្រើនគឺជាក្រុមហ៊ុនបុត្តសម្ព័ន្ធបរទេសរបស់គ្រឹះស្ថានហិរញ្ញវត្ថុធំៗ ដែលមានសាច់ប្រាក់ងាយស្រួលលើសពីតម្រូវការទីផ្សារ នៅក្នុងប្រទេសរបស់ពួកគេ។ ទោះបីជាការប្រកួតប្រជែងកាន់តែមានភាពខ្លាំងក្លាឡើង ធនាគារនៅតែអាចចាប់យកចំណែកទីផ្សារបានច្រើនជាងមុន និង បានបង្កើនចំណាត់ថ្នាក់ល្អជាងមុនក្នុងឆ្នាំ 2016 ក្នុងចំណោមធនាគារពាណិជ្ជទាំង 38 នៅកម្ពុជា។

## របាយការណ៍ហិរញ្ញវត្ថុ

ធនាគារសម្រេចបាននូវសមិទ្ធផលផ្នែកហិរញ្ញវត្ថុក្នុងឆ្នាំ 2016 គួរឲ្យកត់សម្គាល់ ដូចជា ការកើនឡើងនូវប្រាក់បញ្ញើរបស់អតិថិជន អនុបាតឥណទាន-ប្រាក់បញ្ញើ និង អនុបាតចំណូល-ចំណាយ។ ប្រាក់បញ្ញើរបស់អតិថិជន បានកើនឡើង 37% ដែលមានចំនួន 81 លានដុល្លារអាមេរិក ធ្វើឲ្យអនុបាតឥណទានប្រាក់បញ្ញើមានការធ្លាក់ចុះមកត្រឹម 120% ដែលមានការធ្លាក់ចុះចំនួន 39% បើធៀបទៅនឹងឆ្នាំ 2015។ អនុបាតចំណូល ចំណាយ ក៏បានធ្លាក់ចុះទាបមិនធ្លាប់មានមកត្រឹម 35.5% ពី 39.2% ក្នុងឆ្នាំ 2015។

ប្រាក់ចំណូលសរុបរបស់ធនាគារក្នុងឆ្នាំ 2016 មានចំនួន 20.9 លានដុល្លារអាមេរិក ដែលមានការកើនឡើងចំនួន 17% និង ប្រាក់ចំណេញមុនដកពន្ធមានចំនួន 8.4 លានដុល្លារអាមេរិក ដែលមានការកើនឡើងចំនួន 5% សម្រាប់ឆ្នាំហិរញ្ញវត្ថុ 31 ធ្នូ 2016។ ទ្រព្យសកម្មសរុបរបស់ធនាគារបានកើនឡើង 10% ដែលមានចំនួន 623 លានដុល្លារអាមេរិក និង ឥណទានបានកើនឡើង 6% ដែលមានចំនួន 362 លានដុល្លារ អាមេរិក។ កំណើនឥណទានត្រូវបានប៉ះពាល់ដោយសារការទម្លាក់តម្លៃយ៉ាងខ្លាំង ជាពិសេសពីធនាគារបរទេសមួយចំនួន ដែលធ្វើឲ្យខាតបង់ទាំងអស់គ្នា និង ដាក់សម្ពាធលើគុណភាពទ្រព្យសកម្មក្នុងឧស្សាហកម្មទាំងមូល ដែលបានកើនឡើងពី 2% ក្នុងឆ្នាំ 2015 ទៅ 2.4% ក្នុងឆ្នាំ 2016។ វិធានការរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីកាត់បន្ថយកំណើនឥណទាន ច្រើនលើសលុប ក៏បានធ្វើឲ្យមានការបញ្ចេញឥណទានដោយប្រុងប្រយ័ត្នជាងមុនផងដែរ។

ក្នុងឆ្នាំ 2016 ធនាគារបានផ្តល់ឥណទានដល់វិស័យសំខាន់ៗដូចជា អាជីវកម្មលក់ដុំ និងលក់រាយ ក៏ដូចជាវិស័យទេសចរណ៍ ដែលជាវិស័យចូលរួមចំណែកធ្វើឲ្យសេដ្ឋកិច្ចកម្ពុជារីកចម្រើន។ ធនាគារក៏បានផ្តោតលើកម្មវិធី "Home Ownership Program" ដោយជំរុញ និងជួយប្រជាជនកម្ពុជា ឲ្យក្លាយជាម្ចាស់លើផ្ទះក្នុងសុបិន្តរបស់ពួកគេ។

### រក្សាកំណើនប្រាក់ចំណេញប្រតិបត្តិការ

24.7%

### កំណើនគណនីសន្សំ និងចរន្ត

68.3%

### អនុបាតថ្លៃដើមធៀបចំណូល

35.5%



**លោក លឹម លូងសេង**
អគ្គនាយកប្រចាំប្រទេសកម្ពុជា

## ការពង្រីកបណ្ដាញប្រតិបត្តិការ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា បានបើកសាខាថ្មីចំនួនពីរក្នុងឆ្នាំ 2016 ដែលធ្វើឲ្យធនាគារមានសាខាសរុបចំនួន 12 សាខា ហើយតាមរយៈនេះ ពង្រីកបណ្ដាញប្រតិបត្តិការរបស់ធនាគារទូទាំងប្រទេស។ សាខាថ្មីទាំងពីរនេះស្ថិតនៅក្នុងរាជធានីភ្នំពេញ ដែលសាខាម៉ៅសេទុង ត្រូវបានបើកក្នុងខែ មេសា និងសាខាបឹងកេងកង ត្រូវបានបើកក្នុងខែ សីហា។ សាខាថ្មីទាំងពីរនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងសាខាទាំងដប់ដែលមានស្រាប់ដោយធ្វើការផ្ដល់ផលិតផល និងសេវាពេញលេញដល់អតិថិជន។ បណ្ដាញម៉ាស៊ីន អេ ធី អឹម របស់ធនាគារដែលស្ថិតនៅក្រៅសាខា ក៏ត្រូវបានពង្រីកពី 12 ម៉ាស៊ីន ទៅ 15 ម៉ាស៊ីន បន្ថែមពីលើម៉ាស៊ីន អេ ធី អឹម ចំនួន 18 ម៉ាស៊ីន ដែលស្ថិតនៅតាមសាខា ដើម្បីផ្ដល់ភាពងាយស្រួលដល់អតិថិជនបន្ថែមទៀត។

## បទប្បញ្ញត្តិ និង អភិបាលកិច្ច

លក្ខខណ្ឌទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុនៅកម្ពុជា កាន់តែមានភាពតឹងរឹងឡើងក្នុងឆ្នាំ 2016 ដោយនិយ័តករ កំពុងតែឈានទៅអនុវត្ត Third Basel Accord (Basel III), International Financial Accounting Standard (IFRS) ការប្រឆាំងការសម្អាតប្រាក់ និង Foreign Account Tax Compliance Act (FATCA) និងមានគោលបំណងពង្រឹងបទប្បញ្ញត្តិ ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារក្នុងប្រទេស។ វិធានការទាំងនេះអាចនាំមកនូវភាពល្អប្រសើរចំពោះសុខភាព ភាពរឹងមាំ និង ស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាសុខមាលភាពសេដ្ឋកិច្ចកម្ពុជា។

ធនាគារផ្ដល់អាទិភាពខ្ពស់ជាងគេដល់ អភិបាលកិច្ចសាជីវកម្ម និងធានាថាគ្រប់លក្ខខណ្ឌទាំងអស់ ត្រូវបានបំពេញ ហើយគោលការណ៍ និងនីតិវិធីផ្ទៃក្នុងទាំងអស់ ត្រូវបានអនុលោមតាមគ្រប់ពេលវេលា។ អភិបាលកិច្ចសាជីវកម្មល្អ ការអនុលោមតាមយ៉ាងខ្ជាប់ខ្ជួន និង ការគ្រប់គ្រងហានិភ័យដោយយកចិត្តទុកដាក់ គឺជាស្នូលនៃ វប្បធម៌របស់សម្ព័ន្ធធនាគារ អ អេច ប៊ី។

# របាយការណ៍អគ្គនាយក ប្រចាំប្រទេសកម្ពុជា (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

## ការជួយដល់សង្គម

ការជួយដល់សង្គម(CSR)នៅតែជាចំណុចស្នូលនៃទំនាក់ទំនងរវាងធនាគារ និងសង្គមកម្ពុជាទាំងមូល ខណៈពេលដែលធនាគារ អ អេច ប៊ី បន្តធ្វើប្រតិបត្តិការនិងរីកចម្រើនឥតឈប់ឈរ។ធនាគារបានរៀបចំកម្មវិធីជួយដល់សង្គមជាច្រើនរយៈពេលប៉ុន្មានឆ្នាំនេះ ដែលបាននាំមកនូវអត្ថប្រយោជន៍ជាវិជ្ជមានដល់ប្រជាជនកម្ពុជា។ ក្នុងឆ្នាំ 2016 ធនាគារក៏បាន សហការជាមួយអង្គការក្រៅរដ្ឋាភិបាល Aide-et-Action ក្រោមកម្មវិធី "The Early Childhood Development School Program" ដើម្បីសាងសង់សាលាបឋមសិក្សាដែលអាចផ្ទុកសិស្សបាន 30នាក់ នៅសហគមជនបទ និងក្រីក្រមួយស្ថិតនៅភូមិស្អាង ខេត្តកណ្តាល។ ស្នាមញញឹម និង ទឹកមុខពោពេញដោយក្តីសង្ឃឹមដែលធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា បានផ្តល់ជូនកុមារទាំងនេះ ឪពុកម្តាយរបស់ពួកគេ និង អ្នកភូមិទាំងអស់ គឺបង្ហាញពីក្តីសប្បាយរីករាយ និងសេចក្តីពេញចិត្ត។ធនាគារនឹងបន្តតាមដាននិងអភិវឌ្ឍសាលារៀននោះ ដើម្បីធានាថា សាលារៀន និងសម្ភារដែលបានផ្តល់ត្រូវបានប្រើប្រាស់ឲ្យអស់ពីលទ្ធភាពដោយសហគមន៍។

ធនាគារបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍវិស័យកីឡានៅកម្ពុជា។ ធនាគារយើងខ្ញុំបន្តរៀបចំកម្មវិធីប្រកួតបាល់ទាត់កុមារ អ អេច ប៊ី ប្រចាំឆ្នាំ និង ទទួលបានជោគជ័យ ដែលចំនួនកុមារចូលរួមមានការកើនឡើងពី 176 នាក់ ទៅ 264 នាក់។ កម្មវិធីនេះទទួលបានការគាំទ្រយ៉ាងច្រើនលើសលុប ហើយធនាគារ អ អេច ប៊ី រងចាំមើលកីឡាករបាល់ទាត់ ទាំងអស់នេះបានបញ្ចប់ការសិក្សានិងតំណាងប្រទេសកម្ពុជាក្នុងព្រឹត្តិការណ៍អន្តរជាតិ។ ធនាគារ អ អេច ប៊ី បានឧបត្ថម្ភកីឡាករជិះកង់ ជម្រើសជាតិកម្ពុជា និង បានផ្សព្វផ្សាយព្រឹត្តិការណ៍ជិះកង់ឡើងភ្នំជាច្រើន ដែលធ្វើឲ្យមានការនិយមជិះកង់ និងជួយឲ្យប្រជាជនកម្ពុជាចូលរួមក្នុងសកម្មភាពដើម្បីសុខភាព។









## យុទ្ធសាស្ត្ររីកចម្រើន

ចាប់ពីពេលនេះតទៅ ធនាគារនឹងផ្តោតទៅលើអាទិភាពសំខាន់ៗមួយចំនួន ដើម្បីដឹកនាំធនាគារ ឲ្យ សម្រេចសេចក្តីប៉ងប្រាថ្នាក្នុងការក្លាយជាធនាគារនាំមុខមួយនៅកម្ពុជា។ ធនាគារ នឹងបន្តគាំទ្រវិស័យសេដ្ឋកិច្ចដែលមានស្ថេរភាព ដែលចូលរួមចំណែកធ្វើឲ្យសេដ្ឋកិច្ចកម្ពុជារីកចម្រើន។ ធនាគារក៏បានគោលបំណងបង្កើតតុល្យភាពផលប័ត្រឥណទានរវាងអតិថិជនជារូបវន្តបុគ្គល និង អតិថិជនជាក្រុមហ៊ុនផងដែរ ក្នុងឆ្នាំ2017។

ធនាគារត្រូវគ្រប់គ្រងការបង្រួមគម្លាតប្រាក់ចំណេញ ដើម្បីបង្កើនប្រាក់ចំណេញ និងគ្រប់គ្រងគុណភាពទ្រព្យសកម្មឲ្យបានល្អដើម្បីកាត់បន្ថយ ឥណទានខូច ព្រោះថាបរិយាកាសអាជីវកម្មកាន់តែមានភាពប្រកួតប្រជែងខ្លាំងឡើងៗ។ ធនាគារបានបង្កើតនីតិវិធីលើកកម្ពស់ផលិតកម្ម និងគំនិតផ្តួចផ្តើម គ្រប់គ្រងចំណាយ ដើម្បីធានាប្រសិទ្ធភាពខ្ពស់នៃថ្លៃប្រតិបត្តិការ។

ធនាគារប្តេជ្ញាផ្តល់សេវាដែលមានគុណភាពប្រសើរជាងមុននិងបទពិសោធន៍ធនាគារដែលមានភាពរាក់ទាក់ និង លក្ខណៈពិសេសប្លែកពីគេ តាមរយៈកម្មវិធីលើកកម្ពស់បទពិសោធន៍អតិថិជន។ ក្នុងឆ្នាំ2017 ធនាគារនឹងផ្តល់ជូននូវផលិតផល និងសេវាបន្ថែមមួយចំនួនទៀត ដើម្បីផ្តល់បទពិសោធន៍ល្អប្រសើរ ដល់អតិថិជន ទៅតាមតម្រូវការ និងការចង់បាន។

ក្រោមគំនិតផ្តួចផ្តើមរបស់សម្ព័ន្ធ ធនាគារបានចាប់ផ្តើមបង្កើតបណ្តាញសេវាធនាគារឌីជីថលជាច្រើន ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនរួមមានសេវាធនាគារចល័ត សេវាធនាគារអនឡាញ និងមធ្យោបាយទូទាត់ផ្សេងទៀត។ ធនាគារមានបំណងធ្វើជាអ្នកនាំមុខគេ ក្នុងការនាំយកបច្ចេកវិជ្ជាសេវាធនាគារឌីជីថលទំនើបមួយមកកម្ពុជា។

ធនាគារនឹងបន្តវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស និងបណ្តុះវប្បធម៌សារជីវកម្មវិជ្ជមាន ដើម្បីសម្រេចបានវប្បធម៌ប្រសិទ្ធភាពការងារខ្ពស់។ បុគ្គលិករបស់ធនាគារ បានបញ្ចប់វគ្គបណ្តុះបណ្តាលសរុបចំនួន 4,855ម៉ោង ក្នុងឆ្នាំ2016 ហើយយើងខ្ញុំប្តេជ្ញានឹងបង្កើនវគ្គបណ្តុះបណ្តាលនៅក្នុង ឆ្នាំ2017។ យើងខ្ញុំជឿជាក់ថា ធនធានមនុស្ស និង ជំនាញរបស់បុគ្គលិកយើងខ្ញុំ ពិតជាមាន សារៈសំខាន់ណាស់ ដើម្បីទទួលបានភាពជោគជ័យ និងរីកចម្រើន ក្នុងឆ្នាំខាងមុខ។

## ដំណើរឆ្ពោះទៅមុខ

នៅមានចន្លោះជាច្រើន សម្រាប់រីកចម្រើននៅក្នុងប្រទេសកម្ពុជា ដោយសារតែមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវថ្នល់ ស្ពាន និងថាមពល ផលិតកម្មចម្រុះរាប់ពីសម្លៀកបំពាក់និងស្បែកជើងរហូតដល់គ្រឿងអេឡិចត្រូនិក និងការតម្លើងផលិតផល ការជំរុញឲ្យមានកំណើនក្នុងវិស័យទេសចរណ៍ និង GDP កម្ពុជា ត្រូវបានព្យាករណ៍ថារក្សាបាននូវកំណើនក្នុងអត្រា 7% និងការចាប់អារម្មណ៍មកលើកម្ពុជាទាក់ទិននឹងឱកាសវិនិយោគបរទេសផ្ទាល់ពីប្រទេសក្នុងតំបន់អាស៊ាន និងប្រទេសជិតខាង។ ទោះបីជាមានសក្តានុពល រីកចម្រើនខ្លាំងបែបនេះក៏ដោយ ធនាគារត្រូវយកចិត្តទុកដាក់ជាប្រចាំ និងប្រុងប្រយ័ត្នលើបញ្ហាប្រឈមមួយចំនួនរួមមាន ការប្រកួតប្រជែងយ៉ាងខ្លាំង ការបង្រួមគម្លាតប្រាក់ចំណេញ និងសម្ពាធលើគុណភាពទ្រព្យសកម្មជាដើម។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអតិថិជនទាំងអស់ ដែលតែងតែគាំទ្រធនាគារយើងខ្ញុំនៅ កម្ពុជា ក្នុងរយៈពេល 9ឆ្នាំ កន្លងមកនេះ។ តាមរយៈពាក្យស្លោក "Together We Progress" យើងខ្ញុំនឹងបន្តធ្វើការឲ្យអស់ពីសមត្ថភាព ដើម្បីធានាឆ្លើយតបទៅនឹងតម្រូវការសេវាធនាគាររបស់អតិថិជន។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះធនាគារជាតិនៃកម្ពុជា សម្រាប់ការណែនាំ និងការគាំទ្រ។ ខ្ញុំបាទសូមថ្លែងអំណរគុណផងដែរ ចំពោះក្រុមប្រឹក្សាភិបាលសម្រាប់ការដឹកនាំ និង ចំពោះបុគ្គលិកទាំងអស់សម្រាប់ការចូលរួមចំណែក និងការប្តេជ្ញាចិត្ត។ សូមអរគុណ!



**លោក លីមលួងសេង**
អគ្គនាយក
ប្រចាំប្រទេសកម្ពុជា



# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់

ពីខាងឆ្វេងដៃ:

1) អាល់ឌៀន រីហ្សាល់ 2) យឹម ទិត្យា 3) ម៉ូហាម៉ាត់ យ៉ូស៊ូស្ស អាសម៉ាត់ ស្សាប៉ារី 4) ចុង គឹមស៊ួន 5) លឹម លួងសេង
6) យ៉ុង ឆឹងសាន 7) ឈ័រ តាំមយីរ 8) ម៉ឹង សំណាង 9) ឈឹម សារ៉េត



# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា




លោក Lim Loong Seng មានបទពិសោធន៍ច្រើនជាង 38ឆ្នាំ ដែល 34ឆ្នាំ នៅក្នុងឧស្សាហកម្ម សេវាហិរញ្ញវត្ថុ និងប្រហែល 9ឆ្នាំ ក្នុងប្រទេសកម្ពុជា។ លោកបានចាប់ផ្តើមអាជីពក្នុងវិស័យធនាគារជាមួយ សម្ព័ន្ធសេវាហិរញ្ញវត្ថុនាំមុខមួយរបស់ម៉ាឡេស៊ី។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ ទាក់ទង នឹងសេវាធនាគារសាជីវកម្ម សេវាធនាគាររូបវន្តបុគ្គល និងសេវាធនាគារក្រុមហ៊ុន ដោយកាន់តំណែងជាន់ខ្ពស់គ្រប់គ្រងផ្នែកប្រតិបត្តិការ ឥណទានហានិភ័យ និងផ្នែកលក់ & ទីផ្សារ។

លោកទទួលបានមេដាយមាស SEARCA និង Harvard Business Alumni Club Malaysia Gold Medal នៅពេលដែលលោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែក Agribusiness ក្នុងឆ្នាំ1986។

លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន RHB Indochina Securities Co., Ltd. និង ធនាគារ RHB Bank (Laos) Ltd.។ លោកក៏ទទួលមើលការខុសត្រូវលើ ការិយាល័យតំណាងរបស់ធនាគារ RHB នៅប្រទេសវៀតណាម និង ប្រទេសមីយ៉ាន់ម៉ាផងដែរ។

លោកទទួល បានអាជ្ញាប័ណ្ណជាពាណិជ្ជករមូលបត្រ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា។ លោកត្រូវបានជ្រើសតាំងជាអនុប្រធានសមាគមពាណិជ្ជកម្ម ម៉ាឡេស៊ី នៅកម្ពុជាចាប់តាំងពីឆ្នាំ 2010 មក។



## ចុង គឹមស៊ួន, សាយម៉ន

### ប្រធានផ្នែកប្រតិបត្តិ

លោក សាយម៉ន បានចូលបំរើការ ជាមួយធនាគារ អ អេ ច ប៊ី ឥណ្ឌូឆៃណា នៅ ខែកញ្ញា ឆ្នាំ 2008 ជានាយកផ្នែកប្រតិបត្តិការរហូតដល់ពេលបច្ចុប្បន្ន។ លោកបានបំរើការអោយស្ថាប័នហិរញ្ញវត្ថុកំពូលមួយចំនួន របស់ប្រទេសម៉ាឡេស៊ីអស់រយ:ពេលជាង 28ឆ្នាំ ដែលធ្វើអោយលោកកើនឡើងឋាន: និងមានបទពិសោធន៍ធំទូលាយនៅក្នុង ផ្នែកប្រតិបត្តិការធនាគារ។ លោកបានដឹកនាំពាណិជ្ជកម្មនិងគំនិតផ្តួចផ្តើមកែលម្អដំណើរការបច្ចេកទេសធនាគារក៏ដូចជាការស្រាវជ្រាវនិងការអភិវឌ្ឍន៍។

គាត់ធ្លាប់ជានាយកផ្នែកអនុវត្តគំរោងនិងអភិវឌ្ឍន៍ដំណើរការពាណិជ្ជកម្ម និងនិតិវិធី។ លោក សាយម៉ន បានបញ្ចប់ការសិក្សាពីសញ្ញាប័ត្រកិតិយុត្តសឆ្នាំ1981ហើយបានទៅបន្តការសិក្សានៅក្នុងសាកលវិទ្យាល័យ York ប្រទេសកាណាដា។



## យ៉ុង ជឹងសាន

### ប្រធានផ្នែកឥណទាន

លោក យ៉ុង បានចូលរួមជាមួយ ធនាគារ អ អេ ច ប៊ី ឥណ្ឌូឆៃណា នៅខែ វិច្ឆិកា ឆ្នាំ2010 ហើយបច្ចុប្បន្ន លោកជានាយកផ្នែកឥណទាន។ គាត់មានបទពិសោធន៍ក្នុងវិស័យធនាគាររយ:ពេល31ឆ្នាំ និង2ឆ្នាំ នៅក្នុង ស្ថាប័នរដ្ឋ និងជាអ្នកផ្តល់យោបល់ ផ្នែកបណ្តុះបណ្តាលមួយ។

លោកមានបទពិសោធន៍ខ្ពស់ក្នុងធនាគារ ពាណិជ្ជកម្មបានបំរើការទាំងសាខា និងការិយាល័យកណ្តាលក្នុងផ្នែកឥណទានប្រតិបត្តិការអភិវឌ្ឍន៍ សាជីវកម្ម និងបណ្តុះបណ្តាល។ លោកបាន បញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Greenwich សហរដ្ឋអាមេរិកជាមួយនឹងបរិញ្ញាប័ត្រ គ្រប់គ្រងពាណិជ្ជកម្មនៅ ឆ្នាំ2007។ លោកក៏បានសម្រេចផែនការផ្នែកហរិញ្ញវត្ថុវិញ្ញាបនបត្រពីសមាគមរៀបចំផែនការហិរញ្ញវត្ថុរបស់ប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ 2006។

# សមាសភាពរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា



## ឈ័រ ធៀមយ៉ូវ

### ប្រធានផ្នែកផ្នែកហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ

លោក ឈ័រ បានចូលរួមជាមួយ ធនាគារ អ អេ ច ប៊ី ឥណ្ឌូឆៃណា នៅខែ ឧសភា ឆ្នាំ2014 ហើយបច្ចុប្បន្ន លោកជានាយកផ្នែកហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រ។ លោកមានបទពិសោធន៍ច្រើនជាង 15ឆ្នាំ លើផ្នែកហិរញ្ញវត្ថុ ហើយលោកមានបទពិសោធន៍លើផ្នែកសវនកម្ម ចាត់ចែងដើមទុន គ្រប់គ្រងហិរញ្ញវត្ថុ ប៉ាយការណ៍ហិរញ្ញវត្ថុ ពន្ធ និងយុទ្ធសាស្ត្រអាជីវកម្ម។

លោកបានបញ្ចប់ការសិក្សាពី Association of Charted Accountants (ACCA) ពីចក្រភពអង់គ្លេស ហើយលោកក៏បានបញ្ចប់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យ Melbourne ប្រទេសអូស្ត្រាលី។



## ម៉ូហាម៉ាត់ យ៉ូស៊ូស្ស អាសម៉ាត់ ស្សាប៉ារី

### ប្រធានផ្នែកធនធានមនុស្ស

លោក យ៉ូស៊ូស្ស គឺជាប្រធានផ្នែកធនធានមនុស្ស និងបណ្តុះបណ្តាល។ លោកបានបញ្ចប់ការសិក្សា ពីសកលវិទ្យាល័យ Sheffield Hallam ផ្នែកច្បាប់ ក្នុងឆ្នាំ1996។ លោកមានផ្លាស់មកអ អេ ច ប៊ីឥណ្ឌូឆៃណា នៅ ខែមិថុនា ឆ្នាំ2012 ពីមុនលោកជាដៃគូរពាណិជ្ជកម្មធនធានមនុស្សសម្រាប់ សម្ព័ន្ធចាយរាយ នៃ RHB Bank។

លោកមានបទពិសោធន៍នៃការគ្រប់គ្រងធនធានមនុស្សរួមមានការចូលរួមក្នុងការជ្រើសរើសបុគ្គល ប្រតិបត្តិការធនធានមនុស្ស ប្រាក់សំណង និងអត្ថប្រយោជន៍ នៃរដ្ឋបាលគោលនយោបាយ និងនីតិវិធីនៃធនធានមនុស្ស ការគ្រប់គ្រងលើការវាយតម្លៃការ ជ្រើសរើសបុគ្គលិកឧស្សាហកម្ម និងទំនាក់ទំនងនឹងបុគ្គលិក។



## អាល់ឌៀន វីហ្សាល

### ប្រធានផ្នែកអភិវឌ្ឍន៍ផលិតផល និងទំនាក់ទំនងទីផ្សារ

លោក វីហ្សាល់ បានផ្លាស់ពី RHB Bank Berhad ក្នុងខែកក្កដា ឆ្នាំ2014។ លោកមានបទពិសោធន៍21ឆ្នាំ ក្នុងវិស័យធនាគារ និងឧស្សាហកម្មធានារ៉ាប់រង។ លោក ក៏មានបទពិសោធន៍ផ្នែកសវនកម្មផ្នែកលក់ និងទីផ្សារ និងប្រតិបត្តិការធនាគារអន្តរជាតិផងដែរ។ លោកបានទទួលសញ្ញាបត្រ គណនីក្នុង ឆ្នាំ1996 នៅ ចក្រភពអង់គ្លេស មហាវិទ្យាល័យ Northumbria ។



## ម៉ឹង សំណាង

### ប្រធានផ្នែកប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យ

លោក សំណាង មានតួនាទីជាប្រធានផ្នែកប្រតិបត្តិតាម និងគ្រប់គ្រងហានិភ័យតាំងពីខែមករា ឆ្នាំ2010។ គាត់មានបទពិសោធន៍ 13ឆ្នាំ ជាទីប្រឹក្សា និងសវនករ។ គាត់ធ្លាប់ជាប្រតិបត្តិ និងសវនករ នៅក្នុងក្រុមហ៊ុនសវនកម្មអន្តរជាតិ KPMG Cambodia និងជាទីប្រឹក្សានៅក្នុងនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាកន្លែងចុងក្រោយក្នុងអាជីពជាទីប្រឹក្សា។ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ វេទមហាឬស្សី នៅឆ្នាំ2004។ មិនតែប៉ុណ្ណោះគាត់បានទទួលបរិញ្ញាបត្រ បច្ចេកទេសគណនេយ្យ ពីចក្រភពអង់គ្លេសនៅឆ្នាំ2007 ហើយបច្ចុប្បន្ន នាក់កំពុងបន្តការសិក្សាផ្នែកគ្រប់គ្រងហានិភ័យហារិញ្ញវត្ថុពី Grobal Association of Risk Professional។

# សមាសភាពរបស់ក្រុមថ្នាក់ដឹកនាំជាន់ខ្ពស់ (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា



## ឈឹម សារ៉េត

### ប្រធានផ្នែកសវនកម្មផ្ទៃក្នុង

លោក សារ៉េត គឺជាប្រធានផ្នែកសវនកម្មផ្ទៃក្នុង។ លោកបានចូលបម្រើការងារនៅក្នុងខែកក្កដា ឆ្នាំ2009។លោកមានបទពិសោធន៍ការងារ 14ឆ្នាំ ហើយក្នុងនោះបទពិសោធន៍ 2ឆ្នាំ ជាគ្រូបង្រៀនផ្នែកគណនេយ្យនិងជាសវនករខាងក្រៅរយៈពេល 4ឆ្នាំ។

លោកមានបទពិសោធន៍ក្នុងការប្រតិបត្តិតាមនិង និងទីប្រឹក្សាសវនកម្មលើ វិស័យជាច្រើនដូចជា ធនាគារស្ថាប័នមីក្រូហិរញ្ញវត្ថុការធានារ៉ាប់រងរោងចក្រកាត់ដេរភោជនីយដ្ឋាន និងក្រុមហ៊ុនផ្តល់សេវាកម្មអំឡុងពេលធ្វើការនៅ KPMG ប្រទេសកម្ពុជា ។

លោក បានសញ្ញាបត្រអនុបណ្ឌិតផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុពីវិទ្យាស្ថានអន្តរជាតិនៃប្រទេសកម្ពុជា (IIC) នៅក្នុងឆ្នាំ 2006។ លោកក៏ទទួលបានវិញ្ញាបនបត្រអ្នកបច្ចេកទេសគណនេយ្យ (CAT) នៅក្នុងឆ្នាំ 2008 ហើយ បច្ចុប្បន្នកំពុងបន្តសិក្សា Association of Charted Accountants (ACCA) ពីចក្រភពអង់គ្លេស។



## យឹម ទិត្យា

### ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន

លោក ទិត្យា ជាប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មានក្នុងខែមករា ពីឆ្នាំ 2013។ លោកមានបទពិសោធន៍ 13ឆ្នាំ ជាមួយនឹងបច្ចេកវិទ្យា ព័ត៌មាន និងប្រព័ន្ធបច្ចេកទេស។ លោកមានតួនាទីគ្រប់គ្រងប្រតិបត្តិការផ្នែក IT និងត្រួតពិនិត្យហេដ្ឋារចនាសម្ព័ន្ធ IT នៅក្នុងការជួយសំរួល នៅក្រៅបណ្តាញ និងផលិតផលសេវាកម្មសម្រាប់ អាជីវកម្មរបស់ធនាគារ។ លោកបានទទួលសញ្ញាបត្រផ្នែកបច្ចេកវិទ្យាព័ត៌មានពី សាកលវិទ្យាល័យ Teknology Petronas ពីប្រទេសម៉ាឡេស៊ីក្នុងឆ្នាំ2007។

# គណៈកម្មាធិការគ្រប់គ្រង

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

| គណៈកម្មាធិការគ្រប់គ្រង | | |
|---|---|---|
| 1. | Mr. Lim Loong Seng | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Cheong Kim Soon | សមាជិកគណៈកម្មាធិការ |
| 3. | Mr. Chua Thiam Yew | សមាជិកគណៈកម្មាធិការ |
| 4. | Mr. Yong Ching San | សមាជិកគណៈកម្មាធិការ |
| 5. | Mr. Mohamad Yussof Ahmad Sapari | សមាជិកគណៈកម្មាធិការ |
| 6. | Mr. Aldrian Rizal Zahari | សមាជិកគណៈកម្មាធិការ |
| 7. | Mr. Meung Samnang | សមាជិកគណៈកម្មាធិការ |

| គណៈកម្មាធិការឥណទាន | | |
|---|---|---|
| 1. | Mr. Christopher Loh | ប្រធានគណៈកម្មាធិការគ្រប់គ្រង |
| 2. | Mr. Lim Loong Seng | សមាជិកគណៈកម្មាធិការ |
| 3. | Mr. Cheong Kim Soon | សមាជិកគណៈកម្មាធិការ |
| 4. | Mr. Yong Ching San | សមាជិកគណៈកម្មាធិការ |

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

ក្រុមប្រឹក្សាភិបាលមានសេចក្តីរីករាយសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា (ហៅកាត់ថា "ធនាគារ") សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016។

**អំពីធនាគារ**

ធនាគារបានចុះបញ្ជីពាណិជ្ជកម្ម នៅថ្ងៃទី09 ខែកក្កដា ឆ្នាំ2008គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ RHB Bank Berhad ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពាណិជ្ជកម្ម នៅប្រទេសម៉ាឡេស៊ី។

ធនាគារ គឺជាធនាគារពាណិជ្ជ ដែលកំពុងធ្វើប្រតិបត្តិការក្រោមច្បាប់ស្តីពីសហគ្រាសពាណិជ្ជនៃកម្ពុជា និងក្រោមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល")។

**សកម្មភាពចម្បង**

ធនាគារធ្វើសកម្មភាពចម្បងក្នុងការផ្តល់សេវាធនាគារពាណិជ្ជជាច្រើនប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**លទ្ធផលហិរញ្ញវត្ថុ**

លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលនៅលើទំព័រទី201។

**ដើមទុន**

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ដើមទុនដែលបានបង់របស់ធនាគារមានចំនួន 67.000.000 ដុល្លារអាមេរិក (តម្លៃចារិក 1ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន)។ មិនមានការផ្លាស់ប្តូរភាគហ៊ុនក្នុងអំឡុងឆ្នាំនោះទេ។

**សំវិធានធន**

ក្នុងអំឡុងឆ្នាំនេះមិនមានបម្រែបម្រួលជាសារវន្តក្នុងគណនីសំវិធានធន ក្រៅពីអ្វីដែលបានលាតត្រដាងក្នុងរបាយការណ៍ ហិរញ្ញវត្ថុនេះទេ។

**ឥណទាន និងបុរេប្រទានអាក្រក់ និងឥណទានសង្ស័យ**

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ពាក់ព័ន្ធទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនយ៉ាងពេញលេញ សម្រាប់បុរេប្រទាននិងឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹតក្រុមប្រឹក្សាភិបាលពុំបានដឹងពី ហេតុការណ៍ណាមួយដែលនាំឲ្យចំនួននៃសំវិធានធនសម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងសង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

**ទ្រព្យសកម្ម**

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្របដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ក្រៅពីបំណុលដែលទំនងជាមិនអាចបង្វិលមកវិញ នៅក្នុងប្រតិបត្តិការអាជីវកម្ម ធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹតក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងធនាគារពុំត្រឹមត្រូវជាសារវន្តទេ។

បំណុលយថាភាព និងបំណុលផ្សេងៗ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន ៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់ធនាគារដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធម្មតារបស់ធនាគារនោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារបានក្លាយជាការបង្ខំ ឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីដំណាច់ឆ្នាំដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់ពេលកំណត់សងនោះទេ។

**ការប្រែប្រួលកាលៈទេសៈ**

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុង របាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ធនាគារសម្រាប់ដំណាច់ឆ្នាំនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនីប្រតិបត្តិការឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

## ប្រតិបត្តិការមិនប្រក្រតី (ត)

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម ៖

| | |
|---|---|
| Ong Seng Pheow | ប្រធានក្រុមប្រឹក្សាភិបាល |
| Abdul Aziz Peru Mohamed | សមាជិកក្រុមប្រឹក្សាភិបាល |
| Chulapong Yukate | សមាជិកក្រុមប្រឹក្សាភិបាល |
| Dato' Khairussaleh Ramli | សមាជិកក្រុមប្រឹក្សាភិបាល |
| Christopher Loh | សមាជិកក្រុមប្រឹក្សាភិបាល |
| Lim Loong Seng | សមាជិកក្រុមប្រឹក្សាភិបាល |

| | |
|---|---|
| Tuan Haji Khairuddin Ahmad | ប្រធានក្រុមប្រឹក្សាភិបាល (បានលាលែងពីតំណែងនៅថ្ងៃទី20 ខែធ្នូ ឆ្នាំ2016) |
| Foo San Kan | សមាជិកក្រុមប្រឹក្សាភិបាល (បានលាលែងពីតំណែងនៅថ្ងៃទី20 ខែធ្នូ ឆ្នាំ2016) |
| Leong Yeng Kit | សមាជិកក្រុមប្រឹក្សាភិបាល (បានលាលែងពីតំណែងនៅថ្ងៃទី20 ខែធ្នូ ឆ្នាំ2016) |
| Choong Tuck Onn | សមាជិកក្រុមប្រឹក្សាភិបាល (បានលាលែងពីតំណែងនៅថ្ងៃទី27 ខែមករា ឆ្នាំ2016) |
| U Chen Hock | សមាជិកក្រុមប្រឹក្សាភិបាល (បានលាលែងពីតំណែងនៅថ្ងៃទី27 ខែមករា ឆ្នាំ2016) |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

1. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានសង្គតភាព។
2. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវក្រុមប្រឹក្សាភិបាលប្រតិបត្តិត្រូវប្រាកដថា ការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
3. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
4. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតយ៉ាងសមស្របថាធនាគារ នឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
5. គ្រប់គ្រង និងដឹកនាំធនាគារឲ្យមានប្រសិទ្ធភាពតាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវធានាថា ផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលសូមធានាអះអាងថារបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យ កម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។




Ong Seng Pheow
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ៖ ថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2017

# របាយការណ៍សវនករឯករាជ្យ

## ជូនភាគទុនិក ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា (ហៅកាត់ថា "ធនាគារ") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល")

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា(ហៅកាត់ថា"ស្តង់ដារ សវនកម្ម")។ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជា មូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រម សីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ច ក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀតដែលកំណត់ដោយក្រម សីលធម៌អន្តរជាតិ និង "វគសក"។

### ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានឧបសម្ព័ន្ធដែលជាតម្រូវការរបស់ធនាគារកណ្តាល ប៉ុន្តែឧបសម្ព័ន្ធទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះ មានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពី កំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែល កើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍នោះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យ ផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុលឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅ នឹងនិរន្តភាព អាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្ម របស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

### ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការ ក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំ ទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តភាពអាជីវកម្មរបស់គណៈគ្រប់គ្រងអាស្រ័យ ទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យជាដុំកំភួនទៅ លើលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាវាមាន ភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុចំពោះការលាតត្រដាងព័ត៌មាននៅក្នុង របាយការណ៍ហិរញ្ញវត្ថុឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀតយើងខ្ញុំត្រូវធ្វើការកែប្រែ មតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់ យើងខ្ញុំអាស្រ័យទៅលើភស្តុតាង សវនកម្មដែលយើងខ្ញុំទទួលបានរហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។

  ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យធនាគារឈប់បន្តនិរន្តភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុរាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗ ដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើង ខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers (Cambodia) Ltd.

ឡាង ហ៊ី

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2017

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ

ធនាគារ អេ អេច ប៊ី ឥណ្ឌូឆៃណា

**សេចក្តីផ្តើម**
អនុលោមទៅតាមប្រការ២៥ នៃប្រកាស ធ-7-010-172 ប្រ.ក ស្តីពីការត្រួតពិនិត្យផ្ទៃក្នុងរបស់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី 28 ខែ កញ្ញា ឆ្នាំ 2010 និងលិខិតលេខ ធ-7-015-161 សជណ ចុះថ្ងៃទី 03 ខែ មីនា ឆ្នាំ 2015 តម្រូវឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាមានការរៀបចំនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

របាយការណ៍ខាងក្រោមត្រូវបានរៀបចំឡើងទៅតាមសេចក្តីណែនាំ ដែលបានចែងក្នុងប្រកាសស្តី ពីការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុះសេចក្តីណែនាំសម្រាប់ការរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីរចនាសម្ព័ន្ធ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ការទទួលខុសត្រូវ**
ក្រុមប្រឹក្សាភិបាលបានទទួលស្គាល់នូវទំនួលខុសត្រូវជារួមទៅលើការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុងដ៏ប្រសើរមួយសម្រាប់វាយតម្លៃប្រសិទ្ធភាពរបស់ខ្លួន។ ប្រព័ន្ធនេះ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងហានិភ័យ ដោយយោងទៅតាមកម្រិតហានិភ័យដែលធនាគារអាចទទួលយកបាន និងកម្រិតហានិភ័យដែលអាចទ្រាំទ្របានដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ជៀសជាងការលុបចោលហានិភ័យទាំងស្រុង ក្នុងការសម្រេចឲ្យបាននូវគោលដៅអាជីវកម្មរបស់ធនាគារ។ ដូច្នេះប្រព័ន្ធនេះអាចត្រឹមតែផ្តល់អំណះអំណាងសមហេតុផលប៉ុណ្ណោះ ប៉ុន្តែពុំអាចធានាបានទាំងស្រុងចំពោះកំហុសឆ្គងជាសារវន្ត ការបាត់បង់ ឬការឆបោកឡើយ។

ក្រុមប្រឹក្សាភិបាលត្រូវបានជួយជ្រោមជ្រែងដោយគណៈកម្មការគ្រប់គ្រង និងគណកម្មការសវនកម្ម ដែលត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវលើការត្រួតពិនិត្យបឋម និងប្រព័ន្ធគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

គណៈគ្រប់គ្រងក៏មានតួនាទីក្នុងការជួយក្រុមប្រឹក្សាភិបាលដើម្បីអនុវត្តគោលនយោបាយ និងដំណើរការនានារបស់ធនាគារលើការកំណត់ ការវាយតម្លៃ ការគ្រប់គ្រង និងការវាយការណ៍ពី ហានិភ័យ ព្រមទាំងប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការចាត់វិធានការកែតម្រូវឲ្យបានសមស្របនិងទាន់ពេលវេលា ក៏ដូចជាផ្តល់ការធានាអះអាងទៅក្រុមប្រឹក្សាភិបាលថា រាល់ដំណើរការទាំងនោះត្រូវបានអនុវត្ត។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាភិបាលបានទទួលការធានាអះអាងពីនាយកគ្រប់គ្រង និងប្រធានគ្រប់គ្រងហានិភ័យថា ប្រព័ន្ធគ្រប់គ្រងហានិភ័យនិងការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តគ្រប់គ្រាន់ និងមានប្រសិទ្ធភាព នៅគ្រប់ផ្នែកសំខាន់ៗទាំងអស់ តាមរយៈប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

**ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង**

- **ការគ្រប់គ្រងហានិភ័យ**
  ការគ្រប់គ្រងហានិភ័យគឺមានសារៈសំខាន់ណាស់សម្រាប់គ្រប់ផ្នែករបស់ធនាគារ និងជាទំនួលខុសត្រូវរបស់បុគ្គលិកគ្រប់រូបផងដែរ។ ធនាគារបានដាក់ចេញជាស្រេចនូវគោលការណ៍ជាក់លាក់ក្នុងការគ្រប់គ្រងហានិភ័យដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលដើម្បីកំណត់វាយតម្លៃ គ្រប់គ្រង និងរាយការណ៍នូវហានិភ័យចម្បងៗដែលត្រូវបានជួបប្រទះដោយធនាគារដែលអាចធ្វើឲ្យប៉ះពាល់ទៅដល់ការសម្រេចគោលដៅអាជីវកម្មរបស់ធនាគារ។

  រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរបស់ធនាគារគឺដើម្បីធ្វើឲ្យប្រាកដថា មានដំណើរការជាបន្តបន្ទាប់ដ៏មានប្រសិទ្ធភាពមួយសម្រាប់គ្រប់គ្រងហានិភ័យ ក្នុងធនាគារទាំងមូល។ ដំណើរការនេះគឺត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដោយក្រុមប្រឹក្សាភិបាល តាមរយៈគណៈកម្មការគ្រប់គ្រងហានិភ័យ ដែលធ្វើការត្រួតពិនិត្យបន្ថែមទៀតទៅលើសកម្មភាពគ្រប់គ្រងហានិភ័យដល់ធនាគារ ដើម្បីធានាឲ្យបានថា ដំណើរការក្នុងការគ្រប់គ្រងហានិភ័យរបស់ធនាគារមានលក្ខណៈល្អប្រសើរ និងមានប្រសិទ្ធភាព។

  តាមរយៈមុខងាររបស់គណៈកម្មការគ្រប់គ្រងហានិភ័យ ក្រុមប្រឹក្សាភិបាលបានបង្កើតនូវកម្រិតហានិភ័យដែលអាចទទួលយកបាន និងកម្រិតហានិភ័យដែលអាចទ្រាំទ្របានសម្រាប់ធនាគារ និងស្ថាប័នពាក់ព័ន្ធ។ កម្រិតហានិភ័យដែលអាចទទួលយកបាន និងកម្រិតហានិភ័យដែលអាច ទ្រាំទ្របានត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ដោយគណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលដើម្បីឲ្យស្របទៅនឹងយុទ្ធសាស្ត្រពាណិជ្ជកម្ម និងស្របតាមយុទ្ធសាស្ត្រអាជីវកម្មរបស់ Group។ ជារៀងរាល់ត្រីមាស របាយការណ៍ពីការគ្រប់គ្រងហានិភ័យរបស់ធនាគារដោយរួមមានវង្វាស់វង្វាល់ហានិភ័យ និងតារាងកម្រិតហានិភ័យដែលអាចទ្រាំទ្របានត្រូវបានលើកបង្ហាញទៅក្រុមប្រឹក្សាភិបាលសម្រាប់ផ្តល់ជាព័ត៌មានការពិភាក្សានិងការធ្វើសេចក្តីសម្រេច ប្រសិនបើចាំបាច់។

- **ការគ្រប់គ្រងហានិភ័យ** (ត)
  គណៈកម្មការគ្រប់គ្រងហានិភ័យ ក៏បានជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យឡើងវិញទៅលើទស្សនៈ  រចនាសម្ព័ន្ធ  គោលនយោបាយ និងបែបផែនគំរូនៃការគ្រប់គ្រងហានិភ័យទូទៅរបស់ធនាគារ។ ក្នុងការបំពេញតួនាទីនិងការទំទួលខុសត្រូវ គណៈកម្មការគ្រប់គ្រងហានិភ័យត្រូវបានជួយជ្រោមជ្រែងដោយផ្នែកគ្រប់គ្រងហានិភ័យដែលធ្វើការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យជាបន្តបន្ទាប់។

  ផ្នែកគ្រប់គ្រងហានិភ័យផ្តល់ឲ្យនូវឯករាជ្យភាពនៃការត្រួតពិនិត្យ ទៅលើសកម្មភាពពាណិជ្ជកម្ម និងការអនុវត្តនូវរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរបស់ Group  ដើម្បីថែរក្សានិងការពារទ្រព្យសម្បត្តិរបស់ធនាគារ  ដោយទប់ស្កាត់និងកាត់បន្ថយនូវការខាតបង់ផ្នែកហិរញ្ញវត្ថុ  និងការបាត់បង់កេរ្តិ៍ឈ្មោះរបស់ធនាគារផងដែរ។ តួនាទីរបស់ផ្នែកគ្រប់គ្រងហានិភ័យ រួមមានការអនុវត្តគោលនយោបាយនិងរចនាសម្ព័ន្ធហានិភ័យរបស់ធនាគារ ការត្រួតពិនិត្យនិងការវាស់វែងហានិភ័យប្រចាំថ្ងៃ    ការផ្តល់ឲ្យនូវការវិភាគហានិភ័យឲ្យបានទាន់ពេលវេលាជូនគណៈគ្រប់គ្រងធានាឲ្យបាននូវការគោរពទៅតាមបទបញ្ញាត្តិដែលតម្រូវឲ្យរាយការណ៍ពីហានិភ័យ ការត្រួតពិនិត្យលើការវាយតំលៃហានិភ័យឥណទានរបស់ Group និងវិភាគលើកាអនុវត្តន៍រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរបស់សហគ្រាសដែលមានលក្ខណៈទូលំទូលាយ និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យដ៏រឹងមាំ។

  ដោយគោរពទៅតាមបទបញ្ញត្តិផ្សេងៗ  និងការអនុវត្តន៍គំរូក្នុងវិស័យនេះ  ធនាគារប្រកាន់ខ្ជាប់តាមគោលការណ៍នៃការចាត់ទុកការគ្រប់គ្រងហានិភ័យ ជាការទទួលខុសត្រូវស្នូលរបស់ផ្នែកអាជីវកម្ម និងផ្នែកប្រតិបត្តិការនីមួយៗ។ ជំហរនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ និងចងក្រងទុកជាឯកសារនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរបស់ធនាគារ។

  ដើម្បីគាំទ្រនិងលើកកម្ពស់គណនេយ្យភាព      និងកម្មសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ      រចនាសម្ព័ន្ធស្វ័យវង្វាយតម្លៃលើការត្រួតពិនិត្យនិងហានិភ័យមួយ ត្រូវបានអនុវត្តនៅគ្រប់ផ្នែកប្រតិបត្តិការ សំខាន់ៗរបស់ធនាគារ ដែលជាផ្នែកមួយនៃដំណើរការគ្រប់គ្រងហានិភ័យ។ ផ្នែកទាំងនេះត្រូវបានតម្រូវឲ្យកំណត់  និងកត់ត្រាទុកជាឯកសារនូវការត្រួតពិនិត្យ  និងដំណើរការនៃការគ្រប់គ្រងហានិភ័យ  ដែលកើតមានឡើងពីសកម្មភាពអាជីវកម្មនានា ក៏ដូចជាវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង      ហានិភ័យ ដើម្បីធានាឲ្យប្រាកដថាហានិភ័យដែលបានកំណត់ត្រូវបានគ្រប់គ្រងនិងកាត់បន្ថយយ៉ាងត្រឹមត្រូវ។

- **ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង**
  ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារដែលរួមមាន គោលនយោបាយ នីតិវិធី ដំណើរការ រចនា  សម្ព័ន្ធគ្រប់គ្រង ភារកិច្ច និងផ្នែកត្រួតពិនិត្យផ្សេងៗទៀតត្រូវបានអនុវត្តដើម្បីធានាឲ្យបាននូវការសម្រេចគោលដៅរបស់ធនាគារប្រកបដោយប្រសិទ្ធភាព    និងប្រសិទ្ធផលប្រតិបត្តិការរបាយការណ៍ហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន និងការអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយផ្សេងៗទៀត។

## សកម្មភាព និងបរិយាកាសត្រួតពិនិត្យ

- **រចនាសម្ព័ន្ធគ្រប់គ្រង**
  ធនាគារមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់  ដោយមានការកំណត់យ៉ាងជាក់លាក់នូវគណនេយ្យភាព និងភាពទំនួលខុសត្រូវ និងបណ្តាញនៃការរាយការណ៍។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារផ្តល់ឲ្យយើងនូវគោលការណ៍ជាមូលដ្ឋាន  សម្រាប់ជាជំនួយដល់ប្រតិបត្តិការរបស់ធនាគារដើម្បីដំណើរការឲ្យបានរលូននិងត្រឹមត្រូវ ក៏ដូចជាចង្អុលបង្ហាញពីរយៈពេលនៃការត្រួតពិនិត្យដើម្បីធានាឲ្យបាននូវការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើប្រតិបត្តិការប្រចាំថ្ងៃ។

- **គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង**
  គោលនយោបាយ  នីតិវិធី  និងដំណើរការនៃអភិបាលកិច្ចអាជីវកម្ម  និងប្រតិបត្តិការរបស់ធនាគារ  ត្រូវចងក្រងទុកជាឯកសារ  និងផ្សព្វផ្សាយក្នុង Group ទាំងមូល   ហើយរាល់បុគ្គលិកទាំងអស់អាចមើលបានតាមរយៈឯកសារដែលបានរក្សាទុកក្នុងកុំព្យូទ័ររបស់ធនាគារ។ គោលនយោបាយ នីតិវិធី  និងដំណើរការទាំងនេះ  ត្រូវបានត្រួតពិនិត្យឡើងវិញ  និងធ្វើបច្ចុប្បន្នកម្មទៅតាមផ្នែកអាជីវកម្ម  និងប្រតិបត្តិការ  តាមរយៈដំណើរការត្រួតពិនិត្យឡើងវិញជាប្រព័ន្ធ  ដើម្បីបត់បែនទៅតាមការផ្លាស់ប្តូររបស់ច្បាប់  និងបទបញ្ញត្តិនានា  ក៏ដូចជាការផ្លាស់ប្តូរនៃបរិបទអាជីវកម្មនិងប្រតិបត្តិការ។ ជាងនេះទៅទៀត ការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយ នីតិវិធី និងដំណើរការ ត្រូវបានធ្វើផងដែរក្នុងការធ្វើឲ្យប្រាកដថាមានការត្រួតពិនិត្យត្រឹមត្រូវក្នុងការគ្រប់គ្រងហានិភ័យ ដែលកើតមានក្នុងអាជីវកម្ម និងប្រតិបត្តិការ។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

**សកម្មភាព និងបរិយាកាសត្រួតពិនិត្យ (ត)**

- **កម្រិតនៃសិទ្ធិអំណាច**
  ការផ្ទេរសិទ្ធិអំណាច រួមមានកម្រិតនៃអំណាចនៅគ្រប់ជាន់ថ្នាក់របស់គណៈគ្រប់គ្រងក្នុងធនាគារ ត្រូវបានកត់ត្រាទុក និងរៀបចំឡើងដើម្បីធានានូវគណនេយ្យភាព និងការទទួលខុសត្រូវ។

- **សុវត្ថិភាពព័ត៌មានវិទ្យា**
  គោលបំណងរបស់សុវត្ថិភាពព័ត៌មានវិទ្យា គឺដើម្បីការពារដល់កម្មវិធី ទិន្នន័យ ព័ត៌មាន ដែលបានរក្សាទុក ព្រមទាំងការពារប្រព័ន្ធកុំព្យូទ័រកុំឲ្យមានការចូលទៅយក ឬការបញ្ចូលព័ត៌មាន និងប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការបំផ្លិចបំផ្លាញក៏ដូចជាការពារភាពជឿទុកចិត្តបាន និងភាពអាចប្រើប្រាស់បានជាបន្តបន្ទាប់នៃប្រព័ន្ធនេះ។

  បរិក្ខារកុំព្យូទ័រ និងព័ត៌មានក្នុងទម្រង់ផ្សេងៗត្រូវបានផ្តល់ឲ្យបុគ្គលិកធនាគារ និងភាគីទីបីដែលពាក់ព័ន្ធដើម្បីជួយសម្រួលដល់ការបំពេញភារកិច្ចរបស់ពួកគេ។ ទ្រព្យសម្បត្តិទាំងនេះ ដោយអាស្រ័យទៅតាមតម្លៃ និងកម្រិតប្រឈមហានិភ័យរបស់វា គឺត្រូវមានការត្រួតពិនិត្យដើម្បីការពារកុំឲ្យមានការបាត់បង់ជាយថាហេតុ ឬដោយចេតនា ឬការចូលទៅប្រើប្រាស់ កែសម្រួល ចាត់ចែង និងចែករំលែកដោយគ្មានអនុញ្ញាត។

  សុវត្ថិភាពព័ត៌មានវិទ្យាការពារព័ត៌មានពីការគំរាមកំហែងជាច្រើន ក៏ដូចជាការរក្សាការសម្ងាត់ សច្ចៈភាព និងភាពដែលអាចប្រើប្រាស់បានរបស់ព័ត៌មាន។ សុវត្ថិភាពព័ត៌មានវិទ្យារបស់ធនាគារអាចសំរេចទៅបាន តាមរយៈការអនុវត្តនៃប្រព័ន្ធត្រួតពិនិត្យ ដែលរួមមានដូចជា គោលនយោបាយ ស្តង់ដារ នីតិវិធី គោលការណ៍ណែនាំ រចនាសម្ព័ន្ធរបស់អង្គភាព និងកម្មវិធីត្រួតពិនិត្យ Software។

- **ដំណើរការនៃគម្រោងថវិកា**
  ដំណើរការដ៏រឹងមាំក្នុងការបែងចែកគម្រោងថវិកាត្រូវបានរៀបចំឡើង ដោយតម្រូវឲ្យផ្នែកប្រតិបត្តិការសំខាន់ៗនៅក្នុងធនាគារធ្វើការរៀបចំគម្រោងថវិកា និងផែនការអាជីវកម្មប្រចាំឆ្នាំដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។ គម្រោងថវិកា និងផែនការអាជីវកម្មរបស់ធនាគាររួមទាំងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រផ្អែកទៅតាម កម្រិតហានិភ័យដែលអាចទទួលយកបាន ត្រូវបានលើកយកទៅពិភាក្សាយ៉ាងល្អិតល្អន់នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ជាពេលដែលផែនការរៀបចំថវិការបស់ធនាគារត្រូវបានបង្ហាញ។

- **ការគ្រប់គ្រងធនធានមនុស្ស**
  ធនាគារបានទទួលស្គាល់ថាគន្លឹះសំខាន់ ដែលគួបផ្សំនឹងប្រព័ន្ធគោលនយោបាយផ្សេងៗគឺធនធានមនុស្ស ហើយប្រព័ន្ធគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង គឺពឹងផ្អែកលើការទទួលខុសត្រូវ សុចរិតភាព និងការវិនិច្ឆ័យរបស់បុគ្គលិកដែលអនុវត្តក្នុងការងារ។ ដូច្នេះហើយ ធនាគារមានគោលនយោបាយ និងនីតិវិធីដែលគ្រប់គ្រងលើការជ្រើសរើស ការតែងតាំង ការអនុវត្តការងារ ការគ្រប់គ្រង ការតបស្នង និងការផ្តល់រង្វាន់ ក៏ដូចជាគោលនយោបាយ និងនីតិវិធីដែលណែនាំពីការគោរពវិន័យ ការបញ្ឈប់ការងារ និងការបណ្តេញចេញ។

  ដើម្បីឲ្យមានការលូតលាស់ប្រកបដោយចីរភាព ធនាគារសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍ធនធានមនុស្ស ការគ្រប់គ្រងទេពកោសល្យ និងការរៀបចំផែនការបន្តវេន។ ដើម្បីបង្កើនសមត្ថភាពបុគ្គលិក ការបង្ហាត់បង្រៀនលើផ្នែកបច្ចេកទេសជាលក្ខណៈប្រព័ន្ធ ព្រមទាំងជំនាញលើភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ត្រូវបានផ្តល់ទៅបុគ្គលិកទៅតាមសេចក្តីត្រូវការរបស់ពួកគេនៅអំឡុងពេលវាយតម្លៃលទ្ធផលការងារ ប្រចាំឆ្នាំ។ ចំពោះការគ្រប់គ្រងអ្នកមានទេព្យកោសល្យ គំនិតផ្តួចផ្តើមដូចជាកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំ ផែនការសម្រាប់អភិវឌ្ឍន៍ខ្លួន និងការណែនាំក៏ត្រូវបានអនុត្តន៍ផងដែរ ដើម្បីធ្វើឲ្យអ្នកដែលមានទេព្យកោលសល្យ ដែលបានកំណត់មានការលូតលាស់នៅក្នុងធនាគារ ដើម្បីជួយជំរុញឲ្យមានអ្នកបន្តវេណដែលស័ក្តសម និងមានសក្តានុពលខ្ពស់សម្រាប់កាន់តំណែងដឹកនាំផ្សេងៗទៅថ្ងៃអនាគត។

- **ក្រមសីលធម៌**
  ក្រមសីលធម៌របស់ធនាគារកំណត់នូវលក្ខណៈស្តង់ដារ លើការអនុវត្តដែលមានភាពល្អប្រសើរ និងមានក្រមសីលធម៌ព្រមទាំងមានគោលបំណងសម្រាប់ការថែរក្សាការជឿជាក់លើសុវត្ថិភាពនិងសុចរិតភាពនៃការអនុវត្តន៍អាជីវកម្មរបស់ធនាគារ។ គ្រប់បុគ្គលិកទាំងអស់របស់ធនាគារតម្រូវឲ្យយល់ដឹង និងប្រតិបត្តិតាមក្រមសីលធម៌។ បុគ្គលិកដែលចូលថ្មីត្រូវបានទទួលការណែនាំពីក្រមសីលធម៌ និងតម្រូវឲ្យចុះហត្ថលេខាលើទម្រង់ស្តីពីការគោរពតាមបទបញ្ញត្តិផ្សេងៗនៅពេលដែលក្លាយជាបុគ្គលិកធនាគារ។

## សកម្មភាព និងបរិយាកាសត្រួតពិនិត្យ (ត)

- **ក្រុមសីលធម៌** (ត)
  ធនាគារក៏បានបង្កើតឲ្យមាននូវគោលការណ៍ណែនាំស្តីពីកាផ្តល់រង្វាន់និងបដិសណ្ឋារកិច្ចផងដែរដើម្បីលើកកម្ពស់សុចរិតភាពនិងតម្លាភាពសម្រាប់ការផ្តល់ឲ្យ និងការទទួលនូវរង្វាន់។ គោលការណ៍ណែនាំភ្ជាប់មកជាមួយមួយទៀតត្រូវបានរៀបចំឡើងសម្រាប់ជាជំនួយដល់ធនាគារ និងបុគ្គលិក ដើម្បីឲ្យយល់អំពីកាតព្វកិច្ចរបស់ភាគីនីមួយៗក្នុងការលើកកម្ពស់សុចរិតភាពក្នុងការផ្តល់រង្វាន់។

- **គោលនយោបាយគ្រប់គ្រងហានិភ័យនៃការឆបោក**
  គោលនយោបាយគ្រប់គ្រងហានិភ័យនៃការឆបោកនេះត្រូវបានបង្កើតឡើងមក ដើម្បីលើកកម្ពស់សង្គតភាពនៃឥរិយាបទក្នុងអង្គភាពតាមរយៈការអភិវឌ្ឍន៍ ការអនុវត្ត និង ការត្រួតពិនិត្យឲ្យបានទៀងទាត់ទៅលើការទប់ស្កាត់ ការកំណត់ឲ្យបាននូវអំពើឆបោក និងយុទ្ធសាស្រ្តសម្រាប់ទប់ទល់ទៅនឹងអំពើឆបោកនោះ។ គោលនយោបាយនេះចែងយ៉ាងច្បាស់ពីចំណុចស្នូលនៃគោលការណ៍ គ្រប់គ្រងអំពើឆបោកជាមួយធនាគារដែលរួមមានភាពជាអ្នកដឹកនាំនិងក្រុមសីលធម៌ ការយល់ដឹងពីការឆបោក ការកំណត់ឲ្យបាននូវអំពើបោក ការរាយការណ៍ និងបញ្ជូនបន្ត រួមទាំងការតបតទៅនឹងអំពើបោកជាមួយនឹងសកម្មភាពកែតម្រូវយ៉ាងសមរម្យ។

- **ផែនការប្រមូលទិន្នន័យមកវិញក្នុងករណីគ្រោះមហន្តរាយ និងផែនការបន្តនិរន្តរភាពអាជីវកម្ម**
  ធនាគារទទួលស្គាល់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីផ្តល់ជូននូវសេវាដែលចាំបាច់ទៅអតិថិជនឲ្យបានជានិរន្តនិងធានាឲ្យបាននូវសុវត្ថិភាពសម្រាប់បុគ្គលិកថែទាំទ្រព្យសម្បត្តិ និងទិន្នន័យ និងការពារឲ្យបានរឹងមាំនូវផលប្រយោជន៍របស់បុគ្គលពាក់ព័ន្ធសំខាន់ៗដែលធានាឲ្យបាននូវភាពជោគជ័យរបស់អង្គភាព។ កម្មវិធីការគ្រប់គ្រងការបន្តអាជីវកម្មរបស់ធនាគារគឺផ្អែកលើប្រតិបត្តិនៃការបន្តនិរន្តរភាពអាជីវកម្មដ៏ល្អ និងគោលការណ៍អនុវត្តស្របទៅតាមបទដ្ឋានរបស់ Group និងបទដ្ឋានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។

  ធនាគារកំពុងបន្តគ្រប់គ្រងកម្មវិធីបន្តនិរន្តរភាពអាជីវកម្មរបស់ធនាគារ ដែលរួមបញ្ចូលនូវការគ្រប់គ្រងវិបត្តិឲ្យមានប្រសិទ្ធភាពដើម្បីទប់ទល់ទៅនឹងវិបត្តិជាក់ស្តែង។ ផែនការក្នុងការបន្តនិរន្តរភាពអាជីវកម្មនិងផែនការប្រមូលទិន្នន័យមកវិញពីគ្រោះមហន្តរាយ គឺស្ថិតនៅក្រោមការធ្វើតេស្តសាកល្បង និងការហ្វឹកហាត់ជាប្រចាំ ដើម្បីធានាដល់ប្រសិទ្ធផល ភាពដែលអាចជឿទុកចិត្តបាន និងភាពដំណើរការរបស់វា។ ការសាកល្បង និងហ្វឹកហាត់ឲ្យដូចភាពជាក់ស្តែងត្រូវបានធ្វើឡើងដើម្បីឲ្យបុគ្គលិកមានភាពស៊ាំ និងក៏ដូចជាធ្វើឲ្យបុគ្គលិកមានជំនាញ និងវិធីសាស្រ្តដែលតម្រូវឲ្យមានសម្រាប់ការកំណត់ វាយតម្លៃ ទប់ទល់ និងដោះស្រាយហេតុការណ៍ធ្ងន់ធ្ងរណាមួយបាន។

## ព័ត៌មាន និងទំនាក់ទំនង

- **ការត្រួតពិនិត្យឡើងវិញលើលទ្ធផល**
  ព័ត៌មានយ៉ាងទៀងទាត់ និងលម្អិតត្រូវបានផ្តល់ឲ្យដោយគណៈគ្រប់គ្រងក្នុងការតាមដានលើលទ្ធផលជាក់ស្តែង ដោយធៀបនឹងផែនការយុទ្ធសាស្រ្តអាជីវកម្ម និងការបែងចែកហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ ព័ត៌មានទាំងនេះរួមមានសូចនាករហិរញ្ញវត្ថុនិងប្រតិ-បត្តិការសំខាន់ៗទាំងឡាយ ព្រមទាំងការផ្តួចផ្តើមយុទ្ធសាស្រ្តសំខាន់ៗ ដែលបានអនុវត្តដោយធនាគារនៅក្នុងការិយបរិច្ឆេទ។

  គណៈកម្មាការគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល ទទួល និងត្រួតពិនិត្យឡើងវិញនូវរបាយការណ៍លទ្ធផលហិរញ្ញវត្ថុជារៀងរាល់ខែ និងត្រីមាសដើម្បីធៀបនឹងគោលដៅដែលកំណត់ទុកជាមុន និង មូលហេតុនៃភាពខុសឆ្គងមួយចំនួនដើម្បីធ្វើការវាស់វែង ដែលអាចសម្រេចឲ្យបានដល់គោលដៅដែលបានកំណត់ទុក។

- **គោលនយោបាយរាយការណ៍ដោយសម្ងាត់** (Whistle Blower Policy)
  ធនាគារបានរៀបចំឡើងនូវដំណើរការនៃការរាយការណ៍ពីបុគ្គលណាដែលត្រូវបានរកឃើញថាបានបំពាន ឬវៀរចាកពីដំណើរការ និងការត្រួតពិនិត្យរបស់ធនាគារ។ បុគ្គលិកទាំងអស់ត្រូវបាន ផ្តល់ឱកាសឲ្យធ្វើការរាយការណ៍ តាមរយៈយន្តការរាយការណ៍ជាសម្ងាត់ដោយមានការអះអាងថាការរាយការណ៍នេះត្រូវរក្សាទុកជាការសម្ងាត់ ហើយអត្តសញ្ញាណរបស់អ្នករាយការណ៍ត្រូវបានការពារ។

# របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំ (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

## ព័ត៌មាន និងទំនាក់ទំនង (ត)

- **រចនាសម្ព័ន្ធនៃការគ្រប់គ្រងឧប្បត្តិហេតុ**
  ដើម្បីបំពេញបន្ថែមលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រព័ន្ធរាយការណ៍ឧប្បត្តិហេតុដែលមានលក្ខណៈទូលំទូលាយមួយត្រូវបានអនុវត្ត ដើម្បីធានាឲ្យប្រាកដថាមានការរាយការណ៍ និងគ្រប់គ្រងឧប្បត្តិហេតុបានត្រឹមត្រូវ។ ប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុក៏ធានាឲ្យបានថាគ្រប់ឧប្បត្តិហេតុណាដែលបង្កឲ្យមានជាហានិភ័យនិងការខាតបង់ជាសារវ័ន្ត ត្រូវបានរាយការណ៍យ៉ាងឆាប់រហ័សទៅដល់គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលជាមួយនឹងវិធានការចាំបាច់ដែលបានអនុវត្តដើម្បីកាត់បន្ថយហានិភ័យចម្បងៗដែលនឹងអាចកើតមានឡើង។ ទាំងនេះអាចឲ្យអ្នកមានធ្វើសេចក្ដីសម្រេចចិត្តធ្វើការសម្រេចចិត្តបានត្រឹមត្រូវ និងយល់ដឹងពីស្ថានភាពថ្មីៗ ព្រមទាំងគ្រប់គ្រងហានិភ័យដោយមានប្រសិទ្ធភាព។

## រចនាសម្ព័ន្ធប្រតិបត្តិ

- **គណៈកម្មការក្រុមប្រឹក្សាភិបាល**
  ក្រុមប្រឹក្សាភិបាល បានចាត់តាំងការទទួលខុសត្រូវជាក់លាក់ទៅកាន់គណៈកម្មការក្រុមប្រឹក្សាភិបាលដែលត្រូវបានបង្កើតឡើងក្នុងធនាគារមានដូចជា គណៈកម្មការគ្រប់គ្រងហានិភ័យ គណៈកម្មការសវនកម្ម គណៈកម្មការជ្រើសតាំងនិងវាយតម្លៃ។

  គណៈក្រុមប្រឹក្សាភិបាលត្រូវបានទទួលភារកិច្ចជាក់លាក់ក្នុងការពិនិត្យមើល និងពិចារណាទៅលើគ្រប់បញ្ហាទាំងអស់នៅក្នុងព្រំដែននៃទំនួលខុសត្រូវ ដែលមានចែងនិងមានសំអិតសំអាងយ៉ាងច្បាស់លាស់។

- **គណៈកម្មការគ្រប់គ្រង**
  គណៈកម្មការគ្រប់គ្រងមានសមាសភាពសមាជិកជាគណៈគ្រប់គ្រងសំខាន់ៗរបស់ធនាគារ ហើយ មានអគ្គនាយកគ្រប់គ្រង/ប្រធានប្រចាំប្រទេសជាប្រធាន។ គណៈកម្មការគ្រប់គ្រងបានផ្ដល់ឱកាសដល់គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ពិភាក្សាលើបញ្ហាយុទ្ធសាស្ត្រដែលប៉ះពាល់ដល់ចក្ខុវិស័យ ទិសដៅយុទ្ធសាស្ត្រ ការរួបរួមអាជីវកម្ម និងតម្លៃនៃកេរ្តិ៍ឈ្មោះ ក៏ដូចជាផែនទីបង្ហាញផ្លូវជាយុទ្ធសាស្ត្ររបស់ធនាគារ។ គណៈកម្មការគ្រប់គ្រងជួបប្រជុំជារៀងរាល់ខែ ហើយកំណត់ហេតុអង្គប្រជុំត្រូវបានលើកឡើងដល់ក្រុមប្រឹក្សាពាណិជ្ជកម្មអន្តរជាតិរបស់ហ្គ្រុប (Group International Business Council) និងក្រុមប្រឹក្សាភិបាលរបស់ធនាគារឲ្យបានជ្រាបជាព័ត៌មាន។

- **តួនាទីប្រតិបត្តិ**
  តួនាទីប្រតិបត្តិ គឺជាការទទួលខុសត្រូវរួមរបស់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងជាន់ខ្ពស់ ព្រមទាំងបុគ្គលិកទាំងអស់របស់ធនាគារ។ ដូច្នេះមានការរំពឹងទុកថា បុគ្គលពាក់ព័ន្ធនឹងលើកតម្កើងការគោរពបទប្បញ្ញត្តិ និងទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ហើយទន្ទឹមនឹងនេះត្រូវគោរពក្រមសីលធម៌ និងរក្សាឥរិយាបថឲ្យបានត្រឹមត្រូវចំពោះរាល់ទង្វើរបស់ខ្លួន។

  គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារគាំទ្រគណៈក្រុមប្រឹក្សាភិបាល និងគណៈកម្មការគ្រប់គ្រងហានិភ័យក្នុងការគ្រប់គ្រងហានិភ័យខាងផ្នែកប្រតិបត្តិរបស់ធនាគារ និងធានាឲ្យបានថាមានកម្មវិធីប្រតិបត្តិជាស្រេច និងមានការពិនិត្យឲ្យបានទៀងទាត់ទៅលើភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃកម្មវិធីទាំងនេះក្នុងការគ្រប់គ្រងហានិភ័យខាងផ្នែកប្រតិបត្តិ។ បន្ថែមលើនេះទៀត គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារបាបង្កើតឲ្យមាននូវតួនាទីប្រតិបត្តិមួយនៅលំដាប់ធនាគារ ដែលមានឯករាជ្យភាពក្នុងការធ្វើទំនាក់ទំនងផ្ទាល់ទៅគណកម្មការគ្រប់គ្រងហានិភ័យនិងក្រុមប្រឹក្សាភិបាល។ ប្រធានការិយាល័យប្រតិបត្តិជាអ្នកត្រួតត្រាលើការគ្រប់គ្រងទាំងអស់លើផ្នែកប្រតិបត្តិរបស់ធនាគារ។

  ដើម្បីជំរុញដល់ការយល់ដឹងពីគោលការណ៍ណែនាំ និងច្បាប់នានាដែលនាំឲ្យការប្រតិបត្តិបានខ្ជាប់ខ្ជួននោះ ការិយាល័យផ្នែកប្រតិបត្តិក៏បានរៀបចំនូវការជួបជុំគ្នាជាមួយគ្រប់ផ្នែកដែលពាក់ព័ន្ធ និងបង្ហាត់បង្រៀននូវចំណុចជាចាំបាច់ដែលត្រូវបំពេញឲ្យត្រឹមត្រូវតាមច្បាប់ និងគោលការណ៍ណែនាំទាំងឡាយ។

## រចនាសម្ព័ន្ធប្រតិបត្តិ (ត)

- **តួនាទីសវនកម្មផ្ទៃក្នុង**
  តួនាទីសវនកម្មផ្ទៃក្នុងគឺជាជំនួយដល់ក្រុមប្រឹក្សាភិបាល និងគណៈកម្មការសវនកម្មដោយផ្តល់ឲ្យនូវឯករាជ្យភាព និងភាពប្រាកដប្រជានៃគោលដៅដែលគ្រប់គ្រាន់សម្រាប់ប្រសិទ្ធភាពនៃការរចនា និងប្រតិបត្តិការរបស់រចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរបស់ធនាគារ ដំណើរការនៃការត្រួតពិនិត្យ និងការគ្រប់គ្រងដែលបានអនុវត្តក្នុងធនាគារទាំងមូល។

  ផែនការសវនកម្មផ្ទៃក្នុងត្រូវបានធ្វើឡើង ដោយផ្អែកតាមវិធីសាស្ត្រជ្រើសរើសហានិភ័យជាគោលនិងត្រូវបានអនុម័តដោយគណៈកម្មការសវនកម្មជារៀងរាល់ឆ្នាំ។ របាយការណ៍សវនកម្មដែលរួមមានលទ្ធផលសំខាន់ៗ បានដាក់ចេញនូវអនុសាសន៍ដើម្បីការធ្វើការកែលម្អហើយការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះអនុសាសន៍ទាំងនោះ ត្រូវបានលើកយកទៅធ្វើជាប្រធានបទក្នុងការប្រជុំគណៈគ្រប់គ្រង និងគណៈកម្មការសវនកម្មជារៀងរាល់ខែ និងត្រីមាសផងដែរ។

  ប្រធានសវនកម្មផ្ទៃក្នុងធ្វើការរាយការណ៍តាមតួនាទីទៅផ្នែកសវនកម្មផ្ទៃក្នុងរបស់ Group និងរាយការណ៍ជាលក្ខណៈរដ្ឋបាលទៅនាយកគ្រប់គ្រងដើម្បីធានានូវឯករាជ្យភាពរបស់សវនកម្មផ្ទៃក្នុងពីគណៈគ្រប់គ្រង។

  គណៈកម្មការសវនកម្មជួបប្រជុំយ៉ាងទៀងទាត់ដើម្បីពិភាក្សាលើគំហើញនិងអនុសាសន៍នានាសម្រាប់ការកែលម្អលើចំណុចដែលបានលើកឡើងដោយសវនករផ្ទៃក្នុង និងសវនករឯករាជ្យ ក៏ដូចជាអាជ្ញាធរនិយ័តករនានាអំពីស្ថានភាពនៃប្រព័ន្ធផ្ទៃក្នុងរបស់ធនាគារ។ កំណត់ហេតុអង្គប្រជុំរបស់គណៈកម្មការសវនកម្មត្រូវបានលើកឡើងដល់ក្រុមប្រឹក្សាភិបាលឲ្យបានជ្រាបដែលរាល់ការលើកឡើងរបស់គណៈកម្មការសវនកម្មត្រូវបានជម្រាបដល់ក្រុមប្រឹក្សាភិបាលនីមួយៗដោយប្រធានគណៈកម្មការសវនកម្ម។

  សកម្មភាពលម្អិតរបស់គណៈកម្មការសវនកម្ម ត្រូវបានរៀបរាប់នៅក្នុងរបាយការណ៍របស់គណៈកម្មការសវនកម្មក្នុងឧបសម្ព័ន្ធ ។

- **ជំលោះផលប្រយោជន៍**
  ធនាគារបានរៀបចំការបែងចែកតួនាទី និងការបង្ការជំលោះផលប្រយោជន៍យ៉ាងមានប្រសិទ្ធភាពតាមរយៈការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់ឡើងវិញ នូវសកម្មភាពនានា ដោយឯករាជ្យដើម្បីបង្ការកុំឲ្យមានកំហុសឆ្គងដោយអចេតនា ការឆបោក និងការបំពានផ្សេងៗ។

- **ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម**
  កម្មវិធីការប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញជាបន្តបន្ទាប់ និងធ្វើបច្ចុប្បន្នកម្មដើម្បីគោរពទៅតាមបទបញ្ញត្តិនានា ក៏ដូចជាដើម្បីប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ គ្រប់បុគ្គលិកទាំងអស់ត្រូវបានរំពឹងថានឹងបំពេញតួនាទីរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងវិជ្ជាជីវៈខ្ពស់ អនុលោមទៅតាមកម្មវិធីប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងដើម្បីឲ្យមានការប្រុងប្រយ័ត្នក្នុងការពារកុំឲ្យធនាគារត្រូវបានគេប្រើប្រាស់ដើម្បីសម្អាតប្រាក់ ឬផ្តល់ហិរញ្ញប្បទានដល់សកម្មភាពល្មើសច្បាប់នានារួមមានហិរញ្ញប្បទានភេរវកម្មជាដើម។

  គណៈក្រុមប្រឹក្សាភិបាលមានជំនឿថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារមានលក្ខណៈគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ដោយពុំមានបញ្ហាចោទណាមួយគួរឲ្យកត់សម្គាល់ នៅក្នុងកំឡុងពេលត្រួតពិនិត្យនេះឡើយ។

# សកម្មភាពរបស់គណៈកម្មការសវនកម្ម និងមុខងារសវនកម្មផ្ទៃក្នុង (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

### សកម្មភាពរបស់គណៈកម្មការសវនកម្ម

ការជួបប្រជុំគណៈកម្មការសវនកម្មមានចំនួន 4 លើក ដែលត្រូវបានរៀបចំឡើងក្នុង ការិយបរិច្ឆេទ 31 ធ្នូ 2016។ សមាជិករបស់គណៈកម្មការ និងវត្តមានក្នុងការចូលរួមប្រជុំក្នុង ការិយបរិច្ឆេទមានដូចខាងក្រោម៖

| សមាជិករបស់គណៈកម្មការសវនកម្ម | វត្តមានក្នុងការចូលរួមប្រជុំ |
|---|---|
| 1. Chulapong Yukate<br>(ប្រធានគណៈកម្មការ/អភិបាលឯករាជ្យ និងជាអភិបាលមិនប្រតិបត្តិ) | 4/4 (100%) |
| 2. Foo San Kan<br>(សមាជិក/អភិបាលឯករាជ្យ និងជាអភិបាលមិនប្រតិបត្តិ) លាលែងពីដំណែងនាថ្ងៃទី20 ខែធ្នូ ឆ្នាំ2016 | 4/4 (100%) |
| 3. Leong Yengkit<br>(សមាជិក/អភិបាលឯករាជ្យ និងជាអភិបាលមិនប្រតិបត្តិ) លាលែងពីដំណែងនាថ្ងៃទី20 ខែធ្នូ ឆ្នាំ2016 | 4/4 (100%) |
| 4. Ong Seng Pheow<br>(សមាជិក/អភិបាលឯករាជ្យ និងជាអភិបាលមិនប្រតិបត្តិ) លាលែងពីដំណែងនាថ្ងៃទីថ្ងៃទី20 ខែធ្នូ ឆ្នាំ2016 | N/A |
| 5. Encik Abdul Aziz Peru Mohamed<br>(សមាជិក/អភិបាលឯករាជ្យ និងជាអភិបាលមិនប្រតិបត្តិ) លាលែងពីដំណែងនាថ្ងៃទីថ្ងៃទី20 ខែធ្នូ ឆ្នាំ2016 | N/A |

### កំនត់ចំណាំ:

សកម្មភាពសំខាន់ៗរបស់គណៈកម្មការសវនកម្មក្នុងការិយបរិច្ឆេទត្រូវបានសង្ខេបដូចខាងក្រោម៖

- ត្រួតពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ដែលមិនត្រូវបានធ្វើសវនកម្ម និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួចរាល់របស់ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា លីមីធីត មុនពេលអនុម័តដោយក្រុមប្រឹក្សាភិបាល។
- ត្រួតពិនិត្យឡើងវិញលើផែនការសវនកម្មរបស់សវនករខាងក្រៅ យុទ្ធសាស្ត្រនៃការធ្វើ សវនកម្ម ការថ្លឹងថ្លែងហានិភ័យ និងដែនកំណត់នៃការធ្វើសវនកម្មសំរាប់ការិយបរិច្ឆេទ ហិរញ្ញវត្ថុប្រចាំឆ្នាំ។
- ត្រួតពិនិត្យឡើងវិញជាមួយសវនករខាងក្រៅ អំពីលទ្ធផលពីការធ្វើសវនកម្មប្រចាំឆ្នាំ និងរបាយការណ៍គណៈកម្មការសវនកម្ម រួមទាំងការឆ្លើយតបរបស់គណៈគ្រប់គ្រងទៅនឹង គំហើញ និងអនុសាសន៍លើកឡើងដោយសវនករខាងក្រៅ។
- ត្រួតពិនិត្យឡើងវិញទៅលើសេវាកម្មនានា ក្រៅពីសេវាសវនកម្មដែលផ្តល់ដោយសវនករ ខាងក្រៅ និងការពិចារណាលើថ្លៃឈ្នួលសេវាកម្មដែលពាក់ព័ន្ធ ដើម្បីឲ្យប្រាកដថាថ្លៃឈ្នួល សេវាកម្មដែលបាន កំណត់ស្ថិតក្នុងគោលនយោបាយរបស់ធនាគារ។
- វាយតម្លៃការបំពេញការងាររបស់សវនករខាងក្រៅ ហើយផ្តល់អនុសាសន៍សំខាន់ៗជូន ក្រុមប្រឹក្សាភិបាល ដើម្បីពិចារណាក្នុងការតែងតាំងសវនករខាងក្រៅ និងថ្លៃឈ្នួលសេវា សវនកម្ម។
- ត្រួតពិនិត្យឡើងវិញ និងអនុម័តលើផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង ដើម្បីធានា លើភាពគ្រប់គ្រាន់នៃដែនកំណត់ និងវិសាលភាពក្នុងការធ្វើសវនកម្ម ព្រមទាំងតម្រូវការ សវនករផ្ទៃក្នុង។

**កំនត់ចំណាំ:** ( **ត** )

- ត្រួតពិនិត្យលើរបាយការណ៍សវនកម្មផ្ទៃក្នុង អនុសាសន៍របស់សវនករផ្ទៃក្នុង និងការ ឆ្លើយតបរបស់គណៈគ្រប់គ្រង ក៏ដូចជាសកម្មភាពនានា ដែលត្រូវអនុវត្តដើម្បីកែលំអប្រព័ន្ធ ត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធី ព្រមទាំងស្ថានភាពនៃការបញ្ចប់ផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង។
- ត្រួតពិនិត្យឡើងវិញលើប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ ដែលបានធ្វើឡើងក្នុងធនាគារ។
- ដាក់ជូននូវរបាយការណ៍ប្រជុំគណៈកម្មការសវនកម្ម ដល់ក្រុមប្រឹក្សាភិបាលដើម្បីឲ្យបាន ជ្រាប និងសំរាប់ការណែនាំបន្ថែមពីក្រុមប្រឹក្សាភិបាលក្នុងករណីចាំបាច់។

សមាជិកគណៈកម្មការសវនកម្ម បានចូលរួមវគ្គបណ្តុះបណ្តាល សន្និសិទ និងសិក្ខាសាលា ក្នុងអំឡុង ការិយបរិច្ឆេទឆ្នាំ 2015មានដូចជា៖

- Corporate Governance for Capital Market Intermediaries
- Trans-Pacific Partnership Agreement (TPPA) for Board of Directors & Senior Management
- Digital Signature Training To RHB Board of Directors
- Malaysian Financial Reporting Standard 9 – Financial Instruments for RHB Banking Group Directors
- FIDE FORUM Dialogue on Directors´ and Officer Liability Insurance
- Mandatory Accreditation Programme For Directors Of Public Listed Companies
- Anti-Money Laundering/Counter Financing of Terrorism for RHB Banking Group BODs & GMCs and Heads
- New Companies Act 2016

## មុខងារសវនកម្មផ្ទៃក្នុង

ធនាគារបានបង្កើតឡើងនូវនាយកដ្ឋានសវនកម្មផ្ទៃក្នុងដែលប្រតិបត្តិតាម Internal Audit Charter ហើយរាយការណ៍ជូនគណៈកម្មការសវនកម្ម។ តួនាទីចំបងរបស់សវនកម្មផ្ទៃក្នុង គឺជួយគណៈកម្មការសវនកម្មក្នុងការបំពេញតួនាទី និងភារកិច្ច តាមរយៈការត្រួតពិនិត្យឡើងវិញដោយឯករាជ្យ និងរាយការណ៍ពីភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ការត្រួត-ពិនិត្យផ្ទៃក្នុង និងដំណើរការអភិបាលកិច្ច។

គណៈកម្មការអនុម័តលើផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង នៅរៀងរាល់ដើមការិយបរិច្ឆេទ នីមួយៗ។ សវនកម្មផ្ទៃក្នុងបានផ្អែកលើការថ្លឹងថ្លែងហានិភ័យ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំ ផែនការ និងការធ្វើ សវនកម្ម ដែលស្របគ្នាទៅនឹងរចនាសម្ព័ន្ធរបស់ធនាគារក្នុងការរៀបចំ ការអនុវត្តន៍ និងការតាមដាន ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

នៅចុងបញ្ចប់នៃការធ្វើសវនកម្ម សវនករផ្ទៃក្នុង បានតាមដានយ៉ាងស្វិតស្វាញនូវវឌ្ឍនៈភាព នៃការអនុវត្តន៍អនុសាសន៍ ដើម្បីធានាថារាល់ហានិភ័យធំៗ និងការត្រួតពិនិត្យ ដែលត្រូវផ្តោត យ៉ាងយកចិត្តទុកដាក់ត្រូវបានអនុវត្តដោយគណៈគ្រប់គ្រង។ រាល់របាយការណ៍សវនកម្មផ្ទៃក្នុង ស្តីពីលទ្ធផលការងារដែលបានធ្វើសវនកម្មរួច រួមជាមួយអនុសាសន៍ និងវឌ្ឍនៈភាពនៃ ការអនុវត្តន៍ ត្រូវបានរាយការណ៍ជូន គណៈគ្រប់គ្រង និងគណៈកម្មការសវនកម្ម។

សវនកម្មផ្ទៃក្នុងបានសហការជាមួយសវនករខាងក្រៅ ដើម្បីដោះស្រាយរាល់បញ្ហាលើការ ត្រួតពិនិត្យ ដែលបានលើកឡើងដោយសវនករខាងក្រៅដើម្បីធ្វើឲ្យប្រាកដថា រាល់បញ្ហាដែល បានរាយការណ៍ត្រូវ បានអនុវត្តដោយគណៈគ្រប់គ្រង។

# សកម្មភាពរបស់គណៈកម្មការសវនកម្ម និងមុខងារសវនកម្មផ្ទៃក្នុង (ត)

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

### ក្របខ័ណ្ឌរបស់គណៈកម្មការសវនកម្ម

**សមាជិករបស់គណៈកម្មការសវនកម្ម**

1. សមាជិកភាព

   ក) សមាជិករបស់គណៈកម្មការសវនកម្ម ត្រូវតែតែងតាំងដោយក្រុមប្រឹក្សាភិបាល ក្នុងចំណោមក្រុមប្រឹក្សាភិបាលរបស់ធនាគារ។

   ខ) សមាជិករបស់គណៈកម្មការសវនកម្ម ត្រូវមានសមាជិកយ៉ាងតិចបំផុត បី(3) នាក់។

2. ប្រធានគណៈកម្មការសវនកម្ម

   ក) សមាជិកទាំងអស់របស់គណៈកម្មការសវនកម្ម នឹងធ្វើការបោះឆ្នោតជ្រើសតាំង ប្រធានគណៈកម្មការក្នុងចំណោមសមាជិកគណៈកម្មការសវនកម្ម។

   ខ) គណៈកម្មការត្រូវដឹកនាំដោយប្រធានគណៈកម្មការសវនកម្ម។

**រចនាសម្ព័ន្ធនៃការរាយការណ៍**

គណៈកម្មការសវនកម្មរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ហើយរបាយការណ៍សវនកម្ម នឹងត្រូវ លើកឡើង ក្នុងអង្គប្រជុំក្រុមគណៈកម្មការសវនកម្ម (Group Audit Committee) ដែលជាផ្នែកមួយ តម្រូវដោយធនាគារមេ។

**តួនាទី និង ភារកិច្ច**

1. ភាពត្រឹមត្រូវ និងតម្លាភាពនៃការរាយការណ៍
   គណៈកម្មការសវនកម្ម ត្រូវធានាថា របាយការណ៍ហិរញ្ញវត្ថុដែលបោះផ្សាយជា សាធារណៈ ប្រកបដោយភាពត្រឹមត្រូវនិងមានតម្លាភាពហើយទាន់ពេលវេលា។

2. ប្រសិទ្ធិភាពសវនកម្មផ្ទៃក្នុង

   ក) ត្រួតពិនិត្យទៅលើមុខងាររបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងធ្វើឲ្យប្រាកដ លើការគោរព តាមច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធដែលចេញដោយអាជ្ញាធរ។

   ខ) ត្រួតពិនិត្យឡើងវិញ លើភាពគ្រប់គ្រាន់នៃដែនកំណត់នៃការធ្វើសវនកម្មផ្ទៃក្នុង សមត្ថភាព និងចំនួនបុគ្គលិករបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងសិទ្ធិក្នុងការ ពេញការងាររបស់ នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

   គ) ត្រួតពិនិត្យឡើងវិញលើនីតិវិធីសវនកម្មផ្ទៃក្នុង គំហើញដែលលើកឡើងដោយ សវនកម្មផ្ទៃក្នុង និងអនុសាសន៍ ផ្តល់ជូនគណៈគ្រប់គ្រងក្នុងការអនុវត្តន៍។

   ឃ) តែងតាំង រៀបចំអត្ថប្រយោជន៍ វាយតម្លៃលើការបំពេញការងារ និងសម្រេចចិត្តក្នុង ការផ្លាស់ប្តូរ រឺបញ្ឈប់ប្រធានសវនកម្មផ្ទៃក្នុងរបស់ធនាគារ។

3. ការត្រួតពិនិត្យផ្ទៃក្នុង
   ត្រួតពិនិត្យឡើងវិញទៅលើប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការនៃ ការគ្រប់គ្រង់ហានិភ័យ។

**តួនាទី និង ភារកិច្ច** (ត)

4. សវនកម្មខាងក្រៅ

ក) ផ្តល់អនុសាសន៍ក្នុងការតែងតាំងសវនកម្មខាងក្រៅ សំរាប់អនុម័តដោយក្រុមប្រឹក្សាភិបាល។

ខ) ផ្តល់អនុសាសន៍ក្នុងការផ្លាស់ប្តូរសវនកម្មខាងក្រៅ ដើម្បីអនុម័តដោយក្រុមប្រឹក្សាភិបាល។

គ) វាយតម្លៃលើគោលដៅសកម្មភាព ដែលបានអនុវត្ត និងឯករាជ្យភាពរបស់សវនករ ខាងក្រៅ (ឧទាហរណ៍ តាមរយៈការត្រួតពិនិត្យឡើងវិញ និងការថ្លឹងថ្លែង ទំនាក់ទំនងរវាងសវនករខាងក្រៅជាមួយធនាគារ រឺអង្គភាពដទៃទៀត)។

ឃ) ត្រួតពិនិត្យឡើងវិញជាមួយសវនករខាងក្រៅ ទៅលើដែនកំណត់ និងផែនការ សវនកម្ម រួមបញ្ចូលទាំងការផ្លាស់ប្តូរដែនកំណត់របស់ផែនការសវនកម្ម។

ង) ត្រួតពិនិត្យឡើងវិញជាមួយសវនករខាងក្រៅ ទៅលើការវាយតម្លៃប្រព័ន្ធត្រួត ពិនិត្យផ្ទៃក្នុង និងរបាយការណ៍សវនករ។

ច) ត្រួតពិនិត្យលើរបាយការណ៍អនុសាសន៍ ដែលផ្តល់ដោយសវនករខាងក្រៅ និងការឆ្លើយ តបរបស់គណៈគ្រប់គ្រង។

ឆ) ត្រួតពិនិត្យឡើងវិញយ៉ាងទៀងទាត់ទៅលើបញ្ហាដែលបានលើកឡើង និងធ្វើឲ្យ ប្រាកដថា រាល់គំហើញត្រូវបានគ្រប់គ្រង និងកែតម្រូវដោយសមស្រប ទាន់ពេលវេលា។

ជ) ត្រួតពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុ មុនពេលអនុវត្តដោយក្រុមប្រឹក្សាភិបាល ដោយផ្តោតទៅលើ៖

1. ការផ្លាស់ប្តូរ រឺការអនុវត្តន៍ ទៅលើគោលនយោបាយគណនេយ្យសំខាន់ៗ

2. ព្រឹត្តិការណ៍ដែលខុសប្រក្រតីហើយមានលក្ខណៈជាសារវ័ន្ត

3. ការគោរពតាមស្តង់ដារគណនេយ្យ និងបទបញ្ញត្តិផ្សេងៗ។

ឈ) ការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសវនកម្មខាងក្រៅ និងមានសិទ្ធិជួបជាមួយ សវនកម្មខាងក្រៅ ដោយមិនចាំបាច់មានវត្តមានពីគណៈគ្រប់គ្រងយ៉ាងតិចមួយឆ្នាំ ម្តង។

ញ) ត្រួតពិនិត្យឡើងវិញលើលិខិតលាលែងរបស់សវនកម្មខាងក្រៅ។

ដ) អនុម័តនូវសេវាកម្មនានាដែលមិនពាក់ព័ន្ធនឹងសេវាសវនកម្ម ដែលផ្តត់ផ្គង់ដោយ សវនករខាងក្រៅ។

ឋ) ធានាឲ្យមានការត្រួតពិនិត្យត្រឹមត្រូវ ដើម្បីឲ្យប្រាកដថាការផ្គត់ផ្គង់សេវាកម្មនានា ក្រៅពីសេវាសវនកម្មមិនប៉ះពាល់ដល់ឯករាជ្យភាពរបស់សវនករខាងក្រៅ។

# សកម្មភាពរបស់គណៈកម្មការសវនកម្ម និងមុខងារសវនកម្មផ្ទៃក្នុង (ត)

ធនាគារ អេ អេច ប៊ី ឥណ្ឌូឆៃណា

**<u>តួនាទី និង ភារកិច្ច</u>** (ត)

5. <u>ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ</u>
   ការពិនិត្យឡើងវិញនូវប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ និងទំនាស់ផលប្រយោជន៍ដែលនឹង អាចកើតឡើងនៅក្នុងធនាគារ រួមបញ្ចូលទាំងប្រតិបត្តិការផ្សេងៗ នីតិវិធី រឺក្រមសីលធម៌ ហើយចោទសំនួរទាក់ទងនឹងភាពស្មោះត្រង់របស់គណៈគ្រប់គ្រង។

**<u>សេចក្តីអនុម័ត</u>**

គណៈកម្មការសវនកម្មមានសេចក្តីអនុម័តដូចខាងក្រោម៖

ក) មានធនធានគ្រប់គ្រាន់តាមតម្រូវការដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

ខ) មានសិទ្ធិពេញលេញ និងមិនមានការហាមប្រាម ក្នុងការទទួលយកនូវព័ត៌មានជាចាំបាច់ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

គ) មានសិទ្ធិធ្វើការស៊ើបអង្កេតរាល់ទង្វើសកម្មភាពនានា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌគណៈ កម្មការសវនកម្ម។

ឃ) មានការអនុម័តក្នុងការបង្កើតគណៈកម្មការគ្រប់គ្រង/អនុគណៈកម្មការក្នុងករណីចាំបាច់។

ង) មានការអនុម័តក្នុងការផ្ទេរទំនួលខុសត្រូវផ្សេងៗទៅកាន់នរណាម្នាក់ រឺគណៈកម្មការ ណាមួយក្នុងករណីដែលចាំបាច់។

ច) មានសិទ្ធិក្នុងការទទួលយកនូវវិជ្ជាជីវៈ និងការណែនាំឯករាជ្យផ្សេងៗ។

ឆ) មានសិទ្ធិកោះប្រជុំជាមួយសវនករខាងក្រៅ សវនករផ្ទៃក្នុង រឺទាំងពីរ ដោយមិនរាប់បញ្ចូល នូវវត្តមានក្រុមប្រឹក្សាភិបាលផ្សេងៗ និងបុគ្គលិករបស់ធនាគារ និងផ្នែកពាក់ព័ន្ធ ខាងក្រៅផ្សេងៗក្នុងករណីចាំបាច់។

**<u>ប្រជុំ និងកំណត់ត្រា</u>**

ក) គណៈកម្មការនឹងត្រូវប្រជុំប្រចាំត្រីមាស រឺនៅក្នុងករណីចាំបាច់ ហើយកិច្ចប្រជុំមិនត្រូវ តិចជាង បួន(4) ដង ក្នុង1ឆ្នាំ។

ខ) កូរ៉ុមនៃកិច្ចប្រជុំត្រូវមានយ៉ាងហោចណាស់ ពីរ(2) នាក់ រឺ 50% នៃសមាជិកទាំងអស់ រឺ ច្រើនជាងនេះ។

គ) គណៈកម្មការអាចកោះប្រជុំនៅក្នុងព្រះរាជាណាចក្រកម្ពុជា រឺ ប្រទេសផ្សេងៗ។

ឃ) គណៈកម្មការត្រូវបានអនុញ្ញាតផងដែរនូវការអនុវត្តន៍សេចក្តីសម្រេច តាមរយៈសារាចរណ៍ណែនាំ។

ង) នាយកផ្នែកនីមួយៗ គណៈគ្រប់គ្រងដែលពាក់ព័ន្ធត្រូវបានអញ្ជើញឲ្យចូលរួមកិច្ចប្រជុំ ជាមួយគណៈកម្មការនេះ (រឺផ្នែកផ្សេងទៀតក្នុងករណីចាំបាច់)។

ច) គណៈកម្មការអាចពន្យាពេលប្រជុំ រឺអាចកោះប្រជុំជាធម្មតាវិញ នៅករណីចាំបាច់ តាមរយៈការសន្ទនាដោយប្រើប្រាស់បច្ចេកវិទ្យាហើយអាចឲ្យអ្នកចូលរួមប្រជុំស្តាប់ លឺបាន។ សមាជិកចូលរួម ក្នុងអង្គប្រជុំនឹងត្រូវរាប់ជាកូរ៉ុម។ រាល់សេចក្តីសម្រេចដែល យល់ព្រមដោយ សមាជិកនៅក្នុងអង្គប្រជុំប្រភេទនេះនឹងត្រូវមានសុពលភាពដូចគ្នានឹង សេចក្តីសម្រេចក្នុងអង្គប្រជុំធម្មតាដែរ។

ឆ) សេចក្តីសម្រេច សំណើ និងបញ្ហាផ្សេងៗ ត្រូវដាក់ជូនឆ្លងការយល់ព្រមនៅរៀងរាល់ពេល ប្រជុំគណៈកម្មការ ហើយការអនុម័តត្រូវយកតាមមតិភាគច្រើននៃវត្តមានសមាជិក ទាំងអស់។

ជ) ប្រធានគណៈកម្មការ នឹងត្រូវតែងតាំងនរណាម្នាក់ជាលេខា និងកត់ត្រានូវកិច្ចប្រជុំដែលបានប្រព្រឹត្តទៅ។

របាយការណ៍ហិរញ្ញវត្ថុ 2016

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា

RHB Indochina Bank



# ការអនុវត្តន៍ប្រកបដោយនិរន្តរភាព

យើងរួមគ្នាដើម្បីភាពរីកចំរើន

**ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា**

អគារលេខ 263 វិថីអង្គឌួង (ផ្លូវលេខ 110) ភ្នំពេញ

លេខទូរស័ព្ទ (855) 23 992 833 លេខទូរសារ (855) 23 991 822

**www.rhbgroup.com**
**facebook.com/RHB Cambodia**

# មាតិកា


200 តារាងតុល្យការ

201 របាយការណ៍លទ្ធផល

202 របាយការណ៍បម្រែបម្រួលមូលធន

203 របាយការណ៍លំហូរសាច់ប្រាក់

204 - 250 កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

# តារាងតុល្យការ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សម្គាល់ | 2016 | | 2015 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | **6,256,945** | 25,259,287 | **3,805,590** | 15,412,640 |
| សមតុល្យនៅធនាគារកណ្តាល | 4 | **146,491,301** | 591,385,382 | **112,359,292** | 455,055,133 |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 5 | **115,751,265** | 467,287,857 | **90,495,806** | 366,508,014 |
| ឥណទាន និងបុរេប្រទានអតិថិជន | 6 | **347,575,673** | 1,403,162,992 | **338,622,585** | 1,371,421,469 |
| ទ្រព្យសកម្មផ្សេងៗ | 7 | **2,931,117** | 11,832,919 | **15,241,270** | 61,727,142 |
| ពន្ធពន្យារទ្រព្យសកម្ម | 20(ក) | **637,890** | 2,575,162 | **151,520** | 613,656 |
| ទ្រព្យសកម្មអរូបី | 8 | **295,308** | 1,192,158 | **353,150** | 1,430,258 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | **2,955,017** | 11,929,404 | **2,914,540** | 11,803,887 |
| **ទ្រព្យសកម្មសរុប** | | **622,894,516** | 2,514,625,161 | **563,943,753** | 2,283,972,199 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | 10 | **231,367,484** | 934,030,533 | **262,539,327** | 1,063,284,274 |
| ប្រាក់បញ្ញើរបស់អតិថិជន | 11 | **297,271,520** | 1,200,085,126 | **216,199,505** | 875,607,995 |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | 20(ខ) | **1,610,398** | 6,501,177 | **1,722,942** | 6,977,915 |
| បំណុលផ្សេងៗ | 12 | **8,198,445** | 33,097,122 | **5,732,717** | 23,217,504 |
| **បំណុលសរុប** | | **538,447,847** | 2,173,713,958 | **486,194,491** | 1,969,087,688 |
| **មូលធន** | | | | | |
| ដើមទុន | 13 | **67,000,000** | 270,479,000 | **67,000,000** | 271,350,000 |
| ចំណេញរក្សាទុក | | **17,446,669** | 70,432,203 | **10,749,262** | 43,534,511 |
| **មូលធនសរុប** | | **84,446,669** | 340,911,203 | **77,749,262** | 314,884,511 |
| **បំណុល និងមូលធនសរុប** | | **622,894,516** | 2,514,625,161 | **563,943,753** | 2,283,972,199 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 204 ដល់ទំព័រទី 250 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផល

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សម្គាល់ | 2016 ដុល្លារអាមេរិក | 2016 ពាន់រៀល | 2015 ដុល្លារអាមេរិក | 2015 ពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 14 | **32,740,161** | 132,172,030 | **24,494,670** | 99,203,414 |
| ចំណាយការប្រាក់ | 15 | **(14,548,943)** | (58,734,083) | **(9,799,719)** | (39,688,862) |
| **ចំណូលការប្រាក់សុទ្ធ** | | **18,191,218** | 73,437,947 | **14,694,951** | 59,514,552 |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ | 16 | **2,561,002** | 10,338,765 | **2,994,301** | 12,126,919 |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសារ | | **(7,811)** | (31,533) | **(16,316)** | **(66,080)** |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ** | | **2,553,191** | 10,307,232 | **2,977,985** | 12,060,839 |
| ចំណូលប្រតិបត្តិការផ្សេងៗ | | **183,267** | 739,849 | **151,750** | 614,588 |
| **ចំណូលប្រតិបត្តិការសរុប** | | **20,927,676** | 84,485,208 | **17,824,686** | 72,189,979 |
| ចំណាយបុគ្គលិក | 17 | **(3,376,220)** | (13,629,800) | **(3,448,087)** | (13,964,752) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | 18 | **(1,035,209)** | (4,179,139) | **(1,044,770)** | (4,231,319) |
| ចំណាយទូទៅ និងចំណាយប្រតិបត្តិការ | 19 | **(3,012,420)** | (12,161,140) | **(2,500,055)** | (10,125,223) |
| **ចំណេញមុនកាត់កងសំវិធានធនឥណទានបាត់បង់** | | **13,503,827** | 54,514,949 | **10,831,774** | 43,868,685 |
| សំវិធានធនឥណទានបាត់បង់ | 6 | **(5,078,809)** | (20,503,152) | **(2,823,668)** | (11,435,855) |
| **ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ** | | **8,425,018** | 34,011,797 | **8,008,106** | 32,432,830 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 20(គ) | **(1,727,611)** | (6,974,365) | **(2,137,283)** | (8,655,996) |
| **ចំណេញក្នុងឆ្នាំ** | | **6,697,407** | 27,037,432 | **5,870,823** | 23,776,834 |
| **បែងចែកទៅឲ្យក្រុមហ៊ុនមេរបស់ ធនាគារ** | | **6,697,407** | 27,037,432 | **5,870,823** | 23,776,834 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 204 ដល់ទំព័រទី 250 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | បែងចែកទៅឲ្យក្រុមហ៊ុនមេរបស់ធនាគារ | | |
|---|---|---|---|
| | ដើមទុន | ចំណេញរក្សាទុក | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2015 | 52,000,000 | 4,878,439 | **56,878,439** |
| ការបង្កើនដើមទុន | 15,000,000 | - | **15,000,000** |
| ចំណេញក្នុងឆ្នាំ | - | 5,870,823 | **5,870,823** |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 | 67,000,000 | 10,749,262 | **77,749,262** |
| សមមូលនឹងពាន់រៀល | 271,350,000 | 43,534,511 | **314,884,511** |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 67,000,000 | 10,749,262 | **77,749,262** |
| ចំណេញក្នុងឆ្នាំ | - | 6,697,407 | **6,697,407** |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 67,000,000 | 17,446,669 | **84,446,669** |
| សមមូលនឹងពាន់រៀល | 270,479,000 | 70,432,203 | **340,911,203** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 204 ដល់ទំព័រទី 250 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

| | កំណត់សម្គាល់ | 2016 | | 2015 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានពីប្រតិបត្តិការ | 21 | **12,055,482** | 48,667,981 | **57,532,844** | 233,008,018 |
| ការប្រាក់បានទទួល | | **32,906,597** | 132,843,932 | **24,494,670** | 99,203,414 |
| ការប្រាក់បានបង់ | | **(13,854,444)** | (55,930,390) | **(9,799,719)** | (39,688,862) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | **(2,326,525)** | (9,392,181) | **(1,962,504)** | (7,948,141) |
| សាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ | | **28,781,110** | 116,189,342 | **70,265,291** | **284,574,429** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| **ការទិញ៖** | | | | | |
| - ទ្រព្យសកម្មអរូបី | 8 | **(45,935)** | (185,440) | **(137,108)** | (555,287) |
| - ទ្រព្យសម្បត្តិ និងបរិក្ខារ | 9 | **(979,745)** | (3,955,231) | **(657,320)** | (2,662,146) |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | **12,500,000** | 50,462,500 | **-** | - |
| សាច់ប្រាក់បានមកពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | **14,800** | 59,748 | **23,473** | 95,066 |
| សាច់ប្រាក់សុទ្ធបានពី/(បានប្រើក្នុង)សកម្មភាពវិនិយោគ | | **11,489,120** | 46,381,577 | **(770,955)** | (3,122,367) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីការបង្កើនដើមទុន | | **-** | - | **15,000,000** | 60,750,000 |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | **-** | - | **15,000,000** | 60,750,000 |
| **កំណើនក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **40,270,230** | 162,570,919 | **84,494,336** | 342,202,062 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | **125,175,701** | 506,961,590 | **40,681,365** | 165,776,562 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | **-** | (1,627,286) | **-** | (1,017,034) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | 22 | **165,445,931** | 667,905,223 | **125,175,701** | 506,961,590 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី 204 ដល់ទំព័រទី 250 គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 1. ព័ត៌មានទូទៅ

ធនាគារ អ អេច ប៊ី ឥណ្ឌូឆៃណា (ហៅកាត់ថា "ធនាគារ") បានបង្កើតឡើងនៅថ្ងៃទី09 ខែកក្កដា ឆ្នាំ2008 ដោយបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") បានផ្តល់ជូនអាជ្ញាប័ណ្ណដើម្បីធ្វើប្រតិបត្តិការធនាគារនៅថ្ងៃទី03 ខែតុលា ឆ្នាំ2008។ ធនាគារគឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធដែលត្រូវបានកាន់កាប់ទាំងស្រុងដោយធនាគារ RHB Bank Berhad ជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត បានចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសម៉ាឡេស៊ី និងក្រុមហ៊ុនមេធំចុងក្រោយរបស់ក្រុមហ៊ុន RHB Banking Group ស្របទៅតាមរចនាសម្ព័ន្ធរបស់ក្រុមហ៊ុនរួម ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី13 ខែមិថុនា ឆ្នាំ2016។

ធនាគារធ្វើសកម្មភាពចម្បងក្នុងការផ្តល់សេវាធនាគារពាណិជ្ជជាច្រើនប្រភេទ នៅកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅ អគារលេខ 263 វិថីព្រះអង្គឌួង ផ្លូវព្រះអង្គឌួងជាន់ផ្ទាល់ដីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារមានសាខាទាំងអស់ចំនួន12សាខានៅរាជធានីភ្នំពេញ និងបណ្តាខេត្តនានា។ សាខានៅរាជធានីភ្នំពេញមានទីតាំងស្ថិតនៅអគារការិយាល័យកណ្តាល អគារស៊ីធីម៉លអូឡាំពិក ស្ទឹងមានជ័យ ក្បាលថ្នល់ ពេទ្យលោកសង្ឃ ទួលគោក ម៉ៅសេទុង និងបឹងកេងកង ហើយសាខានៅតាមបណ្តាខេត្តមានដូចជា ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តសៀមរាប និងខេត្តព្រះសីហនុ។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2017។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះត្រូវបានអនុវត្តយ៉ាងមានសង្គតភាពគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។

### 2.1 មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម ហើយប្រសិនបើចំណុចណាមួយដែលមិនបានបង្ហាញតាមវិធីសាស្ត្រថ្លៃដើម វានឹងមានការលាតត្រដាងបន្ថែមទៀត និងបានរៀបចំដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។ ក្នុងការអនុវត្ត CAS ធនាគារក៏បានប្រើការលាតត្រដាងព័ត៌មាន ទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា (ហៅកាត់ថា "CFRS") គឺ CFRS7 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការ ណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះ របាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបាន ជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.1 មូលដ្ឋាននៃការរៀបចំ (ត)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CAS និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត់ ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ បើទោះជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់3 នៃរបាយការណ៍ហិរញ្ញវត្ថុ។

### 2.2 ក្របខ័ណ្ឌរបាយការណ៍ហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី28 ខែសីហា ឆ្នាំ2009 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "ក្រុមប្រឹក្សា ជាតិគណនេយ្យ") បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (ហៅកាត់ថា "IASB") រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំ របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2012 ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ 058 សហវ-កជគ ចុះថ្ងៃទី24 ខែមីនា ឆ្នាំ2016 ក្រុមប្រឹក្សាជាតិគណនេយ្យបានអនុម័តឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទ ដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2019 ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។

CAS ស្តង់ដារគណនេយ្យដែលកំពុងប្រើប្រាស់បច្ចុប្បន្ន មានភាពខុសប្លែកពី CIFRS តាមផ្នែកជាក់លាក់។ ដូច្នេះ ការដាក់ឲ្យប្រើប្រាស់ CIFRS នឹងមានផលប៉ះពាល់មួយចំនួនទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

### 2.3 ការប្តូររូបិយប័ណ្ណ

(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាស សេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.3 ការប្តូររូបិយប័ណ្ណ (ត)

(ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរ ប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានាដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រា ប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

(គ) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមប្រកាសលេខ ធ7-07-164ប្រ.ក. ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 របស់ធនាគារកណ្តាល តម្រូវឲ្យ កត់ត្រាប្តូរទៅជាប្រាក់រៀល ចំពោះតារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូឆ្នាំ2016 ដោយប្រើអត្រាប្តូរប្រាក់មធ្យមភាគផ្លូវការដែលបានចេញផ្សាយដោយធនាគារកណ្តាលនាកាលបរិច្ឆេទរាយការណ៍ ដែល១ដុល្លារអាមេរិកស្មើនឹង 4,037រៀល (31 ធ្នូ 2015 ៖ 1ដុល្លារអាមេរិកស្មើនឹង 4,050 រៀល)។ តួលេខដែលត្រូវបានប្តូរនេះ មិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះ ជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាម អត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

### 2.4 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សមតុល្យដែលមានកាលកំណត់ដើមតិចជាងបីខែគិតចាប់ពីថ្ងៃទទួលបានសាច់ប្រាក់ ក្នុងនោះរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានកម្រិតនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ។

### 2.5 ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជនទាំងអស់ ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការតាមចំនួនទឹកប្រាក់ដើមដែលនៅសល់ ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទានបាត់បង់។

ឥណទានត្រូវបានជម្រះចេញពីបញ្ជីនៅពេលដែលមិនមានភាពជាក់ស្តែង អំពីលទ្ធភាពក្នុងការប្រមូលប្រាក់មកវិញ។ ឥណទាន និងបុរេប្រទានដែលប្រមូលបានមកវិញ បន្ទាប់ពីបានជម្រះចេញពីបញ្ជីរួច ឬបានកត់ត្រាសំវិធានធនរួច ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.6 សំវិធានធនឥណទានបាត់បង់

ធនាគារបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្តាលលេខធ7-09-074ប្រ.ក. ចុះថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2009។ ប្រកាសនេះតម្រូវឲ្យធនាគារពាណិជ្ជទាំងឡាយ ត្រូវចាត់ថ្នាក់ឥណទាន បុរេប្រទាន និងទ្រព្យសកម្មផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នា ជាប្រាំថ្នាក់ ហើយកម្រិតចាំបាច់អប្បបរមានៃសំវិធានធនជាក់លាក់ត្រូវកត់ត្រាអាស្រ័យតាមចំណាត់ថ្នាក់ពាក់ព័ន្ធដូចខាងក្រោម ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ៖

| ចំណាត់ថ្នាក់ | អត្រាសំវិធានធន |
|---|---|
| សំវិធានធនទូទៅ | |
| ឥណទានធម្មតា | 1% |
| សំវិធានធនជាក់លាក់ | |
| ឥណទានឃ្លាំមើល | 3% |
| ឥណទានក្រោមស្តង់ដារ | 20% |
| ឥណទានសង្ស័យ | 50% |
| ឥណទានបាត់បង់ | 100% |

### 2.7 កិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗ

នៅក្នុងដំណើរការអាជីវកម្មធម្មតា ធនាគារចុះកិច្ចសន្យាដែលពាក់ព័ន្ធនឹងឥណទានផ្សេងៗ រួមមានកិច្ចសន្យាឥណទាន លិខិតឥណទាន និងលិខិតធានាធនាគារផ្សេងៗ។ គោលការណ៍គណនេយ្យ និងវិធីសាស្ត្រសំវិធានធន មានលក្ខណៈស្រដៀងគ្នាចំពោះឥណទានផ្សេងៗដូចបានកត់សម្គាល់ខាងលើ។ ធនាគារនឹងកត់ត្រាសំវិធានធនជាក់លាក់ចំពោះកិច្ចសន្យាពាក់ព័ន្ធនឹងឥណទានផ្សេងៗទាំងនោះ នៅពេលដែលធនាគារ គិតថាវាទំនងជាមានការបាត់បង់។

### 2.8 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរក្នុងរយៈពេល5ឆ្នាំ។ ចំណាយនានាពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.9 ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់នានាក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មទាំងនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ការធ្វើរំលស់លើទ្រព្យសម្បត្តិនិងបរិក្ខារត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានរំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗ និងតាមអត្រាប្រចាំឆ្នាំដូចខាងក្រោម ៖

| | អាយុកាលប្រើប្រាស់ |
|---|---|
| ការកែលម្អលើទ្រព្យជួល | រយៈពេលណាមួយដែលខ្លីជាងគេ រវាងរយៈពេលជួល និងអាយុកាលផ្អែកសេដ្ឋកិច្ចរបស់វា |
| បរិក្ខារការិយាល័យ | 5 ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់ | 5 ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | 3 ឆ្នាំ |
| យានយន្ត | 5 ឆ្នាំ |

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ជម្រះទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់។ (ត)

### 2.10 ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ និងត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំរកការថយចុះតម្លៃរបស់វា។ បណ្តាទ្រព្យសកម្មដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វា នឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានគេកត់ត្រាតាម ចំនួនលម្អៀងរវាងតម្លៃយោងនៃទ្រព្យនោះ ធៀបជាមួយតម្លៃដែលអាចស្រង់មកវិញបាន។ តម្លៃដែលអាចស្រង់មកវិញបានគឺជាតម្លៃមួយណាដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផលទៅតាមទំហំតម្លៃយោងនៃទ្រព្យសកម្មនោះ ដែលមិនលើសតម្លៃយោងដែលបានកំណត់ កាត់កងនឹងរំលស់ ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

### 2.11 ចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់បានមកពីឥណទាន និងបុរេប្រទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យ និងការដាក់ប្រាក់នៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ លើកលែងតែមានការសង្ស័យគួរឲ្យបារម្ភចំពោះការប្រមូលប្រាក់មកវិញ ដែលក្នុងករណីនេះការប្រាក់ត្រូវបានព្យួរសិន រហូតដល់ពេលទទួលបានសាច់ប្រាក់ជាក់ស្តែង។ គោលការណ៍ស្តីពីការព្យួរការប្រាក់នេះ គឺអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាលស្តីពីការព្យួរការប្រាក់លើប្រាក់កម្ចីមិនដំណើរការ និងសំវិធានធនឥណទានបាត់បង់។

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជន ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

### 2.12 ចំណូលកម្រៃ និងជើងសារ

ចំណូលកម្រៃ និងជើងសារ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលបានបំពេញសេវាជូនអតិថិជន។ កម្រៃលើការផ្តល់ឥណទានត្រូវបានកត់ត្រាជាចំណូល នៅពេលដែលផ្តល់ឥណទានឲ្យអតិថិជនខ្ចី។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់។ (ត)

### 2.13 ភតិសន្យាប្រតិបត្តិ

ភតិសន្យាដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងផលកម្មសិទ្ធិលើទ្រព្យនេះ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

### 2.14 សំវិធានធន

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។

សំវិធានធនត្រូវបានវាស់វែងឡើងវិញតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

### 2.15 អត្ថប្រយោជន៍បុគ្គលិក

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី
អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំ ដែលបុគ្គលិកបានបំពេញការងារជូនធនាគារ។

### 2.16 ពន្ធពន្យារលើប្រាក់ចំណេញ និងពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍នៅក្នុងប្រទេសកម្ពុជា ដែលជាកន្លែងដែលធនាគារ ប្រតិបត្តិការ និងបង្កើត ចំណូលជាប់ពន្ធ។

ពន្ធពន្យារត្រូវបានគណនាដោយប្រើវិធីសាស្ត្របំណុលក្នុងតារាងតុល្យការ លើលម្អៀងបណ្តោះអាសន្ននៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលប្រើប្រាស់សម្រាប់ការគណនាពន្ធ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាដែលរំពឹងថា និងត្រូវអនុវត្តលើលម្អៀងបណ្តោះអាសន្ន នៅពេលដែលកត់ត្រាត្រលប់ចូលមកវិញដោយផ្អែកតាមពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍។

## 2. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់។ (ត)

### 2.16 ពន្ធពន្យារលើប្រាក់ចំណេញ និងពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ (ត)

ពន្ធពន្យារទ្រព្យសកម្មត្រូវបានគេកាត់កងជាមួយនឹងពន្ធពន្យារបំណុល ប្រសិនបើធនាគារមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់បំណុលពន្ធ និងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយទៅលើអង្គភាពជាប់ពន្ធតែមួយ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងបំណុលពន្ធក្នុងឆ្នាំ ជាមួយនឹងពន្ធទ្រព្យសកម្មក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរ ពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាធនាគារនឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតសម្រាប់យកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់ការបរិច្ឆេទរបាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយរហូតដល់កម្រិតមួយដែលមិនមានភាពប្រាកដថា នឹងមានអត្ថប្រយោជន៍ពន្ធ ពាក់ព័ន្ធនឹងត្រូវកើតឡើង។

### 2.17 ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធ ប្រសិនបើភាគីណាមួយមានសមត្ថភាពក្នុងការគ្រប់គ្រងភាគីមួយទៀត ឬមានឥទ្ធិពលជាសារវន្តទៅលើភាគីផ្សេងទៀតក្នុងការធ្វើការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងប្រតិបត្តិការ។

អនុលោមតាមច្បាប់ស្តីពីធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ភាគីពាក់ព័ន្ធត្រូវបានកំណត់ជាភាគីដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងហោចណាស់ 10% នៃដើមទុន ឬសិទ្ធិបោះឆ្នោត និងរួមបញ្ចូលទាំងបុគ្គលទាំងឡាយណាដែលបានចូលរួមក្នុងរដ្ឋបាល ទិសដៅ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

## 3. ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់។

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និង កត្តា ផ្សេងៗទៀតរួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគតដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈ ផ្សេងៗ។ ធនាគារធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដោយគិតទៅលើអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រស្មើគ្នានឹងលទ្ធផលជាក់ស្តែងណាស់។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

### 3. ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានហានិភ័យជា សារវន្តបណ្តាលឱ្យមាននិយ័តកម្មធំដុំទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំបន្ទាប់ ត្រូវបានពិភាក្សាដូចខាងក្រោម៖

#### (ក) ការខាតបង់លើការថយចុះតម្លៃនៃឥណទាន និងបុរេប្រទាន

ធនាគារអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនតាមប្រកាសលេខ ធ7-09-074ប្រ.ក. ចុះថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2009 ស្តីពីការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន សម្រាប់ធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុ ចេញដោយធនាគារកណ្តាល។ ធនាគារកណ្តាលតម្រូវឲ្យធនាគារពាណិជ្ជទាំងឡាយធ្វើចំណាត់ថ្នាក់ឥណទាន និងបុរេប្រទាន និងទ្រព្យសកម្មប្រហាក់ប្រហែលរបស់ខ្លួនជាប្រាំថ្នាក់ ហើយកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ត្រូវធ្វើឡើងអាស្រ័យទៅតាមចំណាត់ថ្នាក់ពាក់ព័ន្ធ ដោយមិនគិតពីទ្រព្យសកម្មដែលបានដាក់បញ្ចាំ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទាន ធនាគារពិចារណាទៅលើកត្តាពាក់ព័ន្ធទាំងអស់ដែលអាចមានផលប៉ះពាល់ដល់លទ្ធភាពក្នុងការសងប្រាក់នៃភាគីដៃគូរបស់ខ្លួន។

#### (ខ) ពន្ធ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ប៉ុន្តែបទប្បញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសម្រេចជាចុងក្រោយលើចំនួនពន្ធ នឹងធ្វើឡើងបន្ទាប់ពីអធិការកិច្ចរបស់អាជ្ញាធរពន្ធដារ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយ ខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់សំវិធានធនលើប្រាក់ពន្ធពន្យារនៅក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធបានធ្វើឡើង។

## 4. សមតុល្យនៅធនាគារកណ្តាល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | **81,790,980** | 330,190,186 | **53,960,362** | 218,539,467 |
| គណនីផាត់ទាត់ | **597,199** | 2,410,892 | **420,115** | 1,701,466 |
| ទុនបម្រុងកាតព្វកិច្ច (ក) | **54,353,580** | 219,425,403 | **48,784,987** | 197,579,197 |
| ប្រាក់តម្កល់ធានាលើដើមទុន (ខ) | **6,700,000** | 27,047,900 | **6,700,000** | 27,135,000 |
| មូលប្រតអាចជួញដូរបាន (គ) | **3,049,542** | 12,311,001 | **2,493,828** | 10,100,003 |
| | **146,491,301** | 591,385,382 | **112,359,292** | 455,055,133 |

### (ក) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ចគឺជាទុនបម្រុងអប្បបរមា ដែលត្រូវបានគណនាតាមអត្រា8% (2015 ៖ 8%) នៃប្រាក់បញ្ញើរបស់អតិថិជន ជាប្រាក់រៀល និង12.50% (2015 ៖ 12.50%) នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណផ្សេងៗ។ ទុនបម្រុងកាតព្វកិច្ច 4.5% (2015 ៖ 4.5%) នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់រៀល ទទួលបានការប្រាក់ ហើយទុនបម្រុងកាតព្វកិច្ច៨%ទៀត និងទុនបម្រុងកាតព្វកិច្ចនៃប្រាក់បញ្ញើរបស់អតិថិជនជាប្រាក់រៀល ពុំមានការប្រាក់ទេ។

### (ខ) ប្រាក់តម្កល់ធានាលើដើមទុន

យោងតាមប្រកាសលេខ ធ7-01-136ប្រ.ក. ចុះថ្ងៃទី15 ខែតុលា ឆ្នាំ2001 ចេញដោយធនាគារកណ្តាល ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ តម្កល់ប្រាក់ចំនួន 10% នៃដើមទុនចុះបញ្ជីនៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយប្រាក់តម្កល់នេះមិនសម្រាប់ប្រើក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ។

### (គ) មូលបត្រអាចជួញដូរបាន (NCDS)

មូលប្រតនេះ អាចជួញដូរបាន រវាងធនាគារ និងធនាគារផ្សេងៗ។ NCDs ជាប្រាក់រៀល មានកាលកំណត់ពី ពីរសប្តាហ៍ទៅមួយឆ្នាំ ដោយមានអត្រាការប្រាក់ចាប់ពី 1.70% ទៅ 3.99% ក្នុងមួយឆ្នាំ និងមូលបត្រជាប្រាក់ដុល្លារអាមេរិក អាចមានកាលកំណត់ពី ពីរសប្តាហ៍ទៅប្រាំមួយខែ ជាមួយនឹងអត្រាការប្រាក់ ½% SIBOR ។ មូលប្រតអាចជួញដូរបាន អាចត្រូវបានប្រើសម្រាប់កិច្ចសន្យាទិញយកវិញ និងអាចដាក់ជាទ្រព្យបញ្ចាំនៅក្នុងទីផ្សារអន្តរធនាគារ។

មូលប្រតអាចជួញដូរបានរបស់ធនាគារដែលមានចំនួនទឹកប្រាក់ 3,049,542 ដុល្លារអាមេរិក (ឆ្នាំ2015៖2,493,828 ដុល្លារអាមេរិក) ត្រូវបានដាក់ជាទ្រព្យបញ្ចាំសម្រាប់រយៈពេលបីខែ សម្រាប់សម្បទានវិបារូបន៍របស់ខ្លួន នៅធនាគារកណ្តាល។ គិតត្រឹមថ្ងៃ ទី31 ខែធ្នូ ឆ្នាំ2016 ធនាគារមិនទាន់បានប្រើប្រាស់សម្បទានវិបារូបន៍នៅឡើយ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 4. សមតុល្យនៅធនាគារកណ្តាល (ត)

### (ឃ) អត្រាការប្រាក់

គណនីចរន្ត និងគណនីផាត់ទាត់ គឺជាគណនីដែលមិនមានការប្រាក់។ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ប្រាក់តម្កល់ធានាលើដើមទុន និងទុនបម្រុងកាតព្វកិច្ចទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

| | 2016 | 2015 |
|---|---|---|
| ទុនបម្រុងកាតព្វកិច្ច | 0.08% | 0.08% |
| ប្រាក់តម្កល់ធានាលើដើមទុន | 0.08% | 0.08% |
| មូលបត្រដែលអាចជួញដូរបាន | 0.54% - 0.98% | 0.29% - 0.99% |

## 5. សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង។

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត (គណនីមិនមានការប្រាក់) | **27,751,265** | 112,031,857 | **6,495,806** | 26,308,014 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ (*) | **88,000,000** | 355,256,000 | **84,000,000** | 340,200,000 |
| | **115,751,265** | 467,287,857 | **90,495,806** | 366,508,014 |

(*) រាល់គណនីប្រាក់បញ្ញើមានកាលកំណត់ទាំងអស់ មានកាលកំណត់រយៈពេលមួយឆ្នាំ និងទទួលបានការប្រាក់ ដូចខាងក្រោម៖

| | 2016 | 2015 |
|---|---|---|
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 1.10% - 5.20% | 1.00% - 4.60% |

## 6. ឥណទាន និងបុរេប្រទានអតិថិជន

### (ក) វិភាគតាមប្រភេទឥណទាននិងបុរេប្រទាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានមានកាលកំណត់ | **265,441,192** | 1,071,586,092 | **260,688,872** | 1,055,789,934 |
| ឥណទានទិញផ្ទះ | **29,223,480** | 117,975,189 | **24,935,527** | 100,988,885 |
| ឥណទានទិញយានយន្ត | **24,532** | 99,036 | **7,277** | 29,470 |
| ឥណទានវិបារូបន៍ | **59,965,411** | 242,080,364 | **55,826,204** | 226,096,126 |
| ឥណទានទិញយានយន្តរបស់បុគ្គលិក | **199,134** | 803,904 | **130,122** | 526,994 |
| ឥណទានទិញផ្ទះរបស់បុគ្គលិក | **3,068,612** | 12,387,986 | **2,468,563** | 9,997,679 |
| សក្ខីបត្រឥណទានជំនឿទុកចិត្ត | **166,101** | 670,550 | **-** | - |
| ឥណទាននិងបុរេប្រទានអតិថិជនដុល | **358,088,462** | 1,445,603,121 | **344,056,565** | 1,393,429,088 |
| សំវិធានធនឥណទានបាត់បង់៖ | | | | |
| សំវិធានធនជាក់លាក់ | **(7,065,485)** | (28,523,363) | **(2,074,486)** | (8,401,668) |
| សំវិធានធនទូទៅ | **(3,447,304)** | (13,916,766) | **(3,359,494)** | (13,605,951) |
| **ឥណទាននិងបុរេប្រទានអតិថិជនសុទ្ធ** | **347,575,673** | 1,403,162,992 | **338,622,585** | 1,371,421,469 |

### (ខ) សំវិធានធនឥណទានបាត់បង់

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សំវិធានធនដើមឆ្នាំ | **5,433,980** | 22,007,619 | **2,610,312** | 10,637,021 |
| បម្រែបម្រួលសំវិធានធនក្នុងឆ្នាំ | **5,078,809** | 20,503,152 | **2,823,668** | 11,435,855 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | (70,642) | **-** | (65,257) |
| **សំវិធានធនចុងឆ្នាំ** | **10,512,789** | 42,440,129 | **5,433,980** | 22,077,619 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 6. ឥណទាន និងបុរេប្រទានអតិថិជន (ត)

### (គ) វិភាគតាមដំណើរការឥណទាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានធម្មតា | | | | |
| មានការធានា | **344,711,945** | 1,391,602,122 | **335,949,435** | 1,360,595,208 |
| មិនមានការធានា | **18,445** | 74,462 | **-** | - |
| ឥណទានឃ្លាំមើល | | | | |
| មានការធានា | **4,522,303** | 18,256,537 | **5,113,440** | 20,709,434 |
| ឥណទានក្រោមស្តង់ដារ | | | | |
| មានការធានា | **1,909,721** | 7,709,544 | **415,229** | 1,681,678 |
| ឥណទានសង្ស័យ | | | | |
| មានការធានា | **756,352** | 3,053,393 | **1,480,849** | 5,997,437 |
| ឥណទានខាតបង់ | | | | |
| មានការធានា | **6,169,696** | 24,907,063 | **1,097,612** | 4,445,331 |
| | **358,088,462** | 1,445,603,121 | **344,056,565** | 1,393,429,088 |

### (ឃ) វិភាគតាមហានិភ័យឥណទាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហានិភ័យធំ | **38,658,372** | 156,063,848 | **30,445,538** | 123,304,429 |
| ហានិភ័យតូច | **319,430,090** | 1,289,539,273 | **313,611,027** | 1,270,124,659 |
| | **358,088,462** | 1,445,603,121 | **344,056,565** | 1,393,429,088 |

ហានិភ័យធំត្រូវបានកំណត់និយមន័យដោយធនាគារកណ្តាលថាជាហានិភ័យឥណទានទូទៅ ចំពោះអ្នកទទួលផលជាឯកត្តជន ដែលមានចំនួនលើសពី10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យនេះ គឺមានចំនួនខ្ពស់ជាងឥណទានឬកិច្ចសន្យាដែលនៅមិនទាន់ទូទាត់ និងឥណទានឬកិច្ចសន្យាដែលបានអនុម័តរួច។

## 6. ឥណទាន និងបុរេប្រទានអតិថិជន (ត)

### (ង) អត្រាការប្រាក់

ឥណទាន និងបុរេប្រទានអតិថិជន ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម៖

| | 2016 | 2015 |
|---|---|---|
| ឥណទានមានកាលកំណត់ | 7.50% - 15.25% | 8.00% - 14.00% |
| ឥណទានវិបារូបន៍ | 8.00% - 12.50% | 8.00% - 12.00% |

## 7. ទ្រព្យសកម្មផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការប្រាក់ដុលត្រូវទទួល | **4,364,456** | 17,619,309 | **2,519,917** | 10,205,664 |
| ដក៖ ការប្រាក់ត្រូវព្យួរ | **(2,491,243)** | (10,057,148) | **(480,267)** | (1,945,081) |
| ការប្រាក់សុទ្ធត្រូវទទួល | **1,873,213** | 7,562,161 | **2,039,650** | 8,260,583 |
| ប្រាក់សំណងត្រូវទទួល | **140,452** | 567,005 | **54,352** | 220,126 |
| ប្រាក់កក់ | **396,711** | 1,601,522 | **186,624** | 755,827 |
| ការបង់មុន | **130,099** | 525,210 | **278,542** | 1,128,095 |
| ការផ្គត់ផ្គង់ផ្សេងៗ | **108,248** | 436,997 | **115,448** | 467,564 |
| ក្រុមហ៊ុនពាក់ព័ន្ធជំពាក់ (កំណត់សម្គាល់ 24) | **53,000** | 213,960 | **12,500,000** | 50,625,000 |
| ផ្សេងៗ | **229,394** | 926,064 | **66,654** | 269,947 |
| | **2,931,117** | 11,832,919 | **15,241,270** | 61,727,142 |

រាល់ទ្រព្យសកម្មផ្សេងៗទាំងអស់ ត្រូវបានរំពឹងថានឹងអាចយកត្រឡប់មកវិញក្នុងរយៈពេលមួយឆ្នាំ ក្រោយដំណាច់ឆ្នាំលើកលែងតែប្រាក់បញ្ញើចំនួន 374,473ដុល្លារអាមេរិក ទាក់ទងនឹងការជួលការិយាល័យ និងទូរម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (ATM) ដែលនឹងត្រូវបានប្រើប្រាស់លើសពីមួយឆ្នាំក្រោយដំណាច់ឆ្នាំ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 8. ទ្រព្យសកម្មអរូបី

ព័ត៌មានលម្អិតអំពីទ្រព្យសកម្មអរូបី ដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ មានដូចខាងក្រោម៖

| | 2016 | 2015 |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | |
| ដើមឆ្នាំ | 1,199,559 | 1,062,451 |
| បន្ថែម | 45,935 | 137,108 |
| ដំណាច់ឆ្នាំ | 1,245,494 | 1,199,559 |
| **រំលស់បង្គរ** | | |
| ដើមឆ្នាំ | 846,409 | 691,498 |
| រំលស់ | 103,777 | 154,911 |
| ដំណាច់ឆ្នាំ | 950,186 | 846,409 |
| **តម្លៃចុះបញ្ជីសុទ្ធ** | 295,308 | 353,150 |
| សមមូលនឹងពាន់រៀល | 1,192,158 | 1,430,258 |

## 9. ទ្រព្យសម្បត្តិ និងបរិក្ខារ

ព័ត៌មានលម្អិតអំពីទ្រព្យសម្បត្តិនិងបរិក្ខារ មានដូចខាងក្រោម៖

| | ការកែលម្អ ទ្រព្យជួល | បរិក្ខារ ការិយាល័យ | សង្ហារឹម និង បរិក្ខារភ្ជាប់ | បរិក្ខារ កុំព្យូទ័រ | យានយន្ត | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ទ្រព្យជួល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2016** | | | | | | |
| **ថ្លៃដើម** | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 2,866,885 | 2,051,176 | 447,194 | 1,202,787 | 483,020 | 7,051,062 |
| ការទិញ | 506,782 | 186,839 | 73,798 | 111,086 | 101,240 | 979,745 |
| ការលក់ចេញ | - | - | - | - | (36,200) | (36,200) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 3,373,667 | 2,238,015 | 520,992 | 1,313,873 | 548,060 | 7,994,607 |
| **រំលស់បង្គរ** | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 1,488,054 | 1,317,066 | 216,130 | 872,399 | 242,873 | 4,136,522 |
| រំលស់ | 328,935 | 271,209 | 61,484 | 182,832 | 86,972 | 931,432 |
| ការលក់ចេញ | - | - | - | - | (28,364) | (28,364) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 1,816,989 | 1,588,275 | 277,614 | 1,055,231 | 301,481 | 5,039,590 |
| **តម្លៃចុះបញ្ជីសុទ្ធ** | 1,556,678 | 649,740 | 243,378 | 258,642 | 246,579 | 2,955,017 |
| សមមូលនឹងពាន់រៀល | 6,284,309 | 2,623,000 | 982,517 | 1,044,138 | 995,440 | 11,929,404 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 9. ទ្រព្យសកម្មរូបី

| | ការកែលម្អ ទ្រព្យជួល | បរិក្ខារ ការិយាល័យ | សង្ហារឹម និង បរិក្ខារភ្ជាប់ | បរិក្ខារ កុំព្យូទ័រ | យានយន្ត | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ទ្រព្យជួល | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2015** | | | | | | |
| **ថ្លៃដើម** | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 2,856,785 | 1,618,221 | 428,751 | 1,179,295 | 358,990 | 6,442,042 |
| ការទិញ | 10,100 | 432,955 | 18,443 | 23,492 | 172,330 | 657,320 |
| ការលក់ចេញ | - | - | - | - | (48,300) | (48,300) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 2,866,885 | 2,051,176 | 447,194 | 1,202,787 | 483,020 | 7,051,062 |
| **រំលស់បង្គរ** | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2016 | 1,201,620 | 1,046,903 | 163,580 | 676,786 | 195,868 | 3,284,757 |
| រំលស់ | 286,434 | 270,163 | 52,550 | 195,613 | 85,099 | 889,859 |
| ការលក់ចេញ | - | - | - | - | (38,094) | (38,094) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 1,488,054 | 1,317,066 | 216,130 | 872,399 | 242,873 | 4,136,522 |
| **តម្លៃចុះបញ្ជីសុទ្ធ** | 1,378,831 | 734,110 | 231,064 | 330,388 | 240,147 | 2,914,540 |
| សមមូលនឹងពាន់រៀល | 5,584,266 | 2,973,146 | 935,809 | 1,338,071 | 972,595 | 11,803,887 |

## 10. ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | **2,628,331** | 10,610,572 | **2,491,595** | 10,090,960 |
| គណនីប្រាក់សន្សំ | **712,903** | 2,877,990 | **321,466** | 1,301,937 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | **228,026,250** | 920,541,971 | **259,726,266** | 1,051,891,377 |
| | **231,367,484** | 934,030,533 | **262,539,327** | 1,063,284,274 |

## 10. ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ (ត)

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំ ដូចខាងក្រោម ដោយផ្អែកទៅលើលក្ខខណ្ឌ និងប្រភេទរូបិយប័ណ្ណ។ គណនីប្រាក់បញ្ញើមានកាលកំណត់ មានរយៈពេលមួយឆ្នាំ។

| | 2016 | 2015 |
|---|---|---|
| គណនីចរន្ត | គ្មាន | គ្មាន |
| គណនីប្រាក់សន្សំ | គ្មាន | គ្មាន |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 1.10% - 2.75% | 0.65% - 3.25% |

## 11. ប្រាក់បញ្ញើរបស់អតិថិជន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | **53,777,712** | 217,100,623 | **26,259,705** | 106,351,805 |
| គណនីប្រាក់សន្សំ | **37,661,329** | 152,038,785 | **28,074,078** | 113,700,016 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | **205,832,479** | 830,945,718 | **161,865,722** | 655,556,174 |
| | **297,271,520** | 1,200,085,126 | **216,199,505** | 875,607,995 |

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ទទួលបានអត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម ដោយផ្អែកទៅលើលក្ខខណ្ឌ និងប្រភេទរូបិយប័ណ្ណ។ រាល់ប្រាក់បញ្ញើទាំងអស់ មានអាយុកាលមួយឆ្នាំលើកលែងតែប្រាក់បញ្ញើចំនួន 22,963,381ដុល្លារអាមេរិក ដែលមានអាយុកាលលើសពីមួយឆ្នាំ។

| | 2016 | 2015 |
|---|---|---|
| គណនីចរន្ត | 0.88% - 2.08% | គ្មាន |
| គណនីប្រាក់សន្សំ | 1.25% | 1.50% |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | 2.00% - 5.75% | 2.00% - 6.00% |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 12. ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការប្រាក់ត្រូវបង់ | **4,381,846** | 17,689,512 | **3,687,347** | 14,933,755 |
| ប្រាក់រង្វាន់បង្គរ | **792,000** | 3,197,304 | **806,400** | 3,265,920 |
| មូលប្បទានបត្រសម្រាប់ផាត់ទាត់ | **597,199** | 2,410,892 | **420,115** | 1,701,466 |
| ពន្ធកាត់ទុកត្រូវបង់ | **112,883** | 455,709 | **94,424** | 382,417 |
| គណនីអ្នកផ្គត់ផ្គង់ | **106,695** | 430,728 | **99,655** | 403,603 |
| ពន្ធលើប្រាក់បៀវត្សរ៍ត្រូវបង់ | **21,370** | 86,271 | **20,600** | 83,430 |
| ផ្សេងៗ (*) | **2,186,452** | 8,826,706 | **604,176** | 2,446,913 |
| | **8,198,445** | 33,097,122 | **5,732,717** | 23,217,504 |

(*) រួមបញ្ចូលក្នុងបំណុលផ្សេងៗ ទឹកប្រាក់ចំនួន ១,០៥៧,៣៧៣ដុល្លារអាមេរិក គឺជាការផ្ទេរប្រាក់ពីក្រៅប្រទេស ដែលនឹងត្រូវដាក់ចូលគណនីប្រាក់បញ្ញើអតិថិជនជាក់លាក់។

រាល់បំណុលខាងលើទាំងអស់ ត្រូវបានរំពឹងថានឹងត្រូវទូទាត់ក្នុងរយៈពេលមួយឆ្នាំ ក្រោយដំណាច់ឆ្នាំ។

## 13. ដើមទុន

| | 2016 | | | 2015 | | |
|---|---|---|---|---|---|---|
| | ភាគហ៊ុន ('000) | ដុល្លារអាមេរិក | ពាន់រៀល | ភាគហ៊ុន ('000) | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យដើមគ្រា | 67,000 | 67,000,000 | 271,350,000 | 52,000 | 52,000,000 | 211,900,000 |
| ការបញ្ចូលដើមទុន | - | - | - | 15,000 | 15,000,000 | 60,750,000 |
| លម្អៀងបណ្តោះអាសន្ន | - | - | (871,000) | - | - | (1,300,000) |
| សមតុល្យចុងគ្រា | 67,000 | 67,000,000 | 270,479,000 | 67,000 | 67,000,000 | 271,350,000 |

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 ដើមទុនដែលបានអនុម័តរបស់ធនាគារ មានចំនួន៦៧លានដុល្លារអាមេរិក ស្មើនឹង67លាននៃភាគហ៊ុនធម្មតាដែលមានតម្លៃចារិក 1ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ រាល់ភាគហ៊ុនដែលបានចេញផ្សាយទាំងអស់ ត្រូវបានអនុម័ត និងបានបង់សព្វគ្រប់។

## 14. ចំណូលការប្រាក់

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់មកពី៖ | | | | |
| ឥណទាន និងបុរេប្រទានអតិថិជន | **30,382,849** | 122,655,561 | **22,616,731** | 91,597,761 |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **2,290,414** | 9,246,401 | **1,836,591** | 7,438,193 |
| សមតុល្យនៅធនាគារកណ្តាល | **56,717** | 228,967 | **15,614** | 63,237 |
| មូលបត្រដែលអាចជួញដូរបាន | **10,181** | 41,101 | **25,734** | 104,223 |
| | **32,740,161** | 132,172,030 | **24,494,670** | 99,203,414 |

## 15. ចំណាយការប្រាក់

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយការប្រាក់ទៅលើ៖ | | | | |
| គណនីប្រាក់បញ្ញើមានកាលកំណត់ | **14,060,003** | 56,760,232 | **9,433,368** | 38,205,140 |
| គណនីសន្សំ | **363,806** | 1,468,685 | **352,898** | 1,429,237 |
| គណនីចរន្ត | **125,134** | 505,166 | **13,453** | 54,485 |
| | **14,548,943** | 58,734,083 | **9,799,719** | 39,688,862 |

## 16. ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្រៃដំណើរការឥណទាន | **1,157,790** | 4,673,998 | **1,783,572** | 7,223,467 |
| កម្រៃជើងសារ | **426,840** | 1,723,153 | **390,665** | 1,582,192 |
| កម្រៃផ្តល់កិច្ចសន្យាឥណទាន | **186,539** | 753,058 | **159,044** | 644,128 |
| ផ្សេងៗ | **789,833** | 3,188,556 | **661,020** | 2,677,132 |
| | **2,561,002** | 10,338,765 | **2,994,301** | 12,126,919 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 17. ចំណាយបុគ្គលិក

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | **2,566,632** | 10,361,493 | **2,346,380** | 9,502,839 |
| ប្រាក់រង្វាន់ និងប្រាក់លើកទឹកចិត្ត | **553,880** | 2,236,014 | **851,049** | 3,446,748 |
| អត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ | **255,708** | 1,032,293 | **250,658** | 1,015,165 |
| | **3,376,220** | 13,629,800 | **3,448,087** | 13,964,752 |

## 18. ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ (កំណត់សម្គាល់9) | **931,432** | 3,760,191 | **889,859** | 3,603,929 |
| រំលស់ទ្រព្យសកម្មអរូបី (កំណត់សម្គាល់8) | **103,777** | 418,948 | **154,911** | 627,390 |
| | **1,035,209** | 4,179,139 | **1,044,770** | 4,231,319 |

## 19. ចំណាយរដ្ឋបាល និងចំណាយប្រតិបត្តិការ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការជួលអគារ | **618,632** | 2,497,417 | **522,572** | 2,116,417 |
| ការជួសជុល និងការថែទាំ | **337,778** | 1,363,610 | **341,972** | 1,384,987 |
| ការបោះពុម្ព ទីផ្សារ និងការផ្សព្វផ្សាយ | **319,090** | 1,288,166 | **134,694** | 545,511 |
| កម្រៃអាជ្ញាប័ណ្ណ | **260,459** | 1,051,473 | **238,467** | 965,791 |
| សន្តិសុខ | **224,612** | 906,759 | **177,773** | 719,981 |
| ទឹក-ភ្លើង | **222,071** | 896,501 | **201,154** | 814,674 |
| ធានារ៉ាប់រង | **146,363** | 590,867 | **119,288** | 483,116 |
| សម្ភារការិយាល័យ និងការបោះពុម្ពផ្សេងៗ | **135,731** | 547,946 | **101,281** | 410,188 |
| ការអភិវឌ្ឍអាជីវកម្ម | **120,773** | 487,561 | **84,504** | 342,241 |
| ការទំនាក់ទំនង | **98,056** | 395,852 | **93,678** | 379,396 |
| យានយន្ត និងចំណាយដំណើរការយានយន្ត | **89,852** | 362,733 | **98,063** | 397,155 |
| ប៉ាតង់ និងពន្ធអាករផ្សេងៗ | **85,017** | 343,214 | **100,676** | 407,738 |
| កម្រៃរបស់ក្រុមប្រឹក្សាភិបាល | **78,200** | 315,693 | **79,682** | 322,712 |
| ចំណាយអ្នកជំនាញ និងចំណាយពាក់ព័ន្ធផ្សេងៗ | **68,870** | 278,028 | **44,916** | 181,910 |
| សម្ភារសម្រាប់សកម្មភាពធនាគារ | **42,053** | 169,768 | **39,209** | 158,796 |
| កម្រៃសេវាធនាគារ | **30,221** | 122,002 | **28,689** | 116,190 |
| ការផ្គត់ផ្គង់ផ្សេងៗ | **16,356** | 66,029 | **18,368** | 74,390 |
| ចំណាយផ្សេងៗ | **118,286** | 477,521 | **75,069** | 304,030 |
| | **3,012,420** | 12,161,140 | **2,500,055** | 10,125,223 |

## 20. ពន្ធ

(ក) ពន្ធពន្យារទ្រព្យសកម្ម

ពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបានវិភាគដូចខាងក្រោមៈ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធពន្យារទ្រព្យសកម្ម | **716,595** | 2,892,894 | **272,337** | 1,102,965 |
| បំណុលពន្ធពន្យារ | **(78,705)** | (317,732) | **(120,817)** | (489,309) |
| | **637,890** | 2,575,162 | **151,520** | 613,656 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 20. ពន្ធ (ត)

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្មសុទ្ធ មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យដើមឆ្នាំ | 151,520 | 613,656 | - | - |
| បន្ទុកទៅក្នុងរបាយការណ៍លទ្ធផល | 486,370 | 1,963,476 | 151,520 | 613,656 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,970) | - | - |
| សមតុល្យចុងឆ្នាំ | 637,890 | 2,575,162 | 151,520 | 613,656 |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម/(បំណុល) ក្នុងឆ្នាំ មានដូចខាងក្រោម៖

| | សំវិធានធន ឥណទាន បាត់បង់ទូទៅ | រំលស់ពន្លឿន ទ្រព្យសកម្មរូបី និង អរូបី | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2015 | - | - | - |
| បន្ទុកទៅក្នុងរបាយការណ៍លទ្ធផល | 272,337 | (120,817) | 151,520 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2015 | 272,337 | (120,817) | 151,520 |
| សមមូលជាពាន់រៀល | 1,102,965 | (489,309) | 613,656 |
| នាថ្ងៃទី01 ខែមករា ឆ្នាំ2016 | 272,337 | (120,817) | 151,520 |
| បន្ទុកទៅក្នុងរបាយការណ៍លទ្ធផល | 444,258 | 42,112 | 486,370 |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2016 | 716,595 | (78,705) | 637,890 |
| សមមូលជាពាន់រៀល | 2,892,894 | (317,732) | 2,575,162 |

## 20. ពន្ធ (ត)

(ខ) បំណុលពន្ធលើប្រាក់ចំណេញ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យដើមឆ្នាំ | **1,722,942** | 6,977,915 | **1,396,643** | 5,691,320 |
| បន្ទុកក្នុងឆ្នាំ | **2,213,981** | 8,937,841 | **2,288,803** | 9,269,652 |
| ពន្ធលើប្រាក់ចំណេញបានបង់ | **(2,326,525)** | (9,392,181) | **(1,962,504)** | (7,948,141) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | **-** | (22,398) | **-** | (34,916) |
| សមតុល្យចុងឆ្នាំ | **1,610,398** | 6,501,177 | **1,722,942** | 6,977,915 |

(គ) ចំណាយពន្ធលើប្រាក់ចំណេញ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | | |
| ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ | **2,213,981** | 8,937,841 | **2,288,803** | 9,269,652 |
| ពន្ធពន្យារ | **(486,370)** | (1,963,476) | **(151,520)** | (613,656) |
| | **1,727,611** | 6,974,365 | **2,137,283** | 8,655,996 |

ការផ្ទៀងផ្ទាត់រវាងពន្ធលើប្រាក់ចំណេញដែលបានគណនាតាមអត្រាពន្ធតាមច្បាប់ 20% ដូចបានលាតត្រដាងក្នុងរបាយការណ៍លទ្ធផល មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | **8,425,018** | **34,011,797** | **8,008,106** | **32,432,830** |
| ពន្ធគណនាតាមអត្រា 20% | **1,685,004** | 6,802,361 | **1,601,621** | 6,486,566 |
| ផលប៉ះពាល់ពន្ធ ទាក់ទិននឹង៖ | | | | |
| ចំណាយដែលមិនអាចកាត់កងតាមច្បាប់ពន្ធ | **42,607** | 172,004 | **535,662** | 2,169,430 |
| **ចំណាយពន្ធលើប្រាក់ចំណេញ** | **1,727,611** | 6,974,365 | **2,137,283** | 8,655,996 |

អនុលោមតាមច្បាប់សារពើពន្ធកម្ពុជា ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញសាជីវកម្ម តាមអត្រាមួយណា ដែលខ្ពស់ជាងគេ រវាងពន្ធលើប្រាក់ចំណេញតាមអត្រា20% នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមា1%។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 21. សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណេញមុនបង់ពន្ធ | **8,425,018** | 34,011,797 | **8,008,106** | 32,432,830 |
| និយ័តកម្មៈ | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី(កំណត់សម្គាល់18) | **1,035,209** | 4,179,139 | **1,044,770** | 4,231,319 |
| សំវិធានធនឥណទានបាត់បង់ (កំណត់សម្គាល់ 6) | **5,078,809** | 20,503,152 | **2,823,668** | 11,435,855 |
| ចំណេញពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | **(6,964)** | (28,114) | **(64,574)** | (261,524) |
| ចំណូលការប្រាក់សុទ្ធ | **(18,191,218)** | (73,437,947) | **(14,694,951)** | (59,514,552) |
| ខាតប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | **(3,659,146)** | (14,771,973) | **(2,882,981)** | (11,676,072) |
| បម្រែបម្រួលដើមទុនបង្វិល | | | | |
| សមតុល្យនៅធនាគារកណ្តាល | **(5,568,593)** | (22,480,410) | **(32,100,940)** | (130,008,807) |
| មូលបត្រដែលអាចជួញដូរបាន | **-** | - | **15,000,000** | 60,750,000 |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **(16,000,000)** | (64,592,000) | **12,500,000** | 50,625,000 |
| ឥណទាន និងបុរេប្រទានអតិថិជន | **(14,031,897)** | (56,646,768) | **(127,832,457)** | (517,721,451) |
| ទ្រព្យសកម្មផ្សេងៗ | **(356,284)** | (1,438,319) | **(811,381)** | (3,286,093) |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **(31,171,843)** | (125,840,730) | **115,129,266** | 466,273,527 |
| ប្រាក់បញ្ញើរបស់អតិថិជន | **81,072,015** | 327,287,725 | **77,407,770** | 313,501,468 |
| បំណុលផ្សេងៗ | **1,771,230** | 7,150,456 | **1,123,567** | 4,550,446 |
| **សាច់ប្រាក់បានពីប្រតិបត្តិការ** | **12,055,482** | 48,667,981 | **57,532,844** | 233,008,018 |

## 22. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមាន៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | **6,256,945** | 25,259,287 | **3,805,590** | 15,412,640 |
| សមតុល្យនៅធនាគារកណ្តាល (កំណត់សម្គាល់4) ៖ | | | | |
| គណនីចរន្ត | **81,790,980** | 330,190,186 | **53,960,362** | 218,539,467 |
| គណនីជាត់ទាត់ | **597,199** | 2,410,892 | **420,115** | 1,701,466 |
| មូលបត្រដែលអាចជួញដូរបាន (កាលកំណត់បីខែ ឬតិចជាង) | **3,049,542** | 12,311,001 | **2,493,828** | 10,100,003 |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | | | |
| គណនីចរន្ត (កំណត់សម្គាល់ 5) | **27,751,265** | 112,031,857 | **6,495,806** | 26,308,014 |
| គណនីប្រាក់បញ្ញើមានកាលកំណត់ (កាលកំណត់បីខែ ឬតិចជាង) | **46,000,000** | 185,702,000 | **58,000,000** | 234,900,000 |
| | **165,445,931** | 667,905,223 | **125,175,701** | 506,961,590 |

## 23. កិច្ចសន្យា និងយថាភាព

(ក) កិច្ចសន្យាពន្យារឥណទាន

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណែកឥណទានវិបារូបន៍ដែលមិនបានប្រើប្រាស់ | **25,106,102** | 101,353,334 | **17,011,029** | 68,894,667 |
| លិខិតឥណទាន | **1,052,755** | 4,249,972 | **614,936** | 2,490,491 |
| លិខិតធានាផ្សេងៗ | **5,569,512** | 22,484,120 | **2,475,739** | 10,026,743 |
| | **31,728,369** | 128,087,426 | **20,101,704** | 81,411,901 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 23. កិច្ចសន្យា និងយថាភាព (ត)

(ខ) កិច្ចសន្យាភតិសន្យាប្រតិបត្តិដែលមិនអាចលុបចោលបាន

ធនាគារមានកិច្ចសន្យាភតិសន្យាប្រតិបត្តិមិនអាចលុបចោលបាន ចំពោះការជួលអគារការិយាល័យរបស់ខ្លួន។

ចំណាយភតិសន្យាអប្បបរមាសរុបនាពេលអនាគត ក្រោមកិច្ចសន្យាភតិសន្យាប្រតិបត្តិដែលមិនអាចលុបចោលបានមានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ភតិសន្យាអប្បបរមានាពេលអនាគតដែលត្រូវបង់៖ | | | | |
| - មិនលើសមួយឆ្នាំ | **707,048** | 2,854,353 | **590,732** | 2,392,465 |
| - លើសមួយឆ្នាំប៉ុន្តែមិនលើសប្រាំឆ្នាំ | **1,412,099** | 5,700,644 | **1,528,534** | 6,190,563 |
| - លើសប្រាំឆ្នាំឡើងទៅ | **679,446** | 2,742,924 | **536,163** | 2,171,459 |
| | **2,798,593** | 11,297,921 | **2,655,429** | 10,754,487 |

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ

(ក) ភាគីពាក់ព័ន្ធ និងទំនាក់ទំនង

ទំនាក់ទំនង និងភាគីពាក់ព័ន្ធរបស់ធនាគារ មានដូចខាងក្រោម៖

| ទំនាក់ទំនង | ភាគីពាក់ព័ន្ធ |
|---|---|
| ក្រុមហ៊ុនមេធំ | RHB Bank Berhad |
| ក្រុមហ៊ុនភាគីពាក់ព័ន្ធ | ក្រុមហ៊ុនទាំងអស់នៅក្នុងចង្កោមក្រុមហ៊ុនមេធំចុងក្រោយ |
| បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ | សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់របស់ធនាគារ ដែលមានសិទ្ធិធ្វើការសម្រេចចិត្តសំខាន់ៗ ពាក់ព័ន្ធទៅនឹងគោលដៅយុទ្ធសាស្រ្តរបស់ ធនាគារ និងបុគ្គលិក គណៈគ្រប់គ្រងជាន់ខ្ពស់ (រួមទាំងសមាជិក គ្រួសារជិតដិតរបស់ពួកគេផងដែរ)។ |

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

(ខ) ទឹកប្រាក់ជំពាក់ភាគីពាក់ព័ន្ធ សមតុល្យ និងប្រតិបត្តិការភាគីពាក់ព័ន្ធ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទឹកប្រាក់ជំពាក់ក្រុមហ៊ុនមេ៖** | | | | |
| - ប្រាក់បញ្ញើមានកាលកំណត់ | **134,000,000** | 540,958,000 | **179,000,000** | 724,950,000 |
| - ការប្រាក់ត្រូវបង់ | **358,389** | 1,446,816 | **430,921** | 1,745,231 |
| | **134,358,389** | 542,404,816 | **179,430,921** | 726,695,231 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| - ចំណាយការប្រាក់ | **3,742,145** | 15,107,039 | **2,126,240** | 8,611,272 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទឹកប្រាក់ជំពាក់ក្រុមហ៊ុន ភាគីពាក់ព័ន្ធ៖** | | | | |
| - គណនីចរន្ត | **113,016** | 456,246 | **7,086,634** | **28,700,868** |
| - ប្រាក់បញ្ញើមានកាលកំណត់ | **8,596,025** | 34,702,153 | **1,891,398** | 7,660,162 |
| - ការប្រាក់ត្រូវបង់ | **88,716** | 358,146 | **83,416** | 337,835 |
| | **8,797,757** | 35,516,545 | **9,061,448** | 36,698,865 |

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| - ចំណាយការប្រាក់ | **291,766** | 1,177,859 | **1,039** | 4,208 |
| - ចំណូលពីកម្រៃក្នុងការណែនាំអតិថិជនឲ្យគេ | **250** | 1,009 | **1,500** | 6,075 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 24. ប្រតិបត្តិការ និងសមតុល្យភាគីពាក់ព័ន្ធ (ត)

(គ) ទឹកប្រាក់ទទួលបានពីភាគីពាក់ព័ន្ធ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទឹកប្រាក់ភាគីពាក់ព័ន្ធជំពាក់ | 27,304 | 110,226 | 12,500,000 | 50,625,000 |
| ទឹកប្រាក់ក្រុមហ៊ុនមេជំពាក់ | 25,696 | 103,734 | - | - |
| | 53,000 | 213,960 | 12,500,000 | 50,625,000 |

នេះជាទឹកប្រាក់ដែលភាគីពាក់ព័ន្ធ និងក្រុមហ៊ុនមេជំពាក់ ដែលជាចម្បងគឺទាក់ទងនឹងចំណាយផ្សេងៗដែលធនាគារបានបង់ជំនួស ហើយនឹងត្រូវសងមកវិញដោយភាគីពាក់ព័ន្ធ និងក្រុមហ៊ុនមេ។

(ឃ) លាភការរបស់បុគ្គលិកគណៈគ្រប់គ្រងសំខាន់ៗ

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍រយៈពេលខ្លី | 618,346 | 2,496,263 | 598,488 | 2,423,876 |

(ង) លាភការរបស់ក្រុមប្រឹក្សាភិបាល

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្រៃរបស់ក្រុមប្រឹក្សាភិបាល | 78,200 | 315,693 | 79,682 | 322,712 |

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

សកម្មភាពអាជីវកម្មរបស់ធនាគារប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួន ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល។ អាជីវកម្មហិរញ្ញវត្ថុភាគច្រើនប្រឈមមុខនឹងហានិភ័យ ក្នុងនោះហានិភ័យប្រតិបត្តិការគឺជាផលវិបាកដែលពិបាកជៀសរួចណាស់ក្នុងដំណើរការអាជីវកម្ម។ ធនាគារមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ (derivative financial instrument) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

សកម្មភាពអាជីវកម្មរបស់ធនាគារប្រឈមនឹងហានិភ័យហិរញ្ញវត្ថុផ្សេងៗមួយចំនួន ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ (រួមមានហានិភ័យរូបិយប័ណ្ណ ហានិភ័យអត្រាការប្រាក់ ហានិភ័យតម្លៃ) និងហានិភ័យសាច់ប្រាក់ងាយស្រួល។ អាជីវកម្មហិរញ្ញវត្ថុភាគច្រើនប្រឈមមុខនឹងហានិភ័យ ក្នុងនោះហានិភ័យប្រតិបត្តិការគឺជាផលវិបាកដែលពិបាកជៀសរួចណាស់ក្នុងដំណើរការអាជីវកម្ម។ ធនាគារមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិទស្សន៍ (derivative financial instrument) ដើម្បីគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ខ្លួននោះទេ។

ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាសិទ្ធិកិច្ចសន្យាដើម្បីទទួលបានសាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀត ពីអង្គភាពមួយផ្សេងទៀត។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជាឥណទាន និងគណនីត្រូវទទួលផ្សេងៗដែលរួមបញ្ចូលសាច់ប្រាក់ ក្នុងដៃ សមតុល្យនៅធនាគារកណ្តាល សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ឥណទានអតិថិជន និងទ្រព្យសកម្ម ផ្សេងទៀត។

បំណុលហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចកិច្ចសន្យាក្នុងការផ្តល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀត ពីអង្គភាពមួយផ្សេងទៀត។ បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ថាជាបំណុលផ្សេងៗ ដែលរួមបញ្ចូលប្រាក់បញ្ញើរបស់ធនាគារ និង គ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើរបស់អតិថិជន ប្រាក់កម្ចី និងបំណុលផ្សេងៗទៀត។

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ក្នុងដៃ | **6,256,945** | 25,259,287 | **3,805,590** | 15,412,640 |
| សមតុល្យនៅធនាគារកណ្តាល (*) | **85,437,721** | 344,912,080 | **56,874,305** | 230,340,935 |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **115,751,265** | 467,287,857 | **90,495,806** | 366,508,014 |
| ឥណទាន និងបុរេប្រទានអតិថិជន | **347,575,673** | 1,403,162,992 | **338,622,585** | 1,371,421,469 |
| ទ្រព្យសកម្មផ្សេងៗ | **2,435,376** | 9,831,613 | **14,805,626** | 59,962,785 |
| | **557,456,980** | 2,250,453,829 | **504,603,912** | 2,043,645,843 |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **231,367,484** | 934,030,533 | **262,539,327** | 1,063,284,274 |
| ប្រាក់បញ្ញើរបស់អតិថិជន | **297,271,520** | 1,200,085,126 | **216,199,505** | 875,607,995 |
| បំណុលផ្សេងៗ | **5,572,949** | 22,497,995 | **5,617,693** | 22,751,657 |
| | **534,211,953** | 2,156,613,654 | **484,356,525** | 1,961,643,926 |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ** | **23,245,027** | 93,840,175 | **20,247,387** | 82,001,917 |

(*) មិនរាប់បញ្ចូលប្រាក់បញ្ញើបម្រុង និងប្រាក់តម្កល់ធានាលើដើមទុននៅធនាគារកណ្តាល។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យដែលបណ្តាលមកពីការខាតបង់ផ្នែកហិរញ្ញវត្ថុដែលអតិថិជន ឬភាគីដៃគូ ទីផ្សាររបស់ធនាគារ និងធ្វើឲ្យខកខាន មិនបានបំពេញកាតព្វកិច្ចសងបំណុលតាមកិច្ចសន្យាឲ្យធនាគារ។ ហានិភ័យឥណទានភាគច្រើនកើតឡើងពីការផ្តល់ឥណទាន និងបុរេប្រទាន និង កិច្ចសន្យាឥណទានដែលកើតមកពីសកម្មភាពនៃការផ្តល់ប្រាក់កម្ចី។

ហានិភ័យឥណទាន គឺជាហានិភ័យធំជាងគេតែមួយគត់ក្នុងអាជីវកម្មធនាគារ ហេតុនេះគណៈគ្រប់គ្រងរៀបចំហានិភ័យឥណទានរបស់ខ្លួន យ៉ាងប្រុងប្រយ័ត្ន។

(ក) <u>ការវាស់វែងហានិភ័យឥណទាន</u>

ធនាគារបានបង្កើតគោលការណ៍ហានិភ័យឥណទានស្នូល (Core Credit Risk Policy) ដែលត្រូវបានរៀបចំឡើងដើម្បីអភិបាល នូវរាល់សកម្មភាពក្នុងការធានារ៉ាប់រងហានិភ័យរបស់ធនាគារ។ ការបន្តឥណទានត្រូវបានអភិបាលដោយកម្មវិធីឥណទាន ដែល បានរៀបចំគម្រោងពិសេសសម្រាប់ផលិតផល ឬសំពៀតឥណទានពិសេស រាប់ទាំងទីផ្សារគោលដៅ កាលកំណត់ និងលក្ខខណ្ឌ ឯកសារសម្អាង និងនីតិវិធីនៅក្រោមផលិតផលឥណទានដែលនឹងត្រូវវិភាគ និងផ្តល់ជូនអតិថិជន។

ធនាគារក៏ធានាអះអាងថាខ្លួនបានបែងចែកតួនាទីច្បាស់លាស់ រវាងកាតព្វកិច្ចអ្នកលើកសំណើឥណទាន (loan originators) អ្នកវិភាគ ឥណទាន (evaluators) និងកម្រិតការអនុម័តឥណទាន (approving authorities)។

(ខ) <u>ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍បន្ថយហានិភ័យ</u>

ធនាគារគ្រប់គ្រងកម្រិតហានិភ័យ និងផ្តោតការយកចិត្តទុកដាក់លើហានិភ័យឥណទាន នៅពេលដែលហានិភ័យត្រូវបានរកឃើញ ជាពិសេសទៅលើភាគីដៃគូជាឯកត្តជន និងភាគីដៃគូជាក្រុម ព្រមទាំងសហគ្រាសនានា។

ធនាគាររៀបចំរចនាសម្ព័ន្ធតាមកម្រិតនៃហានិភ័យឥណទាន ដោយដាក់កម្រិតលើចំនួនទឹកប្រាក់នៃហានិភ័យដែលអាចទទួលយកបាន ទាក់ទងនឹងអ្នកខ្ចីប្រាក់ជាឯកត្តជន ឬអ្នកខ្ចីប្រាក់ជាក្រុម និងតាមផ្នែកអាជីវកម្ម។ ហានិភ័យនេះត្រូវបានត្រួតពិនិត្យតាមមូលដ្ឋានវង្វិលជុំ ហើយនឹងត្រូវបានត្រួតពិនិត្យឡើងវិញប្រចាំឆ្នាំ ឬញឹកញាប់ជាងនេះតាមការចាំបាច់។ ការដាក់កំណត់លើកម្រិតហានិភ័យឥណទាន តាមផលិតផល និងតាមវិស័យអាជីវកម្ម ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ហានិភ័យធំត្រូវបានកំណត់និយមន័យដោយធនាគារកណ្តាល ថាជាហានិភ័យឥណទានទូទៅចំពោះអ្នកទទួលផលជាឯកត្តជន ដែលលើសពី10%នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ យោងតាមលក្ខខណ្ឌនៃប្រកាសលេខធ7-06-226ប្រ.ក.របស់ធនាគារកណ្តាល តម្រូវឲ្យធនាគាររក្សាឲ្យបានគ្រប់ពេលវេលានូវអនុបាតអតិបរមាចំនួន 20% រវាងហានិភ័យឥណទានទូទៅរបស់ធនាគារ ដែលចេញពីប្រតិបត្តិការជាមួយនឹងអ្នកទទួលផលជាឯកត្តជននីមួយៗ និងមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។ ហានិភ័យឥណទានធំសរុប មិនត្រូវឲ្យលើសពី 300% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ។

ធនាគារបានប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើន ដើម្បីកាត់បន្ថយហានិភ័យឥណទាន រួមមានការតម្រូវឲ្យអ្នកខ្ចីប្រាក់ ដាក់វត្ថុបញ្ចាំលើឥណទាន និងបុរេប្រទានដែលធនាគារផ្តល់ឲ្យខ្ចី។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(គ) គោលការណ៍សំវិធានធន និងការថយចុះតម្លៃ

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន អនុលោមតាមប្រកាសពាក់ព័ន្ធដូចបានបញ្ជាក់នៅក្នុងកំណត់សម្គាល់2.6 នៃរបាយការណ៍ហិរញ្ញវត្ថុ។

ការធ្វើចំណាត់ថ្នាក់ឥណទាន និងការធ្វើសំវិធានធនឥណទានបាត់បង់ ត្រូវបានកំណត់ដោយគិតទៅលើរយៈពេលហួសកំណត់សងនៃឥណទាន និងបុរេប្រទានអតិថិជន និងកត្តាពាក់ព័ន្ធផ្សេងទៀត។

(ឃ) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន

តារាងខាងក្រោមនេះ បង្ហាញពីហានិភ័យឥណទានអតិបរមារបស់ធនាគារ ដោយមិនគិតលើវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងទៀតឡើយ។ ចំពោះទ្រព្យសកម្មក្នុងតារាងតុល្យការ ហានិភ័យដែលបានបង្ហាញខាងលើផ្អែកទៅលើតម្លៃយោងសុទ្ធ។ ចំពោះកិច្ចសន្យាពាក់ព័ន្ធនឹងឥណទាន ហានិភ័យឥណទានអតិបរមាគឺជាចំនួនទាំងស្រុងនៃកញ្ចប់ឥណទានដែលមិនអាចកែប្រែបាន។

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្មក្នុងតារាងតុល្យការ** | | | | |
| សមតុល្យនិងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **115,751,265** | 467,287,857 | **90,495,806** | 366,508,014 |
| ឥណទាននិងបុរេប្រទានអតិថិជន | **347,575,673** | 1,403,162,992 | **338,622,585** | 1,371,421,469 |
| ទ្រព្យសកម្មផ្សេងៗ | **2,435,376** | 9,831,613 | **14,805,626** | 59,962,785 |
| | **465,762,314** | 1,880,282,462 | **443,924,017** | 1,797,892,268 |
| **ទ្រព្យសកម្មក្រៅតារាងតុល្យការ** | | | | |
| កិច្ចសន្យាផ្សេងៗ | **31,728,369** | 128,087,426 | **20,101,704** | 81,411,901 |
| | **497,490,683** | 2,008,369,888 | **464,025,721** | 1,879,304,169 |

ប្រសិនបើមានលទ្ធភាព ធនាគារនឹងចរចាជាមួយភាគីដៃគូរបស់ខ្លួនអំពីវត្ថុបញ្ចាំ ដើម្បីកាត់បន្ថយហានិភ័យឥណទាន។ ក្នុងការវាយតម្លៃពីភាពដែលអាចទទួលយកបាននៃវត្ថុបញ្ចាំ ធនាគារគិតពិចារណាទៅលើភាពដែលអាចដាក់លក់លើទីផ្សារបាន នៃវត្ថុបញ្ចាំក៏ដូចជាភាពពេញលេញនៃទំហំបំណុល។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ និងការបង្កើនឥណទានផ្សេងៗ ដែលធនាគារទទួលបានចំពោះការ ផ្តល់ឥណទាននិងបុរេប្រទានអតិថិជនរបស់ខ្លួន រួមមានទ្រព្យសម្បត្តិ និងការធានាផ្សេងៗ។ ទ្រព្យសម្បត្តិទាំងឡាយត្រូវបានវាយតម្លៃពីមួយគ្រាទៅមួយគ្រា ដោយផ្អែកទៅតាមការវាយតម្លៃរបស់អ្នកវាយតម្លៃឯករាជអាជីព។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ឃ) ហានិភ័យឥណទានអតិបរមាមុនការកាន់កាប់វត្ថុបញ្ចាំ ឬមុនការបង្កើនឥណទាន (ត)

គណៈគ្រប់គ្រងមានជំនឿថាខ្លួនមានលទ្ធភាពបន្តការគ្រប់គ្រង និងទ្រទ្រង់ហានិភ័យឥណទានរបស់ធនាគារដែល បណ្តាលមកពីឥណទាន និងបុរេប្រទាន ឲ្យស្ថិតក្នុងកម្រិតអប្បបរមាតាមវិធីដូចខាងក្រោម៖

- ប្រមាណ 99.99% (2015 ៖ 99.99%) នៃឥណទាននិងបុរេប្រទានរបស់ធនាគារ ត្រូវបានធានាដោយវត្ថុបញ្ចាំ និង
- ធនាគារមាននីតិវិធីវាយតម្លៃឥណទានយ៉ាងសមស្រប ក្នុងការផ្តល់ ឥណទាន និងបុរេប្រទានជូនអតិថិជន។

(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ

ឥណទាន និងបុរេប្រទាន

គិតត្រឹមកាលបរិច្ឆេទនៃតារាងតុល្យការ ហានិភ័យឥណទានរបស់ធនាគារ ដែលកើតពីឥណទាននិងបុរេប្រទានអតិថិជន (ដោយមិនគិតវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងៗ និងមិនគិតដល់សំវិធានធនឥណទានបាត់បង់) មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ឥណទាន និងបុរេប្រទានសុទ្ធ៖** | | | | |
| មិនហួសកាលកំណត់ | | | | |
| និងមិនថយចុះតម្លៃ | **341,283,086** | 1,377,759,818 | **332,589,941** | 1,346,989,257 |
| ហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃ | **4,386,634** | 17,708,841 | **4,960,037** | 20,088,151 |
| ថយចុះតម្លៃ | **1,905,953** | 7,694,333 | **1,072,607** | 4,344,061 |
| | **347,575,673** | 1,403,162,992 | **338,622,585** | 1,371,421,469 |

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ បណ្តាទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ដែលធនាគារបានកាន់កាប់ គឺមិនបានហួសកាលកំណត់សង ឬថយចុះតម្លៃនោះទេ។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ង) គុណភាពឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ

ការវិភាគអំពីសមតុល្យ និងការដាក់ប្រាក់របស់ធនាគារ នៅតាមបណ្តាធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ តាមប្រទេសនៃភាគីដៃគូរបស់ខ្លួន មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ក្នុងប្រទេសកម្ពុជា៖** | | | | |
| ធនាគារពាណិជ្ជ | **88,155,520** | 355,883,834 | **84,226,359** | 341,116,754 |
| **ក្រៅប្រទេសកម្ពុជា៖** | | | | |
| ធនាគារពាណិជ្ជ | **27,595,745** | 111,404,023 | **6,269,447** | 25,391,260 |
| | **115,751,265** | 467,287,857 | **90,495,806** | 366,508,014 |

ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗរបស់ធនាគារ ជាចម្បងរួមមាន ការប្រាក់ត្រូវទទួលចំពោះការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់តម្កល់ ដែលអាចដកមកវិញបាន ដែលធនាគារបានដាក់តម្កល់ចំពោះការជួលអគារការិយាល័យ។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ( ត )

### 25.1 ហានិភ័យឥណទាន ( ត )

(ច) គុណភាពឥណទាននៃឥណទាន និងបុរេប្រទានអតិថិជន

(i) ឥណទាន និងបុរេប្រទានដែលហួសកាលកំណត់សង ប៉ុន្តែមិនថយចុះតម្លៃ

ការវិភាគអំពីអាយុកាលឥណទាន និងបុរេប្រទានដែលហួសកាលកំណត់សង ប៉ុន្តែមិនថយចុះតម្លៃ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ (ដោយមិនគិតលើវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងៗ) មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ហួសកាលកំណត់សងពី៖** | | | | |
| - < 30 ថ្ងៃ | **3,272,843** | 13,212,467 | **1,815,394** | 7,352,346 |
| - 30 ថ្ងៃ < 60 ថ្ងៃ | **674,631** | 2,723,485 | **2,655,520** | 10,754,856 |
| - 60 ថ្ងៃ < 90 ថ្ងៃ | **574,829** | 2,320,585 | **644,756** | 2,611,263 |
| | **4,522,303** | 18,256,537 | **5,115,670** | 20,718,465 |
| **ដក៖ សំវិធានធន** | **(135,669)** | (547,696) | **(155,633)** | (630,314) |
| | **4,386,634** | 17,708,841 | **4,960,037** | 20,088,151 |

ឥណទានដែលហួសកាលកំណត់សង30ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង90ថ្ងៃ ត្រូវបានចាត់ថ្នាក់ជាប្រភេទឥណទានធម្មតា ដែលត្រូវធ្វើសំវិធានធន 1% រីឯឥណទានឃ្លាំមើល ត្រូវធ្វើសំវិធានធន 3%។

ជាទូទៅឥណទាន និងបុរេប្រទានដែលផុតកំណត់សងតិចជាង90ថ្ងៃ មិនត្រូវបានចាត់ទុកថាថយចុះតម្លៃនោះទេ លុះត្រាតែមានព័ត៌មាន ផ្សេងទៀតចង្អុលបង្ហាញផ្ទុយពីនេះ។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ii) ឥណទាននិងបុរេប្រទានដែលថយចុះតម្លៃ

ការវិភាគអំពីអាយុកាលឥណទាន និងបុរេប្រទានដែលហួសកាលកំណត់សង៩០ថ្ងៃ ឬលើសពីនេះ ដែលត្រូវបានចាត់ទុកថាថយចុះតម្លៃ (ដោយមិនគិតលើវត្ថុបញ្ចាំ ឬការបង្កើនឥណទានផ្សេងៗ) មានដូចខាងក្រោម៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ហួសកាលកំណត់សងពី៖** | | | | |
| - 90 ថ្ងៃ < 180 ថ្ងៃ | **1,909,721** | 7,709,544 | **415,229** | 1,681,677 |
| - 180 ថ្ងៃ < 360 ថ្ងៃ | **756,352** | 3,053,393 | **1,650,495** | 6,684,505 |
| - លើសពី 360 ថ្ងៃ | **6,169,696** | 24,907,063 | **925,736** | 3,749,234 |
| | **8,835,769** | 35,670,000 | **2,991,460** | 12,115,416 |
| **ដក៖ សំវិធានធន** | **(6,929,816)** | (27,975,667) | **(1,918,853)** | (7,771,355) |
| | **1,905,953** | 7,694,333 | **1,072,607** | 4,344,061 |

(ឆ) ការរឹបអូសវត្ថុបញ្ចាំ

ធនាគារកណ្តាលតម្រូវឲ្យគ្រឹះស្ថានធនាគារទាំងអស់ ធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិយកបាន ជា "ទ្រព្យសម្បត្តិរឹបអូស" នៅក្នុងតារាងតុល្យការ ប្រសិនបើមាន និងត្រូវលក់ទ្រព្យសម្បត្តិនោះចេញវិញក្នុងរយៈពេលមួយឆ្នាំ។

ក្នុងអំឡុងឆ្នាំនេះ ធនាគារមិនបានរឹបអូសទ្រព្យសកម្មណាមួយដែលបានដាក់ជាវត្ថុបញ្ចាំនោះទេ។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ជ) ការប្រមូលផ្តុំហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ

(i) វិភាគតាមផ្នែកភូមិសាស្ត្រ

ដោយវិភាគតាមទីតាំងប្រទេសនៃភាគីដៃគូ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ហានិភ័យឥណទានរបស់ធនាគារ ដែលភាគច្រើនកើតឡើងនៅក្នុងប្រទេសកម្ពុជា មានដូចខាងក្រោម៖

| | ប្រទេសកម្ពុជា | ប្រទេសផ្សេងៗ | សរុប |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2016** | | | |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **88,155,520** | 27,595,745 | **115,751,265** |
| ឥណទាន និងបុរេប្រទានអតិថិជន | **347,575,673** | - | **347,575,673** |
| ទ្រព្យសកម្មផ្សេងៗ | **2,435,376** | - | **2,435,376** |
| | **438,166,569** | 27,595,745 | **465,762,314** |
| សមមូលនឹងពាន់រៀល | **1,768,878,439** | 111,404,023 | **1,880,282,462** |
| **2015** | | | |
| សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **84,226,359** | 6,269,447 | **90,495,806** |
| ឥណទាន និងបុរេប្រទានអតិថិជន | **338,622,585** | - | **338,622,585** |
| ទ្រព្យសកម្មផ្សេងៗ | **2,305,626** | 12,500,000 | **14,805,626** |
| | **425,154,570** | 18,769,447 | **443,924,017** |
| សមមូលនឹងពាន់រៀល | **1,721,876,008** | 76,016,260 | **1,797,892,268** |

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ជ) ការប្រមូលផ្តុំហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(ii) វិភាគតាមប្រភេទអាជីវកម្ម

តារាងខាងក្រោមនេះ សង្ខេបអំពីហានិភ័យឥណទានរបស់ធនាគារតាមតម្លៃយោងសុទ្ធរបស់វា ដោយចាត់ថ្នាក់តាមប្រភេទអាជីវកម្មនៃភាគីដៃគូ។

| | សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | ឥណទាននិងបុរេប្រទានអតិថិជន | ទ្រព្យសកម្មផ្សេងៗ | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **2016** | | | | | |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 115,751,265 | 3,283,736 | 720,200 | 119,755,201 | 483,451,746 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | - | 43,280,370 | 139,718 | 43,420,088 | 175,286,895 |
| ជំនួញលក់រាយ | - | 52,947,955 | 187,175 | 53,135,130 | 214,506,520 |
| ជំនួញលក់ដុំ | - | 28,355,874 | 70,713 | 28,426,587 | 114,758,132 |
| ផលិតកម្ម | - | 26,651,820 | 198,188 | 26,850,008 | 108,393,482 |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - | 23,779,910 | 73,206 | 23,853,116 | 96,295,029 |
| ឥណទានគេហដ្ឋាន | - | 33,053,369 | 119,304 | 33,172,673 | 133,918,081 |
| សកម្មភាពក្នុងការជួល និងភតិសន្យាប្រតិបត្តិ មិនគិតការជួលអចលនទ្រព្យ | - | 30,782,433 | 97,963 | 30,880,396 | 124,664,159 |
| ការដឹកជញ្ជូន និងការស្តុកទំនិញ | - | 5,492,090 | 33,283 | 5,525,373 | 22,305,931 |
| ទឹក-ភ្លើង | - | 3,051,345 | 8,797 | 3,060,142 | 12,353,793 |
| សកម្មភាពអចលនទ្រព្យ | - | 18,884,143 | 469,226 | 19,353,369 | 78,129,551 |
| សំណង់ | - | 21,127,369 | 57,047 | 21,184,416 | 85,521,487 |
| គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុផ្សេងៗ | - | 23,299,693 | 86,134 | 23,385,827 | 94,408,584 |
| ព័ត៌មានវិទ្យានិងទូរគមនាគមន៍ | - | 1,314,586 | 3,510 | 1,318,096 | 5,321,154 |
| ផ្សេងៗ | - | 32,270,980 | 170,912 | 32,441,892 | 130,967,918 |
| | 115,751,265 | 347,575,673 | 2,435,376 | 465,762,314 | 1,880,282,462 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.1 ហានិភ័យឥណទាន (ត)

(ជ) ការប្រមូលផ្តុំហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(ii) វិភាគតាមប្រភេទអាជីវកម្ម (ត)

| | សមតុល្យ និង ការដាក់ប្រាក់ នៅធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុ ផ្សេងៗ | ឥណទាននិង បុរេប្រទាន អតិថិជន | ទ្រព្យសកម្ម ផ្សេងៗ | សរុប | |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល |
| **2015** | | | | | |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 90,495,806 | 4,831,624 | 12,927,173 | 108,254,603 | 438,431,142 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | - | 52,483,831 | 255,376 | 52,739,207 | 213,593,788 |
| ជំនួញលក់រាយ | - | 51,312,950 | 176,806 | 51,489,756 | 208,533,512 |
| ជំនួញលក់ដុំ | - | 26,055,976 | 53,572 | 26,109,548 | 105,743,669 |
| ផលិតកម្ម | - | 25,718,758 | 180,036 | 25,898,794 | 104,890,116 |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | - | 23,657,307 | 282,555 | 23,939,862 | 96,956,441 |
| ឥណទានគេហដ្ឋាន | - | 29,080,233 | 137,532 | 29,217,765 | 118,331,948 |
| សកម្មភាពក្នុងការជួល និងភតិសន្យាប្រតិបត្តិ មិនគិតការជួលអចលនទ្រព្យ | - | 34,449,364 | 115,383 | 34,564,747 | 139,987,225 |
| ការដឹកជញ្ជូន និងការស្តុកទំនិញ | - | 5,044,965 | 50,013 | 5,094,978 | 20,634,661 |
| ទឹក-ភ្លើង | - | 3,676,323 | 74,177 | 3,750,500 | 15,189,525 |
| សកម្មភាពអចលនទ្រព្យ | - | 14,885,818 | 227,143 | 15,112,961 | 61,207,492 |
| សំណង់ | - | 22,845,460 | 152,707 | 22,998,167 | 93,142,576 |
| គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុផ្សេងៗ | - | 24,040,307 | 94,408 | 24,134,715 | 97,745,596 |
| ការផ្តល់កម្ចីជាឯកត្តជន | - | 252,893 | 380 | 253,273 | 1,025,756 |
| ព័ត៌មានវិទ្យានិងទូរគមនាគមន៍ | - | 1,251,507 | 3,228 | 1,254,735 | 5,081,677 |
| ផ្សេងៗ | - | 19,035,269 | 75,137 | 19,110,406 | 77,397,144 |
| | 90,495,806 | 338,622,585 | 14,805,626 | 443,924,017 | 1,797,892,268 |

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.2 ហានិភ័យទីផ្សារ

ហានិភ័យទីផ្សារ ជាហានិភ័យដែលធ្វើឲ្យមានការប្រែប្រួលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការផ្លាស់ប្តូរតម្លៃទីផ្សារ។ ហានិភ័យទីផ្សារកើតឡើងដោយស្ថានភាពបើកទូលាយនៃអត្រាការប្រាក់ រូបិយប័ណ្ណ និងផលិតផលមូលធន ដែលទាំងអស់នេះប្រឈមមុខនឹងបម្រែបម្រួលទីផ្សារជាក់លាក់និងទូទៅ ព្រមទាំងបម្រែបម្រួលអត្រាទីផ្សារ ឬតម្លៃទីផ្សារ ដូចជាអត្រាការប្រាក់ គំលាតឥណទាន អត្រាប្តូររូបិយប័ណ្ណ និងតម្លៃមូលធនជាដើម។

(ក) ហានិភ័យតម្លៃ

ធនាគារគ្រប់គ្រងហានិភ័យនៃការប្រែប្រួលតម្លៃវិនិយោគរបស់ខ្លួន ដោយធ្វើការត្រួតពិនិត្យលើរបាយការណ៍ប្រតិបត្តិការមូលនិធិ ប្រចាំខែ។

(ខ) ហានិភ័យការប្តូររូបិយប័ណ្ណ

ធនាគារធ្វើប្រតិបត្តិការជាចម្បងជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោលរបស់ធនាគារ។ ធនាគារមិនមានហានិភ័យការប្តូររូបិយប័ណ្ណជាសារវន្តនោះទេ។

(គ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលធ្វើឲ្យមានការប្រែប្រួលលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុ ដោយសារការប្រែប្រួលអត្រាការប្រាក់លើទីផ្សារ។ កម្រិតការប្រាក់អាចកើនឡើងឬថយចុះ អាស្រ័យទៅតាមបម្រែបម្រួលមិនរំពឹងទុកនៃអត្រាការប្រាក់។ គណៈគ្រប់គ្រងធ្វើការត្រួតពិនិត្យជាប្រចាំទៅលើភាពមិនស៊ីគ្នានៃអត្រាការប្រាក់។

តារាងខាងក្រោមនេះ សង្ខេបពីហានិភ័យអត្រាការប្រាក់របស់ធនាគារ។ ទ្រព្យសកម្ម និងបំណុលតាមតាមតម្លៃយោង ត្រូវបានចាត់ថ្នាក់តាមតម្លៃក្នុងកិច្ចសន្យាដើមគ្រា ឬតាមកាលផុតកំណត់សង។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.2 ហានិភ័យទីផ្សារ (ត)

(គ) ហានិភ័យអត្រាការប្រាក់ (ត)

| | 1 ខែ | 1-3 ខែ | 3-12 ខែ | 1-5 ឆ្នាំ | លើសពី5ឆ្នាំ | មិនមាន ការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2016** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | 6,256,945 | 6,256,945 |
| សមតុល្យនៅ ធនាគារកណ្តាល | 85,437,721 | - | - | - | - | - | 85,437,721 |
| សមតុល្យ និង ការដាក់ប្រាក់នៅ ធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ | 43,751,265 | 35,000,000 | 37,000,000 | - | - | - | 115,751,265 |
| ឥណទាន និងបុរេប្រទាន អតិថិជន | 8,295,212 | 9,163,439 | 36,572,328 | 50,378,179 | 243,166,515 | - | 347,575,673 |
| ទ្រព្យសកម្មផ្សេងៗ | 1,873,213 | - | - | - | - | 562,163 | 2,435,376 |
| | 139,357,411 | 44,163,439 | 73,572,328 | 50,378,179 | 243,166,515 | 6,819,108 | 557,456,980 |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់ ធនាគារ និង គ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ | (114,000,000) | (53,026,250) | (61,000,000) | - | - | (3,341,234) | (231,367,484) |
| ប្រាក់បញ្ញើរបស់អតិថិជន | (25,774,383) | (41,620,107) | (115,474,609) | (22,963,381) | - | (91,439,041) | (297,271,521) |
| បំណុលផ្សេងៗ | (1,890,603) | - | - | - | | (3,682,346) | (5,572,949) |
| | (141,664,986) | (94,646,357) | (176,474,609) | (22,963,381) | - | (98,462,621) | (534,211,954) |
| **គម្លាតអត្រាការប្រាក់សរុប** | | | | | | | |
| ជាប្រាក់ដុល្លារអាមេរិក | (2,307,575) | (50,482,918) | (102,902,281) | 27,414,798 | 243,166,515 | (91,643,513) | 23,245,026 |
| សមមូលនឹងពាន់រៀល | (9,315,680) | (203,799,540) | (415,416,508) | 110,673,539 | 981,663,221 | (369,964,862) | 93,840,170 |

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.2 ហានិភ័យទីផ្សារ (ត)

(គ) ហានិភ័យអត្រាការប្រាក់ (ត)

| | 1 ខែ | 1-3 ខែ | 3-12 ខែ | 1-5 ឆ្នាំ | លើសពី5ឆ្នាំ | មិនមាន ការប្រាក់ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2015** | | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | - | - | - | - | - | 3,805,590 | 3,805,590 |
| សមតុល្យនៅ ធនាគារកណ្តាល | 56,874,305 | - | - | - | - | - | 56,874,305 |
| សមតុល្យ និង ការដាក់ប្រាក់នៅ ធនាគារ និងគ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ | 18,495,806 | 46,000,000 | 26,000,000 | - | - | - | 90,495,806 |
| ឥណទាន និងបុរេប្រទាន អតិថិជន | 5,180,759 | 9,382,132 | 40,053,420 | 32,742,559 | 251,263,715 | - | 338,622,585 |
| ទ្រព្យសកម្មផ្សេងៗ | 14,543,478 | - | 19,386 | 87,810 | 75,600 | 79,352 | 14,805,626 |
| | 95,094,348 | 55,382,132 | 66,072,806 | 32,830,369 | 251,339,315 | 3,884,942 | 504,603,912 |
| **បំណុលហិរញ្ញវត្ថុ** | | | | | | | |
| ប្រាក់បញ្ញើរបស់ ធនាគារ និង គ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ | (164,726,266) | (44,000,000) | (51,000,000) | - | - | (2,813,061) | (262,539,327) |
| ប្រាក់បញ្ញើរបស់អតិថិជន | (17,542,571) | (50,196,837) | (93,373,804) | (752,510) | - | (54,333,783) | (216,199,505) |
| បំណុលផ្សេងៗ | (3,207,080) | - | - | - | - | (2,410,613) | (5,617,693) |
| | (185,475,917) | (94,196,837) | (144,373,804) | (752,510) | - | (59,557,457) | (484,356,525) |
| **គម្លាតអត្រាការប្រាក់សរុប** | | | | | | | |
| ជាប្រាក់ដុល្លារអាមេរិក | (90,381,569) | (38,814,705) | (78,300,998) | 32,077,859 | 251,339,315 | (55,672,515) | 20,247,387 |
| សមមូលនឹងពាន់រៀល | (366,045,355) | (157,199,555) | (317,119,042) | 129,915,329 | 1,017,924,226 | (225,473,686) | 82,001,917 |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.3 ហានិភ័យសាច់ប្រាក់ងាយស្រួល

ហានិភ័យសាច់ប្រាក់ងាយស្រួល គឺជាហានិភ័យដែលធនាគារ មិនមានលទ្ធភាពបំពេញកាតព្វកិច្ច សងប្រាក់តាមកាលកំណត់សង នៅពេលដែលអតិថិជនមកដកប្រាក់បញ្ញើតម្រូវការសាច់ប្រាក់តាមការចុះកិច្ចសន្យាឬលំហូរសាច់ប្រាក់ចេញផ្សេងៗ។

(ក) ដំណើរការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល

គណៈគ្រប់គ្រងតាមដានសាច់ប្រាក់ងាយស្រួលក្នុងតារាងតុល្យការ និងគ្រប់គ្រងការប្រមូលផ្តុំ និងទិន្នន័យបំណុលដែលមានកាលកំណត់ក៏ដូចជាបម្រែបម្រួលនៃអ្នកផ្ញើប្រាក់សំខាន់ៗ និងគម្រោងនៃការដកសាច់ប្រាក់របស់ពួកគេ។

(ខ) ដំណើរការផ្តល់ប្រភពទុន

ប្រភពទុនចម្បងរបស់ធនាគារ បានមកពីដើមទុនបានបង់របស់ភាគទុនិក ប្រាក់បញ្ញើរបស់ធនាគារនិងគ្រឹះស្ថាន ហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជន។ ប្រភពទុនត្រូវបានត្រួតពិនិត្យប្រចាំថ្ងៃយ៉ាងទៀងទាត់តាមរយៈការត្រួតពិនិត្យរបស់គណៈគ្រប់គ្រង លើកាលកំណត់នៃប្រាក់បញ្ញើមានកាលកំណត់។

(គ) លំហូរសាច់ប្រាក់មិននិទស្សន៍ (Non-derivative cash flow)

តារាងខាងក្រោមនេះបង្ហាញពីលំហូរសាច់ប្រាក់មិនធ្វើអប្បហារ ដែលកើតឡើងពីទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងកិច្ចសន្យាផ្សេងៗរបស់ធនាគារ ដោយផ្អែកតាមកាលកំណត់លើកិច្ចសន្យាដែលនៅសល់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ។

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.3 ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

(គ) លំហូរសាច់ប្រាក់មិននិទស្សន៍ (Non-derivative cash flow) (ត)

| | 1 ខែ | 1-3 ខែ | 3-12 ខែ | 1-5 ឆ្នាំ | លើសពី5ឆ្នាំ | សរុប |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **2016** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | | | | | | |
| និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | (117,360,538) | (53,165,617) | (61,742,647) | - | - | (232,268,802) |
| ប្រាក់បញ្ញើរបស់អតិថិជន | (117,280,607) | (41,915,534) | (118,502,094) | (24,727,675) | - | (302,425,910) |
| បំណុលផ្សេងៗ | (5,572,949) | - | - | - | - | (5,572,949) |
| | (240,214,094) | (95,081,151) | (180,244,741) | (24,727,675) | - | (540,267,661) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | 150,976,415 | 53,595,665 | 110,924,596 | 170,457,040 | 281,166,234 | 767,119,950 |
| **គម្លាតសាច់ប្រាក់ងាយស្រួលសុទ្ធ** | (89,237,679) | (41,485,486) | (69,320,145) | 145,729,365 | 281,166,234 | 226,852,289 |
| សមមូលនឹងពាន់រៀល | (360,252,510) | (167,476,907) | (279,845,425) | 588,309,446 | 1,135,068,087 | 915,802,691 |
| **2015** | | | | | | |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ | | | | | | |
| និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | (167,726,534) | (44,142,147) | (51,409,308) | - | - | (263,277,989) |
| ប្រាក់បញ្ញើរបស់អតិថិជន | (71,804,833) | (50,483,333) | (95,992,979) | (786,063) | - | (219,067,208) |
| បំណុលផ្សេងៗ | (5,617,693) | - | - | - | - | (5,617,693) |
| | (245,149,060) | (94,625,480) | (147,402,287) | (786,063) | - | (487,962,890) |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | 101,449,404 | 60,044,844 | 83,937,240 | 92,007,126 | 272,084,379 | 609,522,993 |
| **គម្លាតសាច់ប្រាក់ងាយស្រួលសុទ្ធ** | (143,699,656) | (34,580,636) | (63,465,047) | 91,221,063 | 272,084,379 | 121,560,103 |
| សមមូលនឹងពាន់រៀល | (581,983,608) | (140,051,576) | (257,033,442) | 369,445,304 | 1,101,941,735 | 492,318,413 |

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.4 ហានិភ័យប្រតិបត្តិការ

ហានិភ័យប្រតិបត្តិការ គឺជាហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីភាពមិនគ្រប់គ្រាន់ ឬបរាជ័យក្នុងដំណើរការគ្រប់គ្រងផ្ទៃក្នុង កត្តាមនុស្ស ឬកត្តាប្រព័ន្ធ ឬហេតុការណ៍ខាងក្រៅ។ កត្តាទាំងនេះរួមមាន ហានិភ័យខាងផ្នែកច្បាប់ ការអនុលោមតាមច្បាប់ គណនេយ្យ និងការក្លែងបន្លំ។

ធនាគារបានបង្កើតច្បាប់ និងនីតិវិធីផ្សេងៗ ដើម្បីផ្តល់នូវការណែនាំដល់ផ្នែកប្រតិបត្តិការសំខាន់ៗ ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យ និងភាពចាំបាច់នៃមូលដ្ឋានក្នុងការគ្រប់គ្រងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីកំណត់អត្តសញ្ញាណ ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យប្រតិបត្តិការរបស់ខ្លួន។ គោលការណ៍គ្រប់គ្រងប្រព័ន្ធផ្ទៃក្នុង និងការវាស់វែងដែលបានអនុវត្ត រួមមានការបង្កើតអាជ្ញាសម្រាប់ការចុះហត្ថលេខា ការគ្រប់គ្រងប៉ារ៉ាម៉ែត្រក្នុងការកំណត់ប្រព័ន្ធ នីតិវិធីធ្វើឲ្យមានប្រសិទ្ធភាព និងការកត់ត្រាឯកសារ ដើម្បីធានានូវអនុលោមភាពទៅតាមតម្រូវការនៃបទប្បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗ។ គោលការណ៍និងនីតិវិធីផ្សេងៗត្រូវបានត្រួតពិនិត្យឡើងវិញតាមកាលបរិច្ឆេទ ដោយពិចារណាទៅលើគោលដៅ និងយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារ និងតម្រូវការរបស់គោលការណ៍ណែនាំផ្សេងៗ។

តួនាទីរបស់សវនកម្មផ្ទៃក្នុង គឺផ្តល់នូវការវាយតម្លៃឯករាជអំពីភាពគ្រប់គ្រាន់នៃគោលការណ៍ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ ដើម្បីបន្ថយហានិភ័យដែលពាក់ព័ន្ធនឹងសកម្មភាពប្រតិបត្តិការ។ ចំពោះការរកឃើញណាមួយដែលកើតពីសវនកម្ម និងការត្រួតពិនិត្យនេះ គណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ និងគណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុនមេ នឹងត្រួតពិនិត្យបន្ថែមទៀតចំពោះការរកឃើញនោះ។

### 25.5 តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោង។ តម្លៃសមស្របដែលបានប៉ាន់ស្មាន គឺផ្អែកទៅលើវិធីសាស្ត្រ និងការសន្មតដូចខាងក្រោម៖

(i) <u>សមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ</u>

តម្លៃសមស្របនៃសមតុល្យ និងការដាក់ប្រាក់នៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ដែលមានកាលកំណត់តិចជាងមួយឆ្នាំ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។

(ii) <u>ឥណទាន និងបុរេប្រទានអតិថិជន</u>

ឥណទានដែលមានអត្រាថេរ និងមានកាលកំណត់សងនៅសល់រយៈពេលតិចជាងមួយឆ្នាំ តម្លៃយោងរបស់វាជាទូទៅគឺមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា។

ចំពោះឥណទានដែលមានអត្រាថេរ និងមានកាលកំណត់សងនៅសល់រយៈពេលមួយឆ្នាំ ឬលើសមួយឆ្នាំ តម្លៃសមស្របរបស់វា ត្រូវបានប៉ាន់ស្មានដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់រំពឹងទុកនាពេលអនាគត និងប្រើអត្រាឥណទានទីផ្សារដែលមានកាលកំណត់សង និងហានិភ័យឥណទានប្រហាក់ប្រហែលគ្នា។

# 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## 25.5 តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ (ត)

(iii) ប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជន

តម្លៃសមស្របនៃប្រាក់បញ្ញើដែលត្រូវសងតាមតម្រូវការ (គណនីចរន្ត និងគណនីសន្សំ) ឬប្រាក់បញ្ញើដែលមានកាលកំណត់សងនៅសល់រយៈពេលតិចជាងមួយឆ្នាំ ត្រូវបានប៉ាន់ស្មានថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃយោងរបស់វា។ តម្លៃសមស្របនៃប្រាក់បញ្ញើដែលមានកាលកំណត់សងនៅសល់រយៈពេលលើសមួយឆ្នាំ ត្រូវបានប៉ាន់ស្មានដោយផ្អែកតាមលំហូរសាច់ប្រាក់អប្បហារ និងប្រើអត្រាឥណទានទីផ្សារ ចំពោះប្រាក់បញ្ញើរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ និងប្រាក់បញ្ញើរបស់អតិថិជនស្រដៀងគ្នា។

(iv) ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ

តម្លៃយោងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានសន្មតថាមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះមិនមានតម្លៃប្រែប្រួលជាសារវន្តទៅតាមអត្រាទីផ្សារទេ។

## 25.6 ការគ្រប់គ្រងដើមទុន

វត្ថុវិស័យរបស់ធនាគារក្នុងការគ្រប់គ្រងដើមទុន ដែលជាបញ្ញត្តិទូលំទូលាយជាង "មូលធន" នៅលើតារាងតុល្យការគឺ៖

- អនុលោមតាមតម្រូវការដើមទុនដែលកំណត់ដោយធនាគារកណ្តាល
- ការពារលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តភាពអាជីវកម្ម ដើម្បីឲ្យធនាគារអាចបន្តផ្តល់ផលប្រយោជន៍ដល់ ភាគទុនិក និងដល់ភាគីផ្សេងៗ ដែលពាក់ព័ន្ធនឹងធនាគារ និង
- រក្សាមូលដ្ឋានដើមទុនរឹងមាំដើម្បីគាំទ្រដល់ការអភិវឌ្ឍអាជីវកម្ម។

ធនាគារកណ្តាលតម្រូវឲ្យធនាគារពាណិជ្ជទាំងអស់ត្រូវ៖ (I) រក្សាដើមទុនអប្បបរមា (II) រក្សាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារយ៉ាងហោចណាស់ឲ្យស្មើនឹងដើមទុនអប្បបរមា និង (III) អនុលោមតាមអនុបាតសាធនភាព និងអនុបាតសាច់ប្រាក់ងាយស្រួល។

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2016

## 25. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### 25.6 ការគ្រប់គ្រងដើមទុន (ត)

តារាងខាងក្រោមនេះ សង្ខេបអំពីសមាសធាតុដើមទុនតាមច្បាប់របស់ធនាគារ ៖

| | 2016 | | 2015 | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ដើមទុនថ្នាក់ទី1** | | | | |
| ដើមទុន | **67,000,000** | 270,479,000 | **67,000,000** | 271,350,000 |
| ចំណេញរក្សាទុក | **17,446,669** | 70,432,203 | **10,749,262** | 43,534,511 |
| ដកៈ ទ្រព្យសកម្មអរូបី | **(295,308)** | (1,192,158) | **(353,150)** | (1,430,258) |
| ដកៈ ឥណទានទៅឲ្យគណៈគ្រប់គ្រង | **-** | - | **(143,938)** | (582,949) |
| | **84,151,361** | 339,719,045 | **77,252,174** | 312,871,304 |
| **ដើមទុនថ្នាក់ទី2** (ដើមទុនបំពេញបន្ថែម) | | | | |
| សំវិធានធនទូទៅ (1%) | **3,447,304** | 13,916,766 | **3,359,494** | 13,605,951 |
| ដកៈ ការចូលរួមដើមទុនក្នុងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | **(25,000)** | (100,925) | **(25,000)** | (101,250) |
| | **87,573,665** | 353,534,886 | **80,586,668** | 326,376,005 |

ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសលេខ ធ7-016-117 ប្រ.ក ចុះថ្ងៃទី22 ខែមីនា ឆ្នាំ2016 ស្តីពីដើមទុនចុះបញ្ជី អប្បបរមាថ្មីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ប្រកាសនេះតម្រូវឲ្យធនាគារពាណិជ្ជដែលត្រូវបានបង្កើតឡើងក្នុងទម្រង់ ជាសាខារបស់ធនាគារបរទេសត្រូវមានដើមទុនចុះបញ្ជីអប្បបរមា យ៉ាងហោចណាស់ 300 ពាន់លានរៀល (ស្មើនឹង 75 លាន ដុល្លារអាមេរិក)។ ប្រកាសនេះ អនុញ្ញាតឲ្យធនាគារ ពាណិជ្ជទាំងអស់បង្កើនដើមទុនរបស់ខ្លួន ឲ្យស្របតាមតម្រូវការដើមទុនអប្បបរមាថ្មីនេះ ក្នុងរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខានៃ ប្រកាសនេះ។

នៅថ្ងៃទី16 ខែមិថុនា ឆ្នាំ2016 ធនាគារកណ្តាលបានចេញផ្សាយសេចក្តីណែនាំស្តីពីការអនុវត្តប្រកាស លេខ ធ7-016-117 ប្រ.ក ចុះថ្ងៃទី22 ខែមីនា ឆ្នាំ2016 ស្តីពីដើមទុនចុះបញ្ជីអប្បបរមាថ្មីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ សេចក្តីណែនាំតម្រូវឲ្យធនាគារទាំងអស់បង្កើនដើមទុនបន្ថែមយ៉ាង ហោចណាស់ 50% នៃចំនួនដើមទុនចុះបញ្ជីអប្បបរមា ត្រឹមដំណាច់ខែមីនា ឆ្នាំ2017 និងចំនួនដែលនៅសល់ ត្រឹមដំណាច់ថ្ងៃទី22 ខែមីនា ឆ្នាំ2018។

ធនាគារទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាល នៅថ្ងៃទី30 ខែធ្នូ ឆ្នាំ2016 និងការអនុម័តពីធនាគារកណ្តាលស្តីពីផែនការការបញ្ចូលដើមទុន ចំនួន 4លានដុល្លារអាមេរិក ក្នុងខែមករា ឆ្នាំ2017 ដើម្បីបំពេញនូវតម្រូវការដើមទុនបន្ថែម ត្រឹមថ្ងៃទី31 ខែមីនា ឆ្នាំ2017។